**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**មន្ទីរអប់រំ យុវជន និងកីឡា ខេត្តតាកែវ**
**ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុកត្រាំកក់**
**វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អង្គតាសោម**

**ចូលរួមអបអរទិវាអំណាន លើកទី៧**

**លើប្រធានបទ៖**

# «តួនាទីអក្សរសិល្ប៍ពុទ្ធនិយម នៅសម័យក្រោយអង្គរ»

**ព.ស. ២៥៦៥**

**គ.ស. ២០២២**

| | |
|---|---|
| -ឈ្មោះ | ៖ **ទឹម សុខហួយ** |
| -ភេទ | ៖ ប្រុស |
| -ថ្ងៃខែឆ្នាំកំណើត | ៖ ០៩ មីនា ១៩៨៩ |
| -មុខរបរ | ៖ គ្រូបង្រៀនអក្សរសាស្ត្រខ្មែរ |
| -អង្គភាពបម្រើការងារ | ៖ វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អង្គតាសោម (ខេត្តតាកែវ) |
| -លេខទូរសព្ទ | ៖ 086 96 77 27 / 088 855 53 53 |

# មាតិកា


១. សេចក្ដីផ្ដើម........................................................................................................១
២. បញ្ញត្តិនៃអក្សរសិល្ប៍ពុទ្ធនិយម..........................................................................៣
៣. ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍ខ្មែរសម័យក្រោយអង្គរ..................................................៥
២.១. អក្សរសិល្ប៍ខ្មែរសម័យលង្វែក..........................................................................៨
២.២. អក្សរសិល្ប៍ខ្មែរសម័យឧដុង្គ............................................................................៩
៤. ប្រភេទអក្សរសិល្ប៍ពុទ្ធនិយម...........................................................................១១
៥. លក្ខណៈពិសេសនៃអក្សរសិល្ប៍ពុទ្ធនិយម..............................................................១៣
៦. ឥទ្ធិពលពុទ្ធសាសនាក្នុងសង្គម..........................................................................១៦
៧. តួនាទីអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរ...................................................១៧
៧.១. តួនាទីអប់រំដើម្បីស្វែងរកសច្ចភាពនៃជីវិត.............................................................១៧
៧.២. តួនាទីកម្សាន្តបន្ទូរអារម្មណ៍ផ្សារភ្ជាប់ការអប់រំ.........................................................២០
៧.៣. តួនាទីអប់រំស្វែងរកសច្ចភាពនៃជីវិតតាមរយៈស្នាដៃអក្សរសិល្ប៍ទសជាតក.............................២០
៧.៤. តួនាទីកម្សាន្តតាមរយៈស្នាដៃអក្សរសិល្ប៍មរណមាតា.....................................................៤៨
៨. សន្និដ្ឋាន...................................................................................................៤៩

## ១. សេចក្តីផ្តើម

ពុទ្ធសាសនាមានដើមកំណើតនៅប្រទេសឥណ្ឌាក្នុងសតវត្សទី៦ មុនគ្រិស្តសករាជ ប្រហែលគ្នានឹងកំណើតព្រាហ្មណ៍និយមដែរ។ នៅសតវត្សទី ៣មុនគ្រិស្តសករាជ ក្នុងរជ្ជកាល**ព្រះបាទអសោក**ពុទ្ធសាសនាត្រូវបានផ្សព្វផ្សាយពាសពេញទាំងក្នុងប្រទេសឥណ្ឌាទាំងក្រៅប្រទេស។ តាមប្រវត្តិសាស្រ្តកន្លងមក គេបានដឹងថានៅពុទ្ធសតវត្សទី៣(ព.ស.២៣៤)គឺមុនគ.ស.៣០០ឆ្នាំម្ល៉េះ ព្រះបាទអសោកពុទ្ធសាសនិកដ៏ឆ្នើមក្នុងប្រទេសឥណ្ឌាបានបញ្ជូនសមណទូត ពីរអង្គគឺ**ព្រះសោណត្ថេរ** និង**ព្រះឧត្តរត្ថេរ**ឱ្យនាំយកពុទ្ធសាសនាថេរវាទមកផ្សាយនៅសុវណ្ណភូមិ(អាស៊ីអាគ្នេយ៍)។

តាមសិលាចារឹកវ៉ូកាញ់(នៅវៀតណាមខាងត្បូង)ទំនងជាពុទ្ធសាសនាចូលមកប្រតិស្ឋានក្នុងប្រទេសខ្មែរនៅសតវត្សទី២ នៃគ្រិស្តសករាជក្នុងរជ្ជកាល**ព្រះបាទស្រីមារៈ ឬហ្វាន់ចេរម៉ែន**។ ស្ថាបនិកនៃពុទ្ធសាសនា គឺព្រះពុទ្ធគោតម(៥៦៤-៤៨៣មុនគ. ស.)។ ព្រះអង្គបានចូលបរិនិព្វាននៅប្រទេសឥណ្ឌាភាគឦសាន ពេលដែលទស្សនៈឥណ្ឌាបុរាណកំពុងចោទជាបញ្ហាអំពីសុពលភាពនៃសម្មតិកម្មខ្លះៗជាគ្រឹះផ្ទាល់របស់ខ្លួន។ ប៉ុន្តែព្រះធម៌ជាពាក្យប្រៀនប្រដៅទាំងឡាយ និងឥទ្ធិពលរបស់ព្រះអង្គបានផ្សព្វផ្សាយទៅ ទូទាំងទ្វីបអាស៊ីភាគកណ្តាល ខាងត្បូង និងខាងជើងដែលនៅទីនោះៗបានបន្តផ្តល់ឱ្យមានចំណងវប្បធម៌រួមគ្នាមួយ ហើយព្រះធម៌ជាពាក្យប្រៀនប្រដៅរបស់ព្រះអង្គក៏ត្រូវបានគេស្គាល់នាពេលសព្វថ្ងៃនេះ នៅក្នុងអឌ្ឍគោលខាងលិចផងដែរ ។ នៅពេលខាងក្រោយមក ពុទ្ធសាសនាត្រូវបែកចេញជានិកាយផ្សេងៗ។ និកាយទាំងឡាយនោះ នៅតែបានរក្សាប្រពៃណីនៃជីវភាពរបស់ព្រះអង្គ។ ប្រពៃណីទាំងនោះភាគច្រើនឃើញមាននៅក្នុងភាសាបាលី ភាសាសំស្រ្កឹត ភាសាចិន និងភាសាទីបេ ។ ចេញពីភាសាទាំងនោះ ការសិក្សាប្រវត្តិសាស្រ្តសម័យថ្មី ស្វែងរកឃើញក្របខណ្ឌព្រឹត្តិការណ៍សំខាន់ៗ មានស្ថិរភាពបង្គួរនៅក្នុងចរិតមួយ ដែលគេនៅតែធ្វើបុណ្យអបអរ សាទរនៅឡើយក្រោយពេល ២៥០០ឆ្នាំបានកន្លងទៅ។

ឯកសារអក្សរសិល្ប៍ គឺជាឃ្លាំងផ្ទុកនូវចំណេះដឹងស្តីពីបាតុភូតជាក់ស្តែងដែលកើតមាននៅក្នុងជីវភាពរស់នៅរបស់មនុស្ស (រាប់បញ្ចូលទាំងសង្គមមនុស្សថ្នាក់ទាបបំផុត រហូតដល់សង្គមមនុស្សថ្នាក់ខ្ពស់បំផុត) ពោលគឺអក្សរសិល្ប៍គឺជាកញ្ចក់សម្រាប់ខ្លួនបញ្ចាំងនូវតថភាពសង្គម នូវហេតុការណ៍ទាំងឡាយ ដែលមាននៅក្នុងសង្គមមនុស្សក្រុមមនុស្សប្រភេទមនុស្ស ប្រពៃណី ទំនៀមទម្លាប់ ភូមិសាស្រ្តប្រវត្តិសាស្រ្តជាដើម ។ ម្យ៉ាងវិញទៀតរាល់អត្ថបទអក្សរសិល្ប៍ គឺសុទ្ធតែបានផ្តល់ដល់អ្នកអាននូវបញ្ហារបស់មនុស្សនាសម័យណាមួយជាមិនខាន ។ ឧទាហរណ៍ បើយើងអានរឿងទុំទាវ នោះយើងនឹងបានដឹងពី ជីវភាពរស់នៅរបស់ប្រជាជនខ្មែរនាសម័យលង្វែក ហើយបើយើងអានរឿងភូមិតិរិច្ឆាន នោះយើងនឹងអាចដឹងពី ជីវភាពរបស់ប្រជាជនខ្មែរនាសម័យអាណានិគមបារាំង។

សម័យក្រោយអង្គរ ប្រទេសខ្មែរមានវិបរិតដោយសារតែសង្គ្រាម។ គ្រោះមហន្តរាយទាំងអស់នេះធ្វើឱ្យការសិក្សា តែងនិពន្ធ ក្បួនខ្នាត ឬការចងក្រងកត់ត្រានូវព្រឹត្តិការណ៍ផ្សេងៗថយចុះជាលំដាប់។ ទោះជាយ៉ាងនេះក៏ដោយ អ្នកនិពន្ធ កវីបណ្ឌិតខ្មែរពុំលះបង់សេចក្តីព្យាយាមចងក្រងអត្ថបទរឿងរ៉ាវកត់ត្រាលើថ្ម និងការលើក្រាំង ឬស្លឹករឹតដើម្បីលាតត្រដាងនូវទឹកចិត្តរបស់ខ្លួនសម្រាប់ទុកជាកេរមរតក និងជាវិភាគទានយ៉ាងធំក្នុងវិស័យវប្បធម៌ អរិយធម៌ជាតិដែរ។ អត្ថន័យនៃអត្ថបទមានលក្ខណៈរឿងប្រឌិតតាមបែបមនោសញ្ចេតនា ។ រឿងក្នុងជាតកបែបបាលី បានច្នៃតែងផ្សំប្រមុំតាមចិត្តគំនិតរបស់ខ្លួន ដើម្បីសម្របទៅតាមជំនឿ បញ្ហាជីវភាពរស់នៅនាសម័យនោះ។ អត្ថបទភាគច្រើនសរសេរជាពាក្យកាព្យមានបទកាកគតិ ពំនោល ព្រហ្មគីតិ បទភុជង្គលីលាជាដើម ។

អក្សរសិល្ប៍ពុទ្ធនិយម គឺជាអក្សរសិល្ប៍ដែលទទួលឥទ្ធិពលពីព្រះពុទ្ធសាសនា។ រឿងក្នុងគោលពុទ្ធនិយម មានលក្ខណៈខុសប្លែកពី រឿងក្នុងគោលព្រាហ្មណ៍និយម ដោយគោលគំនិតធំ ឬ មូលបញ្ហានៃរឿងពុទ្ធនិយម គឺការសាងបារមីរបស់ព្រះពោធិសត្វ ដើម្បីបានត្រាស់ជាព្រះពុទ្ធ ។ ដំណោះស្រាយបញ្ហាក្នុងរឿងពុទ្ធនិយម គឺអហិង្សា ឬ សន្តិវិធី ។ រីឯតួអង្គឯកប្រុសជាព្រះពោធិសត្វ និងតួអង្គឯកស្រីជាកន្សែសព៌ផ្ទ ។ ចុងបញ្ចប់នៃរឿង គឺការសេរជាតិ ។ រឿងក្នុងអក្សរសិល្ប៍ពុទ្ធនិយម មានពីរបែប គឺរឿងពុទ្ធនិយមសុទ្ធសាធ និងរឿងបែបពុទ្ធនិយមក្លាយ[1]។

ដូច្នេះ ការសិក្សាអក្សរសិល្ប៍នាពេលនេះ គឺយើងធ្វើការសិក្សាឱ្យយល់ពីប្រវត្តិអក្សរសិល្ប៍ខ្មែរតាមសម័យកាលនីមួយៗទៅតាមលំដាប់លំដោយតាំងពីសម័យបុរាណរហូតដល់សម័យបច្ចុប្បន្ន ដោយយើងនឹងធ្វើការសិក្សាពីសម័យទាំងនោះតាមរយៈស្នាដៃរបស់អ្នកនិពន្ធនីមួយៗដូចតទៅ ។

## ២.បញ្ញត្តិអក្សរសិល្ប៍ពុទ្ធនិយម

អក្សរសិល្ប៍ពុទ្ធនិយម > អក្សរសិល្ប៍ + ពុទ្ធនិយម

### ២.១.បញ្ញត្តិ "អក្សរសិល្ប៍"

អក្សរសិល្ប៍ជាសព្ទមួយ ដែលមានការផ្តល់និយមន័យទីទៃពីគ្នាដ៏ច្រើន ពីសំណាក់អ្នកសិក្សាខាងវិជ្ជាមួយនេះ ដូចជា៖

- ក្នុងវចនានុក្រមខ្មែរ បោះពុម្ពគ្រាទី៥នៅឆ្នាំ១៩៦៧ បានបង្ហាញថា៖ អក្សរសិល្ប៍ > អក្សរ + សិល្ប៍
- **អក្សរ** ស្នាមគំនូសមានរាងផ្សេងៗសម្រាប់ប្រើសរសេរកត់ត្រាពាក្យសេចក្តី និងសម្តីទាំងពួងមិនចេះអស់។
- **សិល្ប៍** សំដៅដល់ការរចនាតាក់តែងដ៏វិចិត្រផ្សេងៗ។ ម្យ៉ាងទៀតខ្មែរច្រើនហៅចំមន្តអាគមផ្សេងៗ។
- លោក កេង វ៉ាន់សាក់ (១៩២៥-២០០៨) នៅក្នុង "ទិដ្ឋភាពខ្លះចំពោះអក្សរសិល្ប៍ខ្មែរ" បានឱ្យនិយមន័យអក្សរសិល្ប៍នេះថា ៖ "**អក្សរសិល្ប៍**គឺជាវិទ្យាស្បង់ ដែលចោទ និងដោះស្រាយបញ្ហាមនុស្សទៅតាមសង្គមនីមួយៗ និងដោយសិល្បវិធី"។
- លោក លាង ហាប់អាន បានកំណត់និយមន័យនៃពាក្យអក្សរសិល្ប៍ថា ៖ "**អក្សរសិល្ប៍**ជាការសម្គាល់អក្សរសាស្ត្រដែលទាក់ទងនឹងផ្នែកផ្សេងៗនៃការតែងនិពន្ធដូចជា សន្ទស្សន៍អក្សរសិល្ប៍ (ប្រភេទ) ប្រលោមអក្សរសិល្ប៍ (មនោគតិ) នាដ្យកម្មអក្សរសិល្ប៍ ឧបទេសអក្សរសិល្ប៍ ឧបាម្ភអក្សរសិល្ប៍ និងសុន្ទរកថា»។[2]
- លោកបណ្ឌិត ធ សោ បានឱ្យនិយមន័យអក្សរសិល្ប៍ថា ៖ "**អក្សរសិល្ប៍** គឺជាពាក្យបណ្តាំពាក្យពេចន៍ ឃ្លាប្រយោគ"។

### ២.២.បញ្ញត្តិ "អក្សរសិល្ប៍ពុទ្ធនិយម»

**អក្សរសិល្ប៍ពុទ្ធនិយម** គឺជាការនិយមរាប់អានទៅលើទ្រឹស្តីរបស់ព្រះពុទ្ធបរមគ្រូនៃយើង។ លោកបណ្ឌិត ញ៉ុក ថែម បានឲ្យនិយមន័យថា ៖ តាមធម្មតា រឿងជាតកទាំងឡាយដែលស្ថិតនៅលើមូលដ្ឋាននៃចលនាពុទ្ធនិយម តែងមានរបៀបនិពន្ធជាបីយ៉ាង គឺមានសេចក្តីផ្តើមរឿង ដំណើរសេចក្តីរឿង និងបញ្ចប់រឿងដោយការសេរជាតិ[3] ។

[1] ក្រសួងអប់រំ, អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ ទំព័រ៦៥

[2] លាង ហាប់អាន សិក្សាអត្ថបទ ភាគទី១ (សិក្សាស្នាដៃអក្សរសិល្ប៍ខ្មែរ) ភ្នំពេញ ១៩៦៦ ទំព័រ២៦ ។

[3] បណ្ឌិត ញ៉ុក ថែម បញ្ញាសជាតក ទំព័រ១ (១៩៦៣)

ចំណែកលោក ជុំ កាណាល់ បានឲ្យនិយមន័យថា ៖ **អក្សរសិល្ប៍ពុទ្ធនិយម**ក្នុងទីនេះ ទោះបីលើកយកកម្ម និងផល មកធ្វើជាធំក្ដី។ បានសេចក្ដីថា បើនរណាប្រព្រឹត្តអំពើល្អ ពិតជាឲ្យផលល្អនៅខាងក្រោយ តែបើនរណាប្រព្រឹត្តនូវបាបកម្មអាក្រក់ ក៏ប្រាកដជានឹងទទួលកម្មអកុសលជាក្រោយវិញមិនខានឡើយ[4] ។

ជាមួយគ្នានេះដែរ លោកបណ្ឌិត ឈឹម សុមន៍ សាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់ ក៏បានបញ្ជាក់នៅក្នុងស្នាដៃរបស់ព្រះអង្គថា៖ **អក្សរសិល្ប៍ពុទ្ធនិយម** ជាឯកសារជារឿងរ៉ាវផ្សេងៗ ដែលនិយាយដល់ការកសាងបារមីរបស់តួអង្គពោធិសត្វ ដើម្បីបានត្រាស់ដឹងជាព្រះពុទ្ធក្នុងអនាគតជាតិ[5]។

ចំណែកលោក លី ធាមតេង អ្នកស្រាវជ្រាវអក្សរសាស្ត្រខ្មែរក៏បានបញ្ចេញទស្សនៈក្នុងស្នាដៃរបស់ខ្លួនថា ៖ **អក្សរសិល្ប៍ពុទ្ធនិយម**គឺជាអតីតប្រវត្តិរបស់ព្រះសក្យមុនីគោត្តមបរមគ្រូ មុនព្រះជាតិដែលបានត្រាស់ដឹង។ រឿងនេះប្រភពដើមជាភាសាបាលី មាននៅក្នុងគម្ពីរខុទ្ទកនិកាយជាតមហានិបាត ដែលគេប្រកាន់ជឿថាព្រះពុទ្ធវចនៈ ហើយនិងក្នុងគម្ពីរជាតកអដ្ឋកថា មានជាង ២០០០ឆ្នាំមកហើយ[6]។

អក្សរសិល្ប៍ពុទ្ធនិយម និងអក្សរសិល្ប៍ទាំងឡាយណា ដែលលើកយកលទ្ធិរបស់ព្រះពុទ្ធមកធ្វើការឆ្លុះបញ្ចាំង ត្រូវលះបង់នូវអំពើអាក្រក់ ហើយទៅជឿបុណ្យបាប ខិតខំកសាងកុសលដើម្បីបានសេចក្ដីសុខបច្ចុប្បន្នជាតិ និងអនាគតជាតិ។ **អក្សរសិល្ប៍ពុទ្ធនិយម** គឺជាអក្សរសិល្ប៍មួយបែប ដែលទទួលឥទ្ធិពលពីលទ្ធិព្រះពុទ្ធសាសនា បានចាក់ឫសយ៉ាងជ្រៅនៅលើទឹកដីយើងតាំងពីយូរយារណាស់មកហើយ ទាំងក្នុងបេះដូងមនុស្ស និងលើគ្រប់វិស័យ[7]។

ពុទ្ធសាសនាមានកំណើតនៅប្រទេសឥណ្ឌា តាំងពីសតវត្សរ៍ទី៦មុនគ្រិស្តសករាជ ហើយបានចូលមកប្រទេសកម្ពុជាក្នុងអំឡុងសតវត្សរ៍ទី១ ប៉ុន្តែមានឥទ្ធិពលតិចតួច លុះដល់ចុងសម័យអង្គរក៏ចាប់ផ្ដើមរីកចម្រើន និងមានឥទ្ធិពលខ្លាំងនៅសម័យកណ្ដាលរហូតមក។

បើយោងទៅតាមអត្ថន័យ និងកាលបរិច្ឆេទ គេអាចបែងចែកអក្សរសិល្ប៍ពុទ្ធនិយមជាបីប្រភេទ[8] គឺ៖

- អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធសាធ (គម្ពីរទសជាតក)
- អក្សរសិល្ប៍ពុទ្ធនិយមក្លែងក្លាយ (គម្ពីរបញ្ញាសជាតក)
- អក្សរសិល្ប៍ពុទ្ធនិយមក្លែងក្លាយហួសហេតុ (សាស្ត្រាល្បែង)

និយាយពីអក្សរសិល្ប៍ពុទ្ធនិយមនេះ យើងឃើញថាអ្នកសិក្សាបានចែកអក្សរសិល្ប៍ពុទ្ធនិយមនេះជាបីគឺ

**អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធ** និយាយដ៏ដំណើរជប់ជាតិរបស់ព្រះពុទ្ធ ដែលយើងហៅថា«ទសជាតក» ក្នុងនោះរួមមានរឿងតេមិយជាតក មហាជនកជាតកសុវណ្ណសាមជាតក នេមិរាជជាតក វិធូរជាតក ព្រះវេស្សន្តរជាតក...។

**អក្សរសិល្ប៍ពុទ្ធនិយមក្លាយ** យើងហៅថា បញ្ញាសជាតក ឬជាតក៥០ទាំងអស់នេះ សុទ្ធតែនិយាយពីរឿងរ៉ាវទាក់ទងនឹងព្រះពុទ្ធបរមគ្រូនៃយើង ចំនួន៥០ជាតិ ត្រូវបានអ្នកនិពន្ធបញ្ចេញបញ្ចូលទស្សនៈរបស់ខ្លួនមួយចំនួនផង

---

[4] ជុំ កាណាល់ សិក្សាស្វែងយល់អក្សរសាស្ត្រខ្មែរសង្ខេបបែបទំនើប ទំព័រ២៦ (១៩៨៦)

[5] បណ្ឌិត ឈឹម ស៊ុមន៍ សង្ខេបទសជាតក ទំព័រ១៨ (១៩៥៩)

[6] លី ធាមតេង អក្សរសាស្ត្រខ្មែរ ទំព័រ ៣៥ (១៩៦៦)

[7] បណ្ឌិត ធ សោ អក្សរសិល្ប៍ពុទ្ធនិយម ទំព័រ ៤ (១៩៩៤)

[8] បណ្ឌិត ញ៉ុក ថែម បញ្ញាសជាតក ទំព័រ ១ (១៩៦៣)

ដែរ។តាមទស្សនៈអ្នកសិក្សាមួយបាននិយាយថា ៖ ចំពោះបញ្ញាសជាតកពាក្យនេះប្រែថា ជាតក៥០រឿង ឬ៥០ជាតក។ ច្បាប់ដើមជាភាសាបាលី ជាគម្ពីរសាស្ត្រាស្លឹករឹត។ គម្ពីរនេះគេឃើញមានប្រទេសនៅក្នុងតំបន់ឥណ្ឌូចិន គឺមានប្រទេសខ្មែរ ថៃ លាវ និងភូមា។ ក្នុងនេះយើងលើកយកឈ្មោះទាំង ៥០ នោះ មកបង្ហាញដូចទសជាតកទេ[9]។ បញ្ញាសជាតកនេះ ពិតមែនតែជាគម្ពីរបាលី ហើយក៏មិនមែនជាគម្ពីររបស់ជំនាន់មុន ឬជំនាន់អង្គរទេ គឺជាគម្ពីរអ្នកប្រាជ្ញភាសាបាលីបាននិពន្ធឡើងក្រោយសម័យអង្គរ ជាសម័យដែលប្រជាជនខ្មែរ លែងជឿជាក់ប្រកាន់លទ្ធិព្រាហ្មណ៍សាសនា និងព្រះពុទ្ធសាសនាមហាយាន ហើយបែរមកគោរពព្រះពុទ្ធសាសនាហីនយានវិញ។ **អក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ ឬអក្សរសិល្ប៍ពុទ្ធនិយមផ្លូម** គឺជារឿងរ៉ាវ ដែលនិយាយទាក់ទងនឹងអតីតតួអង្គព្រះពុទ្ធបរមគ្រូនៃយើងមានចំនួន៥០រឿង ឬ៥០ជាតក យើងហៅថាអក្សរសិល្ប៍ល្បែង ឬសាស្ត្រាល្បែង មានការពេញនិយមខ្លាំង ចាប់តាំងពីសម័យលង្វែកមកម្ល៉េះ។

## ៣. ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍ខ្មែរសម័យក្រោយអង្គរ

តាមការសិក្សាស្រាវជ្រាវបានឱ្យដឹងថា បន្ទាប់ពីមានភាសាសម្រាប់និយាយប្រាស្រ័យទាក់ទងគ្នាមកមនុស្សបានបង្កើតតួអក្សរដើម្បីកត់ត្រាចារភាសាទាំងនោ ដូច្នេះបុព្វបុរសខ្មែរយើងក៏មានគំនិតបង្កើតភាសា ដោយខ្ចីតួអក្សរព្រាហ្មី ពីឥណ្ឌាភាគខាងត្បូងយកមកប្រើ [10] ។ ការដែលមានភាសា និងការមានអក្សររបស់ជនជាតិនីមួយៗនេះហើយ ដែលបង្កើតបានជាអក្សរសាស្ត្រ-អក្សរសិល្ប៍ឡើង។ យ៉ាងណាមិញ អក្សរខ្មែរយើងបានចាប់មានកំណើតតាំងពីសម័យនគរភ្នំមកម្លេះ បើសំអាងលើសិលាចារឹក**វ៉ូកាញ់** ស.វទី៣ នៃគ.ស. ដែលនេះសបញ្ជាក់ឱ្យឃើញថា អក្សរខ្មែរបានកើតឡើង ហើយមានការវិវត្តប្រែប្រួលទៅតាមបេត់សង្គម។ តួយ៉ាងដូចជានៅចុងសម័យអង្គរ លទ្ធិទេវរាជបានថយចុះឥទ្ធិពលរបស់ខ្លួនបន្តិចម្តងៗ ទន្ទឹមនឹងការហូរចូលមកដល់នៃព្រះពុទ្ធសាសនា (ហីនយាន) ដែលនាំចូលពីស្រីលង្កា។ សាសនាថ្មីនេះ បានរីកចម្រើនយ៉ាងឆាប់រហ័សក្នុងសតិអារម្មណ៍របស់ប្រជាពលរដ្ឋខ្មែរនាសម័យនោះហើយមានប្រៀបជាងព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនាមហាយាន ។ ទន្ទឹមនឹងនោះ ខ្មែរយើងក៏បានទទួលភាសាមួយទៀត គឺ**ភាសាបាលី** ។ ជាបណ្តើរៗ ខ្មែរបានបោះបង់ចោលភាសាសំស្ក្រឹត ប៉ុន្តែខ្មែរមិនបង់ភាសាខ្លួនចោលទាំងស្រុងនោះទេ ហើយអ្វីដែលពិសេសនោះ គឺខ្មែរយើងរក្សា និងបង្កើតភាសាជាតិ ដោយបានកាឡៃពាក្យបាលីឱ្យមានសូរសំឡេងជាភាសាខ្មែរថែមទៀត ។ឧទាហរណ៍ ៖ ជយ > ជ័យ អាចម> អាចម៌ ... ជាដើម

**អក្សរសិល្ប៍សម័យក្រោយអង្គរ ឬសម័យកណ្តាល** គឺសំដៅចំពោះសំណុំ ចង្កោមអត្ថបទទាំងឡាយណាដែលអ្នកនិពន្ធរចនាឡើងជាភាសាខ្មែរកណ្តាល គឺគិតចាប់ពីស.វ ទី១៥ ដល់ ស.វ ទី១៩ ដែលភាគច្រើនជាអត្ថបទសាស្ត្រា ឬក្រាំង។ អក្សរសិល្ប៍សម័យនេះមាន សម័យលង្វែក(១៤៣១-១៦១៨) សម័យឧដុង្គ(១៦១៨-១៨៦៣) និងសម័យអាណានិគមបារាំង(១៨៦៣-១៩៥៣) ។

បើតាមលោក លាង ហាប់អាន[11] លោកបានបែងចែកសម័យកាលប្រវត្តិអក្សរសាស្ត្រខ្មែរជា៤ ផ្នែកធំៗគឺ៖

- សម័យនគរភ្នំ ស.វ.ទី១ ដល់ ស.វ.ទី៦
- សម័យមុនអង្គរ ស.វ.ទី៦ ដល់ស.វ.ទី៩

[9] បណ្ឌិត ញ៉ុក ថែម មហាវេស្សន្តរជាតក ទំព័រ ២៣ (១៩៦៣)

[10] ត្រឹង ងា , អរិយធម៌ខ្មែរ, ឆ្នាំ១៩៧៥ ទំព័រ៩៣

[11] លាង ហាប់អាន, *សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរសម័យនគរភ្នំ ដល់សម័យឧដុង្គ (ស.វ.ទី១ ដល់ឆ្នាំ១៨៥៩)* ឆ្នាំ១៩៦៧ ទំព័រ៥-១១។

- សម័យអង្គរ ស.វ.ទី៩ ដល់ស.វ.ទី១៤
- សម័យក្រោយអង្គរ ចុងស.វ.ទី១៤ ដល់បច្ចុប្បន្ន ហើយនៅក្នុងផ្នែកទី៤នេះ លោកបានបែងចែកជាបីផ្នែកតូចៗទៀតគឺៈ
    - សម័យលង្វែក ១៥២៥-១៥៩៣
    - សម័យឧដុង្គ ចាប់ពីរជ្ជកាលព្រះបាទជ័យជេដ្ឋា(១៦១៨-១៦២៨) ដល់រជ្ជកាលអង្គឌួង(១៨៤៥-១៨៥៩)
    - សម័យក្រុងភ្នំពេញ គិតចាប់ពីឆ្នាំ១៨៥៩ រហូតដល់សព្វថ្ងៃ។

រីឯលោក ឃីង ហុកឌី[12] គេបានបែងចែកអក្សរសិល្ប៍ទៅតាមសម័យកាលប្រវត្តិសាស្ត្រគឺៈ

- សម័យមុនអង្គរ ស.វ.ទី១ ដល់ស.វ.ទី៩
- សម័យអង្គរ ស.វ.ទី៩ ដល់ស.វ.ទី១៥
- សម័យក្រោយអង្គរ ស.វ.ទី១៥ ដល់ស.វ.ទី១៨
- សម័យបារាំង ឆ្នាំ១៨៦៣-១៩៥៣
- សម័យបច្ចុប្បន្ន ឆ្នាំ១៩៥៣ ដល់បច្ចុប្បន្ន។

បើនិយាយពីចុងសម័យអង្គរ គឺបច្ចាមិត្របានរុករានទន្ទ្រានប្រទេសខ្មែរ នាំឱ្យស្តេចខ្មែរលើករាជធានីមកតាំងនៅចតុមុខវិញ តែនៅតែមិនទទួលបានសេចក្តីសុខក្សេមក្សាន្តដដែល ពោលគឺដោយមានបញ្ហាធំពីរគឺ ការឈ្លានពានពីសំណាក់បរទេស និងទំនាស់វិបត្តិផ្ទៃក្នុង ដែលបានជះឥទ្ធិពលអាក្រក់ដល់វិស័យនានាក្នុងសង្គមខ្មែរ ជាពិសេសគឺវិស័យអក្សរសាស្ត្រ។ ក៏ប៉ុន្តែទោះបីជាស្រុកទេសស្ថិតក្នុងសភាពមានវិបត្តិច្របូកច្របល់ក៏ដោយ ក៏វប្បធម៌ជាតិ អក្សរសាស្ត្រជាតិ បានជ្រកពួនតាមទីវត្តអារាមដែលមានព្រះសង្ឃជាអ្នកការពារ និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋខ្មែរ ។ វត្តអារាមជាសាលារៀន ហើយសិក្ខាកាមនៅសាលាវត្តនេះហើយ ដែលជាអ្នកផលិតអក្សរសាស្ត្រនាសម័យកណ្តាល ដោយបានចារសរសេរលើវត្ថុស្រាលៗ ដូចជា ស្លឹករឹត ស្លឹកត្នោត និងក្រាំង ។

**ចំពោះការកត់ត្រាលើឯកសារទាំងនោះមាន៣បែបគឺៈ**

- <u>បែបទី១</u> : កត់ត្រាលើក្រាំង ដែលមានសន្លឹកបើកបានសងខាង។ គេសរសេរដោយប្រើស្លាបប៉ា)ឬស្លាបសត្វជាមួយទឹកខ្មៅចិន។ សន្លឹកក្រដាសនេះធ្វើនៅក្នុងប្រទេស ហើយមានកម្រាស់ក្រាស់ អាចរក្សាទុកបានយូរ ដោយធ្វើពីស្លឹកស្នាយ និងស្លឹកមន ។
- <u>បែបទី២</u> : កត់ត្រាលើក្រាំងដូចបែបទី១ដែរ តែក្រដាសមានពណ៌ខ្មៅ ហើយសរសេរដោយដីសថ្ម។
- <u>បែបទី៣</u> : កត់ត្រាលើស្លឹករឹតដោយប្រើដែកចារចោះទម្លុះ ហើយមានចោះរន្ធចងខ្សែតាមលេខរៀងទំព័រ ដែលយើងហៅថា សាស្ត្រា ។

ក្នុងសំណុំចង្កាមឯកសារសម័យកណ្តាលទាំងនេះ លោក ***អូ ឈៀង*** បានចែកជា៣ប្រភេទគឺៈ

- **សាស្ត្រាទេសន៍**: ជាអត្ថបទទាក់ទងនឹងការសម្តែងធម៌ ពោលគឺការអប់រំទាក់ទងនឹងពុទ្ធសាសនា។
- **សាស្ត្រាល្បែង** : ជាអត្ថបទសម្រាប់អានកម្សាន្តចិត្ត ឱ្យសប្បាយរីករាយ បំពេរអារម្មណ៍ឱ្យរន្ធត់ញាប់ញ័រភ្លើតភ្លើន ដោយកម្រងភាសាដ៏ប្រណិត។

[12] ឃីង ហុកឌី, *ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ* ឆ្នាំ១៩៧៧ ទំព័រ២៣-២៤។

- **សាស្ត្រាក្បួន** : គឺជាអត្ថបទដែលតាក់តែងជាក្បួនខ្នាត បែបបទ ឬកំណត់ជាគោលចារឹកនៃការធ្វើអ្វីមួយ ដូចជា ក្បួនទាយ ក្បួនថ្នាំ ក្បួនច្បាប់ ក្បួនសាវតារ ។ល។

ចំពោះផ្នែកសិលាចារឹកវិញ ចាប់តាំងពីដើម ស.វ ទី១៤ រៀងមក អ្នកសិក្សាស្រាវជ្រាវពុំឃើញមានសិលាចារឹកនៅប្រទេសខ្មែរទៀតទេ(ទោះបីទំហំខ្លីខ្លី វែងក្តី)។ លុះមកដល់រជ្ជកាលព្រះបាទចន្ទរាជា ទោះបីពេលនោះ រាជធានីពិតប្រាដកតាំងនៅលង្វែកក៏ដោយក៏ព្រះរាជាខ្មែរតែងតែនាំមន្ត្រីបរិវារទៅតំបន់អង្គរ ហើយបានកសាងសិលាចារឹកឡើងវិញ ដោយធ្វើការចារសិលាចារឹកនៅប្រាសាទអង្គរវត្ត ៣អន្លើ គឺនៅត្រង់[13]៖

- សិលាចារឹកនៅ ***ព្រះពាន់*** ត្រង់ដែលមានព្រះពុទ្ធរូបច្រើន។
- សិលាចារឹកនៅថ្នាក់លើបំផុតហៅថា ***បាកាណ***។
- សិលាចារឹកលេខ៣៨ ***នៅព្រះរបៀងថ្នាក់ក្រោម*** គឺស្ថិតពីខាងកើតត្រង់ព្រះចេតិយដោយថ្មបាយក្រៀម។

សិលាចារឹកទាំងនោះ មាន៤០ផ្ទាំង មានចុះគោលកំណត់ពី គ.ស. ១៥៦៥ដល់១៧៤៦។ ប៉ុន្តែសករាជដែលប្រើ គឺមហាសករាជ។

សេចក្តីក្នុងសិលាចារឹកនោះ និយាយពីរឿងធ្វើបុណ្យផ្សេងៗ គឺប្រោសខ្ញុំឱ្យរួចជាអ្នកជា បំបួសមនុស្ស លាបំណន់ សាងព្រះ សាងពិដាន និងថ្វាយរបស់ជាពុទ្ធបូជា។ល។ ជាស្តេចខ្លះ ជាមន្ត្រីខ្លះ[14]។ អ្នកស្រាវជ្រាវមួយក្រុមបានបន្ថែមសេចក្តីទៀតថា«*សេចក្តីអស់នោះ ជាពាក្យចាលចាញ់ ហើយមានទីពឹង ទីរលឹក ចំពោះព្រះរតនត្រ័យប៉ុណ្ណោះ ជាអ្នកសុខចិត្តទទួលព្រមសេចក្តីលំបាកវេទនាដោយយល់ថាវាជាផលនៃកម្មអាក្រក់ ដែលខ្លួនបានធ្វើក្នុងអតីតជាតិ តែពុំបានអស់កម្លាំងនឹងសេចក្តីប្រឹងប្រែងឡើយ គេតែងតែខំសន្សំបុណ្យកុសល ដើម្បីសេចក្តីចម្រើនដល់ខ្លួន និងដល់ប្រទេស*»[15]។

ភាសាដែលគេប្រើក្នុងសិលាចារឹកទាំងនោះ ជាភាសាខ្មែរធម្មតាក្នុងសម័យកណ្តាល និងមានពាក្យពេចន៍បុរាណលាយឡំខ្លួនដែរ តែយើងអាចមើលយល់សេចក្តីបាន ។ តួយ៉ាង សិលាចារឹកនគរវត្តរបស់បណ្ឌិត ជ័យនន្ទ ក៏ស្ថិតនៅសម័យនេះដែរ ដោយយោងតាមសូរ និងអក្សរ។

ដូច្នេះ ក្រោយសម័យអង្គរ ឬសម័យកណ្តាល គឺគិតចាប់ពីការចាកចោលក្រុងអង្គររហូតដល់សម័យអាណានិគមបារាំង ដែលជាសម័យប្រែប្រួលខ្លាំងនៃស្នាដៃអក្សរសិល្ប៍ ជាពិសេសគឺ ការកើតឡើងប្រភេទអក្សរសិល្ប៍ថ្មី គឺការកត់ត្រាលើស្លឹករឹត(សាស្ត្រា) ហើយដែលការប្រែប្រួលនេះ គឺអាស្រ័យទៅលើស្ថានភាពសង្គម(ស្ថានភាពប្រវត្តិសាស្ត្រ ស្ថានភាពនយោបាយដឹកនាំ ស្ថានភាពជំនឿសាសនា ស្ថានភាពអប់រំ និងជីវភាពរស់នៅ) ដែលនេះសបញ្ជាក់ឱ្យឃើញពីភាពទំនាក់ទំនងគ្នារវាងសង្គម និងអក្សរសាស្ត្រ ។

[13] ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ១៩៧៣ ភាគ២ ទំព័រ៨០

[14] សិលាចារឹកនគរវត្ត និងបទានុក្រម ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ឆ្នាំ១៩៥៨។

[15] គោលប្រវត្តិនៃអក្សរសាស្ត្រខ្មែរ ដោយប្រជុំសាស្ត្រាចារ្យ ការផ្សាយរបស់បណ្ណាគារភ្នំពេញ ឆ្នាំ១៩៥៦។

## ៣.១. អក្សរសិល្ប៍ខ្មែរសម័យលង្វែក

អក្សរសិល្ប៍ សម័យលង្វែកគឺជាអក្សរសិល្ប៍មួយរបស់ខ្មែរដែល ចាប់គិតពីឆ្នាំ(១៤៣១ដល់ ១៦១៨)[16] ។ យើងបានដឹងរួចមកហើយថា សម័យលង្វែក ជាសម័យដែលខ្មែរបានចាកចោលក្រុងអង្គរក៏ដូចជាការចាកចោលព្រហ្មញ្ញសាសនា(ពិធីទេវរាជ) និងអាចនិយាយបានថា ជាសម័យដែលខ្មែរចុះអន់ថយ ទាំងខាងផ្នែកកសាង និងផ្នែកការពារ ។ ជាមួយគ្នានេះដែរ វិស័យតែងនិពន្ធក៏បានងាកទៅរកភាពស្រមើស្រមៃតាមបែបជំនឿសាសនា ហើយចំពោះស្នាដៃដែលជាអក្សរសាស្ត្រ-អក្សរសិល្ប៍ គេឃើញមានដូចជា សិលាចារឹកនិងសាស្ត្រា។ ក្នុងចំណោមសាស្ត្រា (សាស្ត្រាទេសន៍ សាស្ត្រាល្បែងនិងសាស្ត្រាក្បួន), សាស្ត្រាល្បែងមាននៅតិចតួចណាស់ ហើយយើងពុំទាន់រកឃើញនូវកាលបរិច្ឆេទនៃការតែងនិពន្ធបញ្ជាក់ឱ្យបានច្បាស់នៅឡើយទេ ព្រោះសាស្ត្រាទាំងនោះ ត្រូវបាត់បង់ដោយសារសង្គ្រាម ជាពិសេសនៅពេលដែលសៀមវាយបែកបន្ទាយលង្វែក ។

និន្នាការអក្សរសិល្ប៍នៅសម័យលង្វែកត្រូវបានកត់ត្រាឡើងជាពីរប្រភេទគឺ កត់ត្រានៅលើថ្ម(សិលាចារឹក) និងកត់ត្រាលើក្រាំង សាស្ត្រា ។

- **ផ្នែកសិលាចារឹក**

នៅសម័យលង្វែកយើងឃើញមានសិលាចារឹកមួយផ្ទាំង ដែលមានចុះកាលបរិច្ឆេទ ហើយអត្ថបទសិលាចារឹកនេះនិពន្ធដោយ បណ្ឌិត ជ័យ នន្ទ ។ សរសេរជាអត្ថបទកំណាព្យមាន១០៩ល្បះ ដែល៤៥ល្បះខាងលើសរសេរជាបទព្រហ្មគីតិ ៥៩ល្បះបន្ទាប់សរសេរជាបទកុជង្គលីលា និង៥ល្បះចុងក្រោយសរសេរជាបទកាកគតិ ។ តាមរយៈខ្លឹមសារនៃអត្ថបទសិលាចារឹកឃើញថា វាមាននិន្នាការទៅរកព្រះពុទ្ធសាសនា ព្រោះបណ្ឌិតជ័យ នន្ទ បានធ្វើការអធិដ្ឋានសុំកើតជាតិក្រោយៗបានជួបប្រសព្វតែក្នុង**ព្រះពុទ្ធសាសនា** ។

- **ផ្នែកសាស្ត្រា**

សាស្ត្រាសម័យលង្វែកពិតជាមានច្រើន ប៉ុន្តែក្នុងចំណោមនោះឃើញមានតែល្បើកអង្គរវត្តមួយទេដែលមានចុះកាលបរិច្ឆេទ។ ថ្វីត្បិតតែរឿងល្បើកនេះ បានលើកឡើងពីតួអង្គអមនុស្សក្តីតែបានបង្ហាញយ៉ាងច្បាស់ពីស្ថានឬបញ្ហារបស់មនុស្សសុទ្ធសាធ ។

ស្នាដៃមួយដែលគេស្គាល់ឈ្មោះអ្នកនិពន្ធពិតប្រាកដគឺ ល្បើកអង្គរ និពន្ធដោយ អ្នកប៉ាង ក្នុងឆ្នាំ១៥៩៨ ជាពាក្យកាព្យ និយាយពីការកសាងប្រាសាទអង្គរវត្តតាមរបៀបរឿងទេពនិទាន។ ប៉ុន្តែអ្នកស្រាវជ្រាវខ្មែរ បានកំណត់រឿងនេះឱ្យខិតមកមុខបន្តិច គឺនៅឆ្នាំ១៦០៩វិញ[17]។

*តើសាស្ត្រាល្បែងគឺជាអ្វី ?*

ដែលហៅថា **សាស្ត្រាល្បែង** គឺជារឿងរ៉ាវទាំងឡាយ ដែលសរសេរជាពាក្យកាព្យ មានច្រើនខ្សែ ហើយកវីច្រើនផ្អែកលើការយល់សប្តិ លើមន្តអាគម ចេះហោះ ចេះហើរ ដើរលើអាកាស ជ្រែកទឹក ជ្រែកដី ដែលមនុស្សធម្មតាមិនអាចធ្វើបាន និងមិនសមហេតុផល ។ កវីទាំងនោះ លោកបង្កើតរឿងទាំងនេះឡើងគឺដើម្បីចង់សម្រាលទុក្ខប្រជារាស្ត្រដែលរងទុក្ខវេទនាដោយសារស្រុកទេសកើតសង្គ្រាម។ ក្រៅពីអត្ថបទខាងលើនេះ មានអត្ថបទទូន្មានជាច្រើនសម្រាប់

---

[16] ម៉ក់ ស៊ីនេត *អក្សរសិល្ប៍ក្រោយអង្គរ*

[17] ឃួន សុខម្ភ *គំនិតរិះគន់សង្គមក្នុងអក្សរសិល្ប៍ខ្មែរ* សន្និសីទធ្វើទៅសាលាជាតិខាងរដ្ឋបាល នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៤ នៅភ្នំពេញ ។

អប់រំខ្លួន និងកូនចៅជំនាន់ក្រោយៗទៀត។ ច្បាប់ទាំងនោះ មានន័យសម្រាប់ការអប់រំ និងពត់មនុស្សឱ្យចេះរស់នៅក្នុងសង្គម និងគោរពច្បាប់( ច្បាប់ធម្មជាតិ និងច្បាប់រដ្ឋ ) ។

ជាការគួរឱ្យសោកស្ដាយ ព្រោះមានសាស្ត្រាស្លឹករឹត និងកាំងជាច្រើនត្រូវវិនាសខូចខាតខ្ទេចខ្ទីអស់ជាច្រើន ដែលនេះទំនងជាមកពីសត្រូវជិតខាង ដែលចូលមកលុកលុយក្នុងប្រទេសកម្ពុជា គេនាំគ្នាដឹកជញ្ជូនយកទ្រព្យសម្បត្តិទាំងនោះ ទៅទុកជាទ្រព្យសម្បត្តិគេផ្ទាល់ ហើយម្យ៉ាងទៀត ប្រហែលជាត្រូវភ្លើងឆេះ ក្នុងគ្រាមានសង្គ្រាមនោះផងក៏មិនដឹង។ ប្រសិនបើមាននៅសេសសល់ គឺយើងសង្កេតឃើញមាននៅតាមទីវត្តអារាម តែច្រើនតែពុំមានឈ្មោះអ្នកនិពន្ធទេ ។ ចំពោះរឿងនេះ មានមតិខ្លះយល់ថា មកពីរបបគ្រប់គ្រង ទើបធ្វើឱ្យអ្នកនិពន្ធខ្លាច មិនហ៊ានបញ្ចេញឈ្មោះខ្លួនឱ្យគេស្គាល់ និងមានមតិខ្លះថា មកពីអ្នកចារមានទម្លាប់អាក្រក់មួយ គឺលុបបំបាត់ឈ្មោះនអ្នកនិពន្ធចោល ហើយតាំងខ្លួនជាអ្នកនិពន្ធជំនួសវិញ។

## ៣.២. អក្សរសិល្ប៍ខ្មែរសម័យឧដុង្គ

### ក- អត្ថន័យនៃអត្ថបទ

អត្ថបទរឿងរ៉ាវផ្សេងៗនៃសម័យឧដុង្គគឺសឹងតែជាទូទៅ មានលក្ខណៈជារឿងប្រឌិត ចងក្រងតាមបែបមនោសញ្ចេតនា។ អ្នកនិពន្ធជ្រើសរើសយករឿងក្នុង**ជាតកបែបបាលី** (បញ្ញាសជាតក ឬជាតក ក្នុងអដ្ឋកថា[18] នៃព្រះត្រៃបិតកជាដើម) មកកែច្នៃតាក់តែងតាមទស្សនៈរបស់អ្នកនិពន្ធ ដើម្បីសម្រេចទៅតាមជំនឿ ការរស់នៅ ( ស្របតាមកាលៈទេសៈ) របស់មនុស្សនាសម័យនោះ ។ គេឃើញមានរឿងផ្សងព្រេង ដោយមានអច្ឆរិយៈហេតុផ្សេងៗដូចជា តួអង្គទេវៈ ខ្មោចយក្ខ អារក្ស អ្នកតា ឬមនុស្សមានមន្តអាគមខ្លាំងពូកែ (ចេះហោះហើរ កាប់មិនមុតដុតមិនឆេះ) យកមកនិទាន ។

សម័យកាលនោះ មនុស្សហាក់បីដូចជាអស់សង្ឃឹមក្នុងជីវិត ហើយប្រើមនោគតិជឿទៅលើហេតុផលអស្ចារ្យដែលខ្លួនយល់ថាពូកែ អាចជួយរំដោះទុក្ខលំបាក ឬបញ្ហាស្មុគស្មាញរបស់ខ្លួនក្នុងបច្ចុប្បន្ននិងអនាគតជាតិ ។ ក្នុងន័យនេះ គេយកទស្សនៈកម្មផល( ព្រះពុទ្ធសាសនា) មកធ្វើជាបញ្ហាចោទ និងស្រាយក្នុងអត្ថន័យនៃអត្ថបទរឿងជាច្រើននាសម័យឧដុង្គ ។

ការកើតមាននូវ**បញ្ហាកម្មផល** ជាមូលហេតុក្នុងរឿងនៃអក្សរសាស្ត្របែបនេះ បុព្វហេតុគឺមកពីការភិតភ័យលំបាកវេទនារបស់ប្រជាពលរដ្ឋ ដោយសារស្រុកទេសកើតចម្បាំងរាំងដល់ ដែលបង្កឡើងដោយពួកសត្រូវឈ្លានពាន ប្លន់ទឹកដីខ្មែរនាសម័យឧដុង្គ ដើម្បីរំសាយនូវទុក្ខសោកពោគភ័យ ដែលញាំញីក្នុងសន្ដានចិត្តរបស់ខេមរជន ។ ចំពោះហេតុការណ៍នេះ អ្នកនិពន្ធបានរិះរកមធ្យោបាយមួយ ដើម្បីព្យាបាលនោះ គឺ**ឱសថ**(ភាពអស្ចារ្យ) និង (បញ្ហាកម្មផល) ដើម្បីជួយអ្នករងគ្រោះ ដូចជា តួអង្គព្រះពោធិសត្វ(បញ្ហាកម្មផល) ដោយយកទស្សនៈបាប បុណ្យ ល្អ អាក្រក់ សុខ ទុក្ខ មកធ្វើជាគោលបញ្ហាដោះស្រាយ ឧទាហរណ៍ អ្នកណាធ្វើល្អបានល្អ អ្នកណាធ្វើអាក្រក់បានអាក្រក់ជាដើម ។

ឯរង្វាន់ផ្ដល់ចំពោះមនុស្សល្អ គេបានបង្កើតឋានសួគ៌ ឋានទេវលោក សម្រាប់លើកទឹកចិត្ត ហើយដើម្បីផ្ដន្ទាទោសចំពោះមនុស្សអាក្រក់ គេក៏បង្កើតឋាននរកប្រេត សម្រាប់បំភ័យឱ្យអនុជនខ្លាច ស្អប់អកុសលកម្ម ហើយខិតខំ

[18] ពាក្យអធិប្បាយសេចក្តីឱ្យងាយយល់ ។

ធ្វើអំពើល្អ។ គ្រប់អត្ថបទអក្សរសិល្ប៍នៅសម័យឧដុង្គអ្នកនិពន្ធមានទិសដៅសម្រាលទុក្ខសោករបស់ប្រជាពលរដ្ឋឱ្យមានសភាពធូរស្រាល និងមានសង្ឃឹមក្នុងឆាកជីវិតរស់នៅ។

**ខ- អត្ថរូបនៃអត្ថបទ**

វិធីតាក់តែងអត្ថបទសម័យឧដុង្គ គេបានប្រើពាក្យកាព្យជាមធ្យោបាយ។ អត្ថបទអក្សរសិល្ប៍ចេនាឡើងជាកំណាព្យមានបទផ្សេងៗគ្នា (បទកាកគតិ ព្រហ្មគីតិ ពំនោល ជាដើម) នោះ ជាមធ្យោយសម្របសម្រួលទៅតាមគោលបំណងក្នុងឧត្តមគតិរឿង ដែលបំពេញអារម្មណ៍ បន្ធូរក្តីទុក្ខព្រួយឱ្យរសាយ ។

របៀបតែងមានដូចខាងក្រោមនេះ៖

***សេចក្តីផ្តើម*** : ជាបទនមស្ការ ព្រះរតនត្រ័យ រំលឹកគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ រំលឹកគុណព្រះមហាក្សត្រ មាតាបិតា គ្រូបាធ្យាយជាដើម ។ ឯកសារខ្លះមានបញ្ជាក់កាលបរិច្ឆេទនៃការតាក់តែងរបស់អ្នកនិពន្ធ ។ ឆ្នាំដែលគេប្រើ ច្រើនជាពុទ្ធសករាជ មហាសករាជ ហើយមានប្រាប់ឈ្មោះងារស័ក្តិលំនៅដ្ឋានរបស់អ្នកនិពន្ធ។ ស្នាដៃខ្មែរទៀតមានបញ្ជាក់ពីប្រភពរឿង ដែលអ្នកនិពន្ធបានដកស្រង់យកមកតាក់តែងរចនា។ ប៉ុន្តែរឿងមួយភាគធំ បែរជាពុំមាន ឬបាត់នូវកាលបរិច្ឆេទ និងឈ្មោះអ្នកនិពន្ធជាដើម ។

***តួសេចក្តី*** អ្នកនិពន្ធច្រើនប្រើភាសាបាលី មគធភាសា ឬសំស្ក្រឹត ទៅតាមចំណេះដឹងរបស់អ្នកនិពន្ធ ក្នុងការតាក់តែងរៀបរៀងរឿង។ ដំណើររឿងជឿលើបញ្ញាកម្មផល ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់។

***បញ្ចប់សេចក្តី*** អ្នកនិពន្ធបញ្ចប់រឿង ដោយធ្វើការឧទ្ទិសប្រាថ្នាកុសលបែបអធិដ្ឋាន ឬការសរជាតិ (ដំណើររឿងមានប្រភពពីព្រះពុទ្ធសាសនា) ។

**គ- អត្ថរសនៃអត្ថបទ**

ដោយដំណើររឿង ជារឿងសម្រាលទុក្ខប្រជាពលរដ្ឋ ដូច្នេះរឿងត្រូវមានភាពអស្ចារ្យ អច្ឆរិយៈ( អច្ឆរិយរស) ធម្មតា( សាមញ្ញរស) កំសត់( ទារុណរស) កំប្លែង (ហាសរស) ដែលជាលក្ខណៈទ្រទ្រង់នៃអត្ថរសទូទៅរបស់អត្ថបទ ។

**ឃ. សេចក្តីសន្និដ្ឋាន**

សរុបសេចក្តីមក អក្សរសិល្ប៍ខ្មែរនាសម័យឧដុង្គមានការរីកចម្រើនឡើងវិញ គឺដោយសារតែព្រះមហាក្សត្រនាម៉ឺនសព្វមុខមន្ត្រីគ្រប់ជាន់ថ្នាក់បានយកព្រះទ័យ និងយកចិត្តទុកដាក់ជាខ្លាំងទៅលើវិស័យនេះ ។ បើទោះបីជាអ្នកនិពន្ធតាក់តែងប្រឌិតរឿងតាមលក្ខណៈអណ្តែតអណ្តូងនិយមយ៉ាងណាក៏ដោយ ក៏វាមានតម្លៃយ៉ាងពិតប្រាកដមួយដែរ ព្រោះតាមរយៈស្នាដៃទាំងនេះហើយ ដែលបានជួយលើកស្ទួយអក្សរសាស្ត្រជាតិឱ្យស្ថិតនៅរហូតដល់សព្វថ្ងៃ ។ ម្យ៉ាងវិញទៀត ទោះបីជាស្នាដៃទាំងនោះ បានទទួលឥទ្ធិពលពីសាសនាក៏ដោយ ក៏ដំណើររឿងបានបង្ហាញពីជីវភាពរស់នៅជាក់ស្តែងរបស់សង្គមមនុស្សដូចជា៖ បញ្ហាស្នេហា បញ្ហាកិត្តិយស បញ្ហាផិតក្បត់ បញ្ហាច្រណែនឈ្នានីស ជាដើម ហើយអ្វីដែលពិសេសជាងនេះទៅទៀតនោះគឺ ស្នាដៃអក្សរសិល្ប៍នាសម័យឧដុង្គ បានដល់នូវចំណេះដឹងខាងផ្នែកអប់រំតាមបែបព្រះពុទ្ធសាសនា ដោយផ្តោតទៅលើបញ្ញាកម្មផល បុណ្យ និងបាប ដែលបុគ្គលម្នាក់ៗបានធ្វើឡើង។

ដូច្នេះស្នាដៃអក្សរសិល្ប៍សម័យឧដុង្គ គឺពិតជាមានសារប្រយោជន៍ និងបានចូលរួមចំណែកក្នុងការទ្រទ្រង់វិស័យអក្សរសាស្ត្រជាតិឱ្យឆ្ពោះទៅរកវឌ្ឍនភាពយ៉ាងពិតប្រាកដ ។

## ៤. ប្រភេទអក្សរសិល្ប៍ពុទ្ធនិយម

ដោយយោងទៅលើអត្ថន័យរបស់រឿង និងកាលបរិច្ឆេទតែង គេចែកអក្សរសិល្ប៍ពុទ្ធនិយមជាពីរប្រភេទគឺៈ អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធ និងអក្សរសិល្ប៍ពុទ្ធនិយមក្លាយ។

### ៤.១. អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធសាធ

រឿងពុទ្ធនិយមសុទ្ធសាធ គឺសំដៅលើរឿងទសជាតក ឬរឿងនានាជាតក ដែលដំណើររឿងទាក់ទងនឹងទស្សនៈគោលសំខាន់ៗក្នុងព្រះពុទ្ធសាសនា ដោយអ្នកនិពន្ធលើកយករឿងបុណ្យ បាបកម្មផលល្អអាក្រក់របស់តួអង្គមកចោទ និងដោះស្រាយ ។ រឿងទាំងឡាយត្រូវបានរៀបរៀងឡើងជាភាសាបាលី តែក្រោយមកមានសម្រាយជាខេមរភាសា មានសរសេរជាពាក្យកាព្យ ។ ចំពោះអត្ថបទសរសេរជាពាក្យរាយគេច្រើន សរសេរឱ្យឈ្មោះថា រឿងជាតកឬគម្ពីរជាតក គម្ពីរទសជាតក គម្ពីរបញ្ញាសជាតក គម្ពីរនានាជាតកជាដើម ។ រឿងក្នុងជាតក គឺជារឿងរបស់ព្រះពុទ្ធអង្គ កាលកំពុងវិលអន្ទោលយកកំណើតក្នុងបុព្វជាតិ ដើម្បីត្រាស់ដឹង ដើម្បីស្រង់សត្វលោក ដែលស្ថិតក្នុងវាលវដ្តសង្សារ។ រឿងក្នុងទសជាតកជារឿងដែលព្រះពោធិសត្វកសាងបារមីដូចជា ៖

- រឿង តេមិយជាតក បំពេញ នេក្ខកម្មបារមី
- រឿង មហាជនក បំពេញ វិរិយបារមី
- រឿង សុវណ្ណសាម បំពេញ មេត្តាបារមី
- រឿង នេមិរាជ បំពេញ អធិដ្ឋានបារមី
- រឿងមហោសថជាតក បំពេញ បញ្ញាបារមី
- រឿងភូរិទត្តជាតក បំពេញ សីលបារមី
- រឿងចន្ទកុមារជាតក បំពេញ ខន្តីបារមី
- រឿងនារទជាតក បំពេញ ឧបេក្ខាបារមី
- រឿងវិធុរជាតក បំពេញ សច្ចៈបារមី
- រឿង ព្រះវេស្សន្តរ បំពេញ ទានបារមី

ក្នុងការបែងចែកលំដាប់នៃការបំពេញបារមីនៃអង្គពោធិសត្វ ក្នុងវចនានុក្រមសម្តេចជួនណាតបានបង្ហាញថា ទសបារមី[19] ឬបារមី ១០ គឺចរិយាដ៏លើសលន់ ឬគុណជាតិដ៏ល្អ ដែលគួរបំពេញមាន ១០ យ៉ាងគឺ ៖

- ទានបារមី ៖ ការធ្វើអំណោយ
- សីលបារមី ៖ ការរក្សាកាយវាចាឱ្យបរិសុទ្ធប្រពៃ
- នេក្ខម្មៈបារមី ៖ ការចេញចាកកាម គឺចេញបួស
- បញ្ញាបារមី ៖ ការដឹងច្បាស់នូវសេចក្តីពិត
- វីរិយៈបារមី ៖ ព្យាយាម
- ខន្តីបារមី ៖ សេចក្តីអត់ធន
- សច្ចៈបារមី ៖ ការកាន់សំដីពិតមិនវេរ៉ុះ
- អធិដ្ឋានបារមី ៖ ការអធិដ្ឋានឲ្យឃើញជាក់ស្តែងតាមហេតុពិត

[19] សម្តេច ជួន ណាត, វចនានុក្រមខ្មែរ ១៩៦៧

– មេត្តាបារមី ៖ ការផ្សាយសេចក្តីរាប់អានចំពោះសព្វសត្វមិនរើសមុខ
– ឧបេក្ខាបារមី ៖ ដំណើរតាំងចិត្តដើយព្រងើយដោយស្មោះស្មើ ។

បារមីទាំង ១០ នេះឯងដែលពោធិសត្វរាល់ព្រះអង្គបំពេញឱ្យបានត្រាស់ជាព្រះសព្វញ្ញុពុទ្ធ ។

### ៤.២. អក្សរសិល្ប៍ពុទ្ធនិយមក្លាយ

រឿងពុទ្ធនិយមក្លាយចែកជាពីរ[20]៖ ពុទ្ធនិយមក្លាយធម្មតា និងពុទ្ធនិយមក្លាយហួសហេតុ(ផ្លូម)។

**ក. រឿងពុទ្ធនិយមក្លាយធម្មតា** : ជាអត្ថបទដែលទាក់ទងនឹងទស្សនៈក្នុងព្រះពុទ្ធសាសនាតិចតួចហើយរឿងទៀតសោតពុំស្ថិតក្នុងគម្ពីរត្រឹមត្រូវជាពុទ្ធវចនៈ(ក្នុងគម្ពីរព្រះត្រៃបិតក) ដូចជារឿងទសជាតកឡើយ ។ អត្ថបទរឿងបែបពុទ្ធនិយមក្លាយច្រើនស្ថិតក្នុងគម្ពីរបញ្ញាសជាតក(៥០ជាតិ) មាន៥០រឿង ។ បញ្ញាសជាតករបស់ខ្មែរមាន[21]៖

| | | | | |
|---|---|---|---|---|
| ១-សមុទ្ទឃោសៈ | ២-សុធនកុមារ | ៣-សុធនុកុមារ | ៤-រតនប្បជោត | ៥-សិរីវិបុលកិត្តិ |
| ៦-វិបុលរាជ | ៧-សិរិចូឌាមណី | ៨-ចន្ទរាជ | ៩-សុភមិត្រ | ១០-សិរិធរសេដ្ឋី |
| ១១-សព្វសិទ្ធិ | ១២-ទុលកបណ្ឌិត | ១៣-អាទិត្តរាជ | ១៤-ទុកម្មានិក | ១៥-មហាសុរសេន |
| ១៦-កនកវណ្ណរាជ | ១៧-វិរិយបណ្ឌិត | ១៨-ធម្មសោណ្ឌក | ១៩-សុទស្សមហារាជ | ២០-វត្តង្គលីរាជ |
| ២១-បោរាណកបិលរាជ | ២២-ធម្មិកបណ្ឌិតរាជ | ២៣- ចាគទាន | ២៤-ធម្មរាជ | ២៥-នរជីវៈ |
| ២៦-សុរូប | ២៧-មហាបទុម | ២៨-ភណ្ឌាការ | ២៩-ពហុលគាវី | ៣០-សេតបណ្ឌិត |
| ៣១-បុប្ផរាជ | ៣២-ពារាណសិរាជ | ៣៣-ព្រហ្មឃោសរាជ | ៣៤-ទេវរុក្ខកុមារ | ៣៥-សលកៈ |
| ៣៦-សោនន្ទ | ៣៧-ទេវន្ទ | ៣៨-នរជីវកឋិន | ៣៩-រថសេន | ៤០-វរនេវរនុជ |
| ៤១-សងបត្ត | ៤២-សព្វសិទ្ធិ | ៤៣-សិសោរាជ | ៤៤-សុបិនកុមារ | ៤៥-សុបិនកុមារ |
| ៤៦-សុវណ្ណកច្ឆបៈទី១ | ៤៧-សុវណ្ណកច្ឆបៈទី២ | ៤៨-សុវណ្ណវង្ស | ៤៩-សុរវង្សវរវង្ស | ៥០-អតិទេវរាជ |

**ខ. រឿងពុទ្ធនិយមក្លាយហួសហេតុ** : ស្នាដៃប្រភេទនេះពុំមាននៅក្នុងគម្ពីរក្បួនខ្នាតពីបុរាណណាមួយឱ្យបានច្បាស់លាស់ទេ ប្រសិនបើមានបញ្ជាក់ក្បួនខ្នាតដើម គម្ពីរដើម គឺអ្នកនិពន្ធគ្រាន់តែថាប៉ុណ្ណោះ ពុំមានដំណើររឿងដូចគ្នាបេះបិទឡើយ ។ ដំណើររឿងមានគោលគំនិតទាក់ទងនឹងពុទ្ធទស្សនៈតែបន្តិចបន្តួច ចំណែកឯតួអង្គនៃរឿងច្រើនមានសកម្មភាពប្រកបដោយគុណវិបត្តិហួសហេតុ រហូតដល់មនុស្សធម្មតាធ្វើមិនកើត ហើយរឿងពុំមានការកសាងបារមីអ្វីមួយច្បាស់លាស់ឡើយ តែទោះជាតួអង្គធ្វើអំពើខុសយ៉ាងណាក្តី លុះដល់ចប់រឿងមានការសជាតិ អ្នកនិពន្ធប្រារព្ធថា តួអង្គនោះជាព្រះពោធិសត្វ។ អក្សរសិល្ប៍ប្រភេទនេះច្រើនជាសាស្ត្រាល្បែង ដែលកើតនៅសតវត្សរ៍ទី១៨ ឬទី១៩ ដែលមានឈ្មោះអ្នកនិពន្ធច្បាស់លាស់ដូចជា៖

– រឿងក្រុងសុភមិត្រ និពន្ធដោយ កោសាធិបតីកៅ ១៧៩៨
– រឿងភោគកុលកុមារ និពន្ធដោយ ឧកញ៉ាព្រះឃ្លាំងនង ១៨០៤
– រឿងកាកី និពន្ធដោយ ព្រះបាទអង្គឌួង ១៩១០
– រឿងមរណមាតា និពន្ធដោយ ឥន្ទបញ្ញាអ៊ុក ១៨៧៧

---

[20] ក្រសួងអប់រំ, អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២, ទំព័រទី៩៧, ២០១៦

[21] ក្រសួងអប់រំ, សៀវភៅគ្រូ ភាសាខ្មែរ ថ្នាក់ទី១០, ទំព័រទី៧៣,២០១២

## ៥. លក្ខណៈសម្គាល់នៃអក្សរសិល្ប៍ពុទ្ធនិយម

### ៥.១. វិធីតែងនិពន្ធ

***ក.ផ្នែកអត្ថន័យ***

អត្ថន័យរឿងច្រើនទាក់ទងនឹងការកសាងបារមីរបស់តួអង្គព្រះពោធិសត្វ ទាក់ទងនឹងជំនឿកម្មផល ។

***ខ.បញ្ហាចោទ និងដោះស្រាយ***

បញ្ហាចោទស្ថិតនៅលើទំនាស់វិបត្តិរវាងព្រះពោធិសត្វ និង ទ្រព្យសម្បត្តិ រវាងទ្រពសម្បត្តិ និង បិតា ភរិយា ដើម្បីផ្តាច់លោភៈ ទោសៈ មោហៈ និង ស្នេហា រវាងទ្រព្យសម្បត្តិ និង ប្រជាពលរដ្ឋ។ដំណោះស្រាយបញ្ហានៅក្នុងរឿង គឺតាមបែបសន្តិវិធី អហិង្សា ។ បង្ហាញពីស្នេហាស្មោះត្រង់រវាងពោធិសត្វ និងកន្សែសារពេជ្ជ ។ នៅទីបញ្ចប់ពោធិសត្វ ទទួលជ័យជំនះ បានជួបជុំគ្រួសារឡើងសោយរាជ្យ ត្រូវបានមហាជនគោរព និង សរសើរចំពោះបារមីរបស់ព្រះអង្គ។

***គ.ផ្នែកអត្ថរូប***

មានលក្ខណៈ ឯកភាពគ្នាដូចតទៅ :

**គ.១-ផ្តើមរឿង**

អ្នកនិពន្ធច្រើនចាប់ផ្តើមរឿងដោយធ្វើបទនមសការគោរពព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និង ការនឹកគុណដល់ មាតា បិតា គ្រូបាធ្យាយ ។

**គ.២.តួរឿង ឬ ដំណើររឿង**

ជាការបរិយាយប្រៀបបាននឹងធម៌ទេសនារបស់ព្រះពុទ្ធអង្គចំពោះភិក្ខុសង្ឃ ពុទ្ធបរិស័ទទាំងឡាយ ដើម្បី មើលឃើញពីការកសាងបារមីរបស់ព្រះអង្គដ៏ស្ថិតស្ថាញក្នុងអនេកជាតិ ។ ច្រើនបំពេរចិត្តគំនិតពុទ្ធសាសនិកឱ្យជឿ បុណ្យបាប ខ្លាចអំពើអាក្រក់ ។ ប័រលាយរឡំរវាងពុទ្ធចក្រ និង ចក្រ ។

- តួអង្គក្នុងអក្សរសិល្ប៍ពុទ្ធនិយម : តួអង្គឯកប្រុសជាពោធិសត្វ តួអង្គឯកនារីជាកន្សែសារពេជ្ជដែល ជាគូរបស់ ព្រះពោធិសត្វ ។
- កាលអាកាស : ច្រើនប្រព្រឹត្តទៅក្នុងនគរពារាណសី សាវត្ថី ស្រុកស្រីពិរាស្ត្រ កលិង្គរាស្ត្រ លង្កា ព្រៃហេមពាន្ត ..ពោលគឺនៅប្រទេសឥណ្ឌា ។

**គ.៣.បញ្ចប់រឿង**

បញ្ចប់ដោយការសរជាតិ ឱ្យតួអង្គពោធិសត្វសំរេចជោគជ័យក្នុងសកម្មភាពអ្វីមួយរដោយការលើកសរសើរ ប្រសិទ្ធពរចំពោះការបំពេញកុសលកម្ម រក្សាសីលរហូតអស់ជន្មាយុ រួចទៅកើតក្នុងស្ថានេតុសិតទេវលោកសោយ សម្បត្តិទិព្វ សុខក្សេមក្សាន្ត ។

### ៥.២.គោលគំនិតអប់រំរបស់អក្សរសិល្ប៍ពុទ្ធនិយម

អក្សរសិល្ប៍ពុទ្ធនិយម បានបង្កប់នូវតម្លៃអប់រំយ៉ាងជ្រាលជ្រៅក្នុងការដុសខាត់ចិត្តគំនិតមនុស្សសង្គមខ្មែរ ឱ្យ ប្រព្រឹត្តនូវអំពើល្អស្រឡាញ់នូវគុណធម៌ ស្រឡាញ់សុខសន្តិភាព គ្មានការប្រកាន់វណ្ណៈ មិនមានការលោភលន់ ជា ពិសេស រួមចំណែកក្នុងការអភិវឌ្ឍសង្គមជាតិគ្រប់វិស័យទាំងអស់។ ខាងក្រោមនេះ យើងសូមលើកយកទស្សនៈអប់រំ សំខាន់ៗ ក្នុងអក្សរសិល្ប៍ពុទ្ធនិយមដូចតទៅ ៖

**ក. អប់រំឱ្យជឿលើទស្សនៈកម្មផល**

គ្រប់ស្នាដៃអក្សរសិល្ប៍ពុទ្ធនិយម នៅក្នុងដំណើររឿងតាំងពីដើមដល់ចប់ អ្នកនិពន្ធបានបង្ហាញពីទស្សនៈកម្មផល ពោលគឺធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ ហើយកម្មនេះវាផ្តល់ឲ្យអ្នកប្រព្រឹត្តក្នុងអតីតជាតិ បច្ចុប្បន្នជាតិ និងអនាគតជាតិ។ ទស្សនៈនៃព្រះពុទ្ធសាសនា បានអប់រំមនុស្សឲ្យប្រព្រឹត្តអំពើល្អគ្រប់បែបយ៉ាង ដែលគំនិតនោះ វាជួយឲ្យមនុស្សរស់នៅក្នុងសុខសន្តិភាពគ្មានអំពើហិង្សា។

**ខ. អប់រំកាយ វាចា និងចិត្ត**

លទ្ធិព្រះពុទ្ធសាសនា ក៏ដូចជាអក្សរសិល្ប៍ពុទ្ធនិយមដែរ គឺបានបណ្តុះទឹកចិត្តពុទ្ធសាសនិកគ្រប់រូបឱ្យប្រព្រឹត្តល្អទាំងកាយ និងវាចាចិត្ត[22]។

**គ. អប់រំឱ្យស្រឡាញ់សន្តិភាព**

ក្នុងទ្រឹស្តីពុទ្ធសាសនាក្តី អក្សរសិល្ប៍ពុទ្ធនិយមក្តី អ្នកនិពន្ធនៅសម័យនោះ បានប្រើវិធីដោះស្រាយទំនាស់ដោយអហិង្សាដើម្បីឱ្យពុទ្ធបរិស័ទ និងអ្នកសិក្សារៀនសូត្រអនុវត្តតាម។ ជាពិសេស អប់រំមនុស្សឱ្យជៀសវាងនូវការប្រព្រឹត្តអំពើមិនល្អសព្វបែបយ៉ាង ដែលជាមាគ៌ាដឹកនាំមនុស្សឆ្ពោះទៅរកសុភមង្គល។ រាល់ដំណោះស្រាយបញ្ហាក្នុងអក្សរសិល្ប៍ពុទ្ធនិយម សុទ្ធតែដោះស្រាយដោយអហិង្សាឬដោយសន្តិភាព និងវៀរចាកអំពើបាបឈ្លានពានគ្រប់បែបយ៉ាង។ឥទ្ធិពលនេះបានអប់រំឲ្យជនជាតិខ្មែរមានចិត្តស្រឡាញ់សន្តិភាពគ្មានគំនិតឈ្លានពានអ្នកដទៃ[23]។

**ឃ. អប់រំមនុស្សឲ្យចេះសន្តោសប្រណី និងធ្វើទាន**

តាមរយៈរឿងពុទ្ធនិយមសុទ្ធសាធ (ទសជាតក) និងពុទ្ធនិយមក្លាយ (បញ្ញាសជាតក) បានបណ្តុះទឹកចិត្តមនុស្សឱ្យមានព្រហ្មវិហារធម៌ចំពោះគ្នា ចេះចែករំលែកសេចក្តីសុខ មតិយោបល់ និងទ្រព្យសម្បត្តិដល់ជនក្រីក្រ ដើម្បីគ្នាមានលទ្ធភាពរស់នៅបានសុខស្រួលដូចគ្នានៅក្នុងសង្គមដែរ។ តាមរយៈរឿងព្រះតេមិយ រឿងសុវណ្ណសាម រឿងព្រះវេស្សន្តរ...អ្នកនិពន្ធបានឆ្លុះបញ្ចាំងពីបញ្ហាទាំងនោះ ដូចជាការធ្វើទាន មេត្តាករុណា ក៏យើងសង្កេតឃើញប្រជាពលរដ្ឋខ្មែរនៅតាមភូមិស្រុកចេះជួយសង្គ្រោះគ្នាទៅវិញទៅមក នៅពេលនរណាម្នាក់ ឬក្រុមគ្រួសារណាមួយជួបប្រទះនូវការងារដ៏លំបាកលំបិនណាមួយដូចជាការសង់ផ្ទះ រំលាយសព[24]។

**ង. អប់រំគំនិតមិនឱ្យមានគំនិតលោភលន់**

តណ្ហា ដែលជារងើកភ្លើងទ្រទ្រង់នូវចំណង់ឲ្យចង់មាន ចង់បានហួសហេតុ និងជាប្រភពនាំឱ្យវិនាសដល់ទ្រព្យសម្បត្តិសុភមង្គលនិងអាយុជីវិតផ្ទាល់ខ្លួន ឬក្រុមគ្រួសារទៀតផង។ តាមរយៈរឿងព្រះតេមិយ រឿងព្រះវេស្សន្តរ តួអង្គព្រះពោធិសត្វ សុទ្ធតែបានពិចារណាយ៉ាងល្អិតល្អន់ គឺមិនលោភលន់នឹងអំណាចទ្រព្យសម្បត្តិបន្តិចសោះឡើយ។ គំរូល្អប្រពៃនេះ ក៏បានអប់រំ និងជួយបន្ធូរបន្ថយដល់ទឹកចិត្តលោភលន់របស់មនុស្សសាមញ្ញទាំងឡាយ កុំឱ្យភ្លើតភ្លើនទៅតាមតណ្ហា[25]។

---

[22] បណ្ឌិត ធ សោ អក្សរសិល្ប៍ពុទ្ធនិយម ទំព័រ ៥១ (១៩៩៤)

[23] បណ្ឌិត ធ សោ អក្សរសិល្ប៍ពុទ្ធនិយម ទំព័រ ៥២ (១៩៩៤)

[24] បណ្ឌិត ធ សោ អក្សរសិល្ប៍ពុទ្ធនិយម ទំព័រ ៥៣ (១៩៩៤)

[25] បណ្ឌិត ធ សោ អក្សរសិល្ប៍ពុទ្ធនិយម ទំព័រ ៥៣ (១៩៩៤)

### ច. អប់រំឱ្យអត់ធ្មត់ និងព្យាយាម

អ្នកកាន់ពុទ្ធសាសនា ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវអក្សរសិល្ប៍បានទទួលនូវចំណេះដឹងផ្លូវចិត្តឱ្យចេះអត់ធ្មត់ តស៊ូព្យាយាមគ្រប់ការងារលំបាកលំបិនទាំងអស់ ដើម្បីដណ្ដើមយកជ័យជម្នះលើខ្លួនឯង ក៏ដូចជាអ្នកដទៃ។ ក្នុងរឿងមហាជនក ព្រះបាទជនកបានតស៊ូព្យាយាមហែលទឹកសមុទ្រដ៏ធំធេងល្វឹងល្វើយរហូតដល់ទេពធីតារក្សាមហាសាគរនាងមណីមេខលាជួយស្រោចស្រង់រួចពីសេចក្ដីស្លាប់។ នៅទីបំផុតព្រះបាទជនកបានឡើងគ្រងរាជ្យសម្បត្តិ នគរមិថិលា ដោយសារតែការតស៊ូព្យាយាមរបស់ព្រះអង្គ។រឿងព្រះវេស្សន្តរ ព្រះពោធិសត្វ បានធ្វើបុណ្យដាក់ទានដល់ជនក្រីក្រនូវទ្រព្យសម្បត្តិសព្វបែបយ៉ាង អាយុជីវិតកូនប្រពន្ធប្រយោជន៍បានត្រាស់ដឹងជាព្រះពុទ្ធ។ ការដាក់ទាន ដំរីបច្ច័យនាគេន្រ្ទ ដល់នគរកលិង្គរាស្ត្រ ដែលគ្មានទឹកភ្លៀង ត្រូវអ្នកស្រុកស្រីពិរាស្រ្តក្តៅក្រហាយបណ្តេញព្រះអង្គចេញពីនគរ ពីព្រោះតែពួកគេមិនទាន់មានទឹកចិត្តទូលំទូលាយ និងប្រកាន់ជាតិសាសន៍ខ្លាំងពេក។ ទោះបីជាត្រូវប្រជារាស្រ្តបណ្តេញចេញពីនគរយ៉ាងនេះក្តី នៅតាមផ្លូវព្រះអង្គនៅតែព្យាយាមដាក់ទានទ្រព្យសម្បត្តិ ឱ្យជនក្រីក្រនៅក្នុងព្រៃ ព្រះអង្គដាក់ទានកូន និងប្រពន្ធដល់តាជូកជក និងឥន្ទ្រព្រាហ្មណ៍ដើម្បីបានត្រាស់ដឹង។ តាមរយៈសកម្មភាពរបស់តួអង្គព្រះពោធិសត្វ ក្នុងការតស៊ូព្យាយាមដើម្បីធ្វើអំពើល្អនេះ បានជះឥទ្ធិពលដល់សតិអារម្មណ៍ពុទ្ធសាសនិកយ៉ាងខ្លាំង ឱ្យអនុវត្តតាមជាច្រើនសម័យកាលមកហើយ។

### ឆ. អប់រំឱ្យចេះត្រិះរិះពិចារណា

អក្សរសិល្ប៍ពុទ្ធនិយម អ្នកនិពន្ធក៏បានប្រើប្រាស់ពាក្យពេចន៍សម្រាប់អប់រំជាច្រើននៅក្នុងដំណើររឿងឱ្យពុទ្ធបរិស័ទអ្នកគោរពប្រណិប័តន៍ទាំងអស់ ធ្វើការពិចារណាឲ្យបានល្អិតល្អន់។ ជៀសវាងការជឿងប់ងល់ខ្លាំង ធ្វើឱ្យធ្លាក់ខ្លួនក្រដោយសារមានបាបកម្ម សូម្បីតែចិញ្ចឹមមាន់ទា ក៏មិនឲ្យប្រកបដែរ។ ការដែលមនុស្សចេះគិតពិចារណាយកបញ្ញាជាអាវុធ និងធ្វើឱ្យពួកគេរស់នៅបានយ៉ាងសុខស្រួល គ្មានការបៀតបៀនពីអ្នកដទៃហើយមានជីវភាពធូរធារទៀតផង។ ក្នុងរឿងមហោសថជាតកព្រះអង្គបានកសាងបារមីបញ្ញាពេញមួយជីវិត ហើយព្រះអង្គអាចដោះស្រាយប្រាថ្នារបស់អាចារ្យទាំងបួននាក់ ធ្វើឱ្យព្រះអង្គរួចផុតពីបំណាងអាក្រក់ និងមានបារមីលើសគេឯង រហូតដល់សព្វថ្ងៃអ្នកណាក៏ប្រាថ្នាចង់បានប្រាជ្ញាឈ្លាសវៃដូចព្រះមហោសថដែរ។

## ៥.៣. សន្និដ្ឋាន

ដូចនេះ អក្សរសិល្ប៍ពុទ្ធនិយមអប់រំមនុស្សឲ្យយល់ដឹងអំពីទស្សនៈកម្មផលមកដោះស្រាយសេចក្ដីសុខទុក្ខយកធម៌ខន្តីមកទប់ទល់ និងការវេទនាលំបាកយកលទ្ធិសន្តិភាពនិយមមកដោះស្រាយទំនាស់តាមពុទ្ធសាសនា។ អក្សរសិល្ប៍ពុទ្ធនិយមមានគោលគំនិតសំខាន់សម្រាប់អប់រំប្រជាពលរដ្ឋ ដែលជាពុទ្ធសាសនិកជនទាំងអស់គ្នាឱ្យធ្វើល្អគ្រប់បែបយ៉ាង ទាំងកាយវាចាចិត្ត វៀរចាកអំពើអាក្រក់ទាំងឡាយ។ អក្សរសិល្ប៍ពុទ្ធនិយមជាផ្នែកមួយនៃអក្សរសិល្ប៍ជាតិ ដែលជាមធ្យោបាយមួយដ៏សំខាន់ក្នុងការអប់រំប្រជាពលរដ្ឋខ្មែរយើងឱ្យប្រព្រឹត្តអំពើល្អគ្រប់បែបយ៉ាង មានសណ្ដាប់ធ្នាប់សមសួន និង មានប្រពៃណីល្អប្រសើរសក្តិសមជាពលរដ្ឋដែលគោរពព្រះពុទ្ធសាសនា និង មានអរិយធម៌ខ្ពស់។ អក្សរសិល្ប៍ពុទ្ធនិយមត្រូវតែមានតួនាទីសមស្របនៅក្នុងកម្មវិធីសិក្សាក្នុងសាលារៀននាពេលបច្ចុប្បន្ន ។

## ៦. ឥទ្ធិពលពុទ្ធសាសនាក្នុងសង្គម

### ៦.១. ប្រភពនៃអក្សរសិល្ប៍ពុទ្ធនិយម

អរិយធម៌ខ្មែរ មានប្រភពចេញពីលទ្ធិព្រាហ្មណ៍និយមផង ជាពិសេសគឺអរិយធម៌ជំនាន់អង្គរ និងលទ្ធិពុទ្ធនិយមផង ដែលជាអរិយធម៌ខ្មែរជំនាន់ក្រោយអង្គរ។ ចលនាអក្សរសិល្ប៍បែបពុទ្ធនិយមមានរូបសេចក្តី និងសណ្ឋានដែលដកស្រង់ពីប្រភពនៃគម្ពីរព្រះត្រៃបិដក។ ពោល គឺការយកគោលគំនិត និងទស្សនវិជ្ជាព្រះពុទ្ធសាសនា មកឆ្លុះបញ្ចាំងក្នុងស្នាដៃអក្សរសិល្ប៍៖១. វិន័យបិដក(ព្រះវិន័យ) ២.សុត្តន្តបិដក (ព្រះសូត្រ)៣.អភិធម្មបិដក(ព្រះអភិធម្ម)។[26]

ព្រះត្រៃបិដក ជាឃ្លាំងផ្ទុកនូវពុទ្ធវចនៈ ដែលមាន៨៤ ០០០ធម្មក្ខន្ធ ចែកចេញជាគម្ពីរ៣[27]សំខាន់គឺ៖

- វិន័យបិដក មាន៥ គម្ពីរ ចែកជា ១៣ភាគ មាន២១ ០០០ធម្មក្ខន្ធ
- សុតន្តបិដកមាន៥គម្ពីរ ចែកជា៦៤ភាគ មាន២១ ០០០ធម្មក្ខន្ធ និង
- អភិធម្មបិដកមាន៧គម្ពីរ ចែកជា៣៣ភាគ មាន៤២ ០០០ធម្មក្ខន្ធ ។

### ៦.២. ឥទ្ធិពលនៃលទ្ធិព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរ

### ក. វិស័យនយោបាយ គ្រប់គ្រង និងដឹកនាំប្រទេស

ក្នុងសម័យអាណានិគមនិយមបារាំង ព្រះពុទ្ធសាសនាមានតួនាទីយ៉ាងសំខាន់ក្នុងនយោបាយរក្សាពូជសាសន៍ឱ្យមានលក្ខណៈ និង អត្តសញ្ញាណជាតិដោយប្រកាន់ខ្ជាប់នូវទំនៀមទំលាប់ប្រពៃណី និង វប្បធម៌របស់ជាតិ។ ឥទ្ធិពលលើវិស័យនយោបាយ ការគ្រប់គ្រង និងដឹកនាំប្រទេសរបស់ព្រះពុទ្ធសាសនា នាសម័យនោះជាឧបសគ្គដល់នយោបាយរំលាយវប្បធម៌ខ្មែរយើងរបស់ពួកបារាំង ។

ដល់សម័យសង្គមរាស្ត្រនិយម សម្តេចនរោត្តម សីហនុគ្រប់គ្រងប្រទេសជាតិដោយផ្សារភ្ជាប់ទាំងស្រុងទៅនឹងព្រះពុទ្ធសាសនា ។ ព្រះអង្គតែងតែសុំយោបល់ពីសម្តេចព្រះសង្ឃរាជទាំងពីរគណៈ។ ដោយសារនយោបាយដ៏ប្រសើរនេះ ព្រះពុទ្ធសាសនាបានចូលរួមយ៉ាងសកម្មក្នុងការកសាងជាតិនាសម័យនោះ ធ្វើឱ្យមានការរីកចំរើន និងទទួលបានឈ្មោះថា ជាកោះសន្តិភាព ។

### ខ. វិស័យវប្បធម៌

- **អប់រំចិត្តគំនិត** ៖ ព្រះពុទ្ធសាសនាអប់រំមនុស្សខ្មែរឱ្យមានចិត្តស្លូតបូត សុភាពរាបសារ ប្រកាន់អកប្បកិរិយា ស្រឡាញ់សន្តិភាព អប់រំមនុស្សឱ្យមានមេត្តា ករុណា ចេះធ្វើទាន ជៀសវាងហិង្សា ។
- **ភាសា** : ព្រះពុទ្ធសាសនាបាននាំភាសាសំស្ក្រឹត និង បាលីបញ្ចូលក្នុងភាសាជាតិខ្មែរយើង ។ នៅសម័យអង្គរ ភាសាសំស្ក្រឹត និង បាលីត្រូវបានគេចាត់ទុកជាភាសាផ្លូវការ និង ថ្លៃថ្នូរ ។
- **អក្សរ** : អក្សរដែលខ្មែរយើងប្រើសព្វថ្ងៃនេះមានប្រភពមកពីអក្សរសំស្ក្រឹត ដែលយកតាមលំនាំអក្សរព្រាហ្មី ។
- **អក្សរសាស្ត្រ អក្សរសិល្ប៍** : រហូតមកដល់ពេលនេះអក្សរសិល្ប៍ខ្មែរយើងចែកចេញជា៣ចលនា ដែលមានចលនាអក្សរសិល្ប៍ពុទ្ធនិយមផងដែរ ។
- **ផ្នែកអប់រំផ្តល់ចំណេះដឹង** : នៅសម័យមុន១ វត្តអារាមជាសាលាពហុបច្ចេកទេស ។ ឪពុកម្តាយត្រូវនាំកូនទៅផ្ញើព្រះសង្ឃ ។ កាលបើរៀនសូត្រចេះអក្សរ និង លេខនព្វន្តខ្លះហើយ កុមារត្រូវរៀនធម៌ បួសជាសាមណេរ

---

[26] បណ្ឌិត ហង់ជួន ណារ៉ុន, វិភាគទាននៃការសិក្សាអក្សរសិល្ប៍ខ្មែរ, ទំព័រ៥២, ២០១៩

[27] ទេស ហាវ, ទេព ណន, ធុក ផល្លីនី, តែ ស្រីសោភ័ណ វប្បធម៌អរិយធម៌ខ្មែរ ទំព័រ៧៤, ២០០៩

និង ភិក្ខុទៀត ដើម្បីរៀនសូត្រកាន់តែជ្រៅជ្រះ ។ អ្នកដែលធ្លាប់បានបួសរៀនក្នុងសំណាក់ព្រះពុទ្ធសាសនា គេហៅថា អន្ទិត ដែលក្លាយមកពីពាក្យ បណ្ឌិត មានន័យថា អ្នកមានចំណេះដឹងជ្រៅជ្រះ ។ មានអ្នកនិពន្ធជាច្រើនធ្លាប់បានបួសរៀន ដូចជា សុតន្តប្រីជាឥន្ទ្រ សន្ធរម៉ុក ភិរម្យង៉ុយ សម្តេចព្រះអង្គឌួង ព្រះរាជសម្ភារ ភិក្ខុសោម ឧកញ៉ានូ កន ជាដើម ។

– **ផ្នែកសិល្បៈ** : វត្តអារាមជាមណ្ឌលថែរក្សាការពារ និង ផ្សព្វផ្សាយសិល្បៈ ។ នៅពេលស្រុកមានកោលាហលកើតចំបាំងរាំងដល់ក្នុងស្រុក ឬ មានសង្គ្រាមឈ្លានពានពីបរទេស ជាពិសេសសម័យអានានិគមនិយមបារាំង សិល្បៈគ្រប់ប្រភេទរបស់ខ្មែរត្រូវរត់ទៅជ្រកកោននៅវត្តអារាម ដែលមានព្រះសង្ឃជាអ្នកថែរក្សា និងបង្ហាត់បង្រៀន។ ព្រះសង្ឃច្រើនមានចំណេះដឹងខាងសិល្បៈឆ្លាក់ គំនូរ និង ក្បាច់រចនាសំរាប់លំអតាមព្រះវិហារ កុដិ សាលាឆាន់ ចេតីយ៍ ។ ល ។ ព្រះសង្ឃដឹកនាំកសាងកុដិ សាលា ស្ពាន មន្ទីរពេទ្យ ព្រះវិហារ... ។

– **ផ្នែកជំនឿ** : ព្រះពុទ្ធសាសនាអប់រំមនុស្សឱ្យជឿទៅលើបុណ្យ បាប កម្ម ផល ដែលជំនឿនេះធ្វើឱ្យពុទ្ធសាសនិកមិនរមិលគុណ ចេះគោរពមាតា បិតា គ្រូអាចារ្យ និង អ្នកមានគុណទាំងឡាយ ។

– **ទំនៀមទម្លាប់ប្រពៃណី** : ទំនៀមទំលាប់ប្រពៃណីដែលទទួលឥទ្ធិពលពីពុទ្ធសាសនាមានដូចជា បុណ្យពិសាខបូជា មាឃបូជា ភ្ជុំបិណ្ឌ ចូលឆ្នាំ ចូលវស្សា ចេញវស្សា កឋិន បុណ្យផ្កា ... ។

– **ផ្នែកកសិកម្ម** : កាលពីជំនាន់ដើម វត្តអារាមនីមួយៗ តែងតែមានស្រែ ដែលគេហៅថា ស្រែវត្ត ឬ ស្រែព្រះ ។ ព្រះសង្ឃចូលរួមក្នុងការកសាងទំនប់ ប្រឡាយទឹក លើកផ្លូវ ។ ល ។

– **ផ្នែកសង្គមកិច្ច** : វត្តអារាមផ្តល់ដល់យុវជន និង ប្រជាពលរដ្ឋនូវវិជ្ជាជីវៈផ្សេងៗដូចជា ជាងឈើ ជាងចម្លាក់ ជាងគំនូរ ជាងកំបោរ...។ វត្តអារាមជាកន្លែងចិញ្ចឹមអ្នកគ្មានទីពឹង ជាអន្តេវាសិកសម្រាប់សិស្ស និស្សិតដែលមានស្រុកឆ្ងាយៗ ដើម្បីស្នាក់នៅរៀនសូត្រ ។ មុនពេលវិទ្យាសាស្ត្រផ្នែកពេទ្យមានការរីកចំរើន វត្តអារាមគឺជាមន្ទីរពេទ្យ ព្រះសង្ឃជាគ្រូពេទ្យ ដែលខ្មែរយើងច្រើននិយមហៅថា គ្រូខ្មែរ ជាពិសេសគឺការព្យាបាលតាមចិត្តសាស្ត្រប្រើមន្តអាគម គាថា និង ធម្មទេសនាសំរាប់អ្នកជំងឺផ្លូវចិត្ត ។

## ៧. តួនាទីអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរ

### ៧.១. តួនាទីអប់រំដើម្បីស្វែងរកសច្ចភាពនៃជីវិត

***ពុទ្ធសាសនា គឺជាសាសនាផង និងជាទស្សនវិជ្ជាផង***។ ព្រះពុទ្ធបានបញ្ញត្តិក្រមចរិយាធម៌មួយយ៉ាងល្អសម្រាប់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា និងពុទ្ធសាសនិកជនជាគ្រហស្ថឱ្យវៀរចាកនូវការធ្វើអំពើអាក្រក់ទាំងពួង (សព្វបាបស្សអករណំ) ងាកមកប្រព្រឹត្តសេចក្តីល្អ(កុសលស្សូបបសម្បទា) និងតាមដានពិនិត្យផ្លូវចិត្តខ្លួនឯងឱ្យច្បាស់លាស់ដើម្បីសម្អាតផ្លូវចិត្ត(សចិន្តបរិយោទបនំ)ដោយត្រូវបដិបត្តតាមមាគ៌ាអដ្ឋង្គិកមគ្គ។

**ពុទ្ធសាសនា គឺជាសាសនាមនុស្សនិយម** ។ រូបមន្តដំបូងបំផុតរបស់ព្រះពុទ្ធសាសនា ត្រូវបានគេរកឃើញនៅក្នុងអ្វីដែលគេស្គាល់ថាជា "**ចតុរារិយសច្ចៈ**" ដែលត្រូវតែជាការយកចិត្តទុកដាក់របស់មនុស្ស ប្រកបដោយប្រាជ្ញាគ្រប់រូប និងជាសេចក្តីប្រកាសត្រឹមត្រូវ ស្តីពីធម្មជាតិនៃលោកនិងធម្មជាតិនៃមនុស្ស។

**ក. ចតុរារិយសច្ចៈ** (អរិយសច្ចៈបួន)[28]គឺ :

**ក.១. ទុក្ខអរិយសច្ចៈ** ទាក់ទងនិងធម្មជាតិពិតនៃជីវិត សេចក្តីសោកសៅ និងសេចក្តីសប្បាយតែខាងក្រៅនៃជីវិតការខកចិត្ត និងទោមនស្សនៃជីវិតអនិច្ចតានិងអនត្តានៃជីវិត។ បុគ្គលគប្បីយល់ប្រការនេះជាការណ៍ពិតដោច្បាស់លាស់និងដោយពេញលេញ ។ ទុក្ខអរិយសច្ចៈទុក្ខដែលជាសភាពពិត មាន ជាតិទុក្ខ គឺទុក្ខព្រោះកំណើត ។ ជរាទុក្ខ គឺជាទុក្ខព្រោះចាស់ ។ ព្យាធិទុក្ខ គឺទុក្ខព្រោះឈឺ ។ មរណទុក្ខ គឺទុក្ខព្រោះស្លាប់ ។

**ក.២. សមុទយអរិយសច្ចៈ** (ហេតុនៃទុក្ខ) សម្តែងថាទុក្ខបណ្តាលមកពីប្រភេទនៃរាគៈ ឬតម្រេកដែលជិតដាមដោយកាមតណ្ហា កិលេស និងសេចក្តីសៅហ្មងដទៃទៀត។ បុគ្គលមិនគ្រាន់តែយល់ដឹងនូវការពិតនេះដោយច្បាស់ លាស់ប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានសេចក្តីព្យាយាមរំលើងឫសគល់រាគៈទាំងនោះថែមទៀត។ សមុទយអរិយសច្ចៈហេតុដែលនាំឱ្យកើតទុក្ខ ព្រោះវិជ្ជានិងតណ្ហា។ អវិជ្ជា គឺមកពីមិនដឹងមិនយល់ហេតុនៃទុក្ខ។ តណ្ហា គឺចំណង់ចង់បាននូវអ្វីៗគ្រប់យ៉ាងមានកាមតណ្ហា ចំណងជាដើម ។

**ក.៣. និរោធទុក្ខអរិយសច្ចៈ** សភាពពិតក្នុងការរំលត់ទុក្ខ ដោយបំបាត់អវិជ្ជាជាប្រភពដើមនៃទុក្ខ។ ជាលទ្ធភាពជំនះទុក្ខបានដែលសម្រេចដល់ធម៌ដ៏ខ្ពស់បំផុតនៃពុទ្ធសាសនាគឺនិព្វាន(ការរំលត់ទុក្ខ)។

**ក.៤. មគ្គអរិយសច្ចៈ** មាគ៌ានាំទៅកាន់ការរំលត់ទុក្ខពិតប្រាកដ ការយល់ដឹងនូវមគ្គតែប៉ុណ្ណោះមិនគ្រប់គ្រាន់ទេ គេត្រូវខិតខំដើរតាមមាគ៌ានេះ និងប្រតិបត្តិតាមដោយទៀតទាត់ទៀត។ មគ្គអរិយសច្ចៈ វិធីរំលត់ទុក្ខប្រកបដោយមគ្គ (ត្រូវ) មាន ៨ យ៉ាងគឺ (ហៅថា អដ្ឋង្គិកមគ្គ)

- សម្មាទិដ្ឋិ : យល់ឃើញត្រូវ
- សម្មាសង្កប្ប : ត្រិះរិះត្រូវ
- សម្មាវាចា : សម្តីត្រូវ
- សម្មាកម្មន្ត : ការងារត្រូវ
- សម្មាអាជីវៈ : ការចិញ្ចឹមជីវិតត្រូវ
- សម្មាវាយាម : ព្យាយាមត្រូវ
- សម្មាសតិ : រឭកត្រូវ
- សម្មាសមាធិ : តាំងចិត្តត្រូវ

**ខ. លក្ខណៈនៃភាវៈ (ត្រៃលក្ខណ៍)**

លក្ខណៈសកលបីយ៉ាងនៃជីវិតគឺៈ

- អនិច្ចំ : ភាវៈទាំងអស់សុទ្ធតែមិនទៀងទាត់ ក្នុងការកើតស្លាប់ចម្រើនវិនាស មិនទៀងទាត់ ។
- ទុក្ខំ : ភាវៈទាំងអស់ឱ្យតែមាននាមនិងរូប សុទ្ធតែមានទុក្ខដូចគ្នា។
- អនត្តា : ភាវៈទាំងអស់សុទ្ធតែមិនមែនជារបស់ខ្លួន ។

សរុបមក ភាវៈទាំងពួងក្នុងធម្មជាតិត្រូវតែមានការប្រែប្រួលដោយភ្ជាប់ហេតុនិងផល ។

[28] អ្នកស្រី ត្រឹង-ងា, សៀវភៅអរិយធម៌ខ្មែរ ទំព័រ ២៥-៣៣

### គ. បញ្ហាកម្មផល

- **កម្មផល** : ទ្រឹស្តីកម្មផល ដែលបង្ហាញពីចំណងនៃអំពើនិងផលដែលបុគ្គលបានសាងឡើង។ មនុស្សមានការចេះដឹង ល្ងង់ខ្លៅ ល្អ អាក្រក់ ស្រេចទៅលើខ្លួនឯង អំពើរបស់ខ្លួននិងមានវិជ្ជាចេះដឹងបានសម្រេចមគ្គផលក៏ដោយសារខ្លួនឯងបានសិក្សាសន្សំប្រឹងស្មឹងស្មាធិ៍ បើល្ងង់ខ្លៅអប្បប្រាជ្ញាក៏ដោយសារកម្មនិងផល ២យ៉ាង :
  - **កល្យាណកម្ម** : អំពើល្អឱ្យផលល្អ (ធ្វើបុណ្យបានបុណ្យ)
  - **បាបកម្ម** : អំពើអាក្រក់ឱ្យផលអាក្រក់ (ធ្វើបាបបានបាប) ។

  ពុទ្ធភាសិត "***អ្នកណាសាបព្រួសពូជបែបណា អ្នកនោះនឹងបានផលបែបនោះ***" ។
- **កម្មពៀរ** : ផលអាក្រក់ដែលបុគ្គលបានទទួលដោយសារអំពើអាក្រក់ ដែលបុគ្គលនោះបានប្រព្រឹត្តពីអតីតជាតិ ជាការប៉ះពៀរគ្នា។

### ឃ. បដិច្ចសមុប្បាទធម៌ ១២ ប្រការ គឺៈ

- អវិជ្ជា ជាបច្ច័យឱ្យកើតសង្ខារ
- សង្ខារ ជាបច្ច័យឱ្យកើតវិញ្ញាណ
- វិញ្ញាណ ជាបច្ច័យឱ្យកើតនាមរូប
- នាមរូប ជាបច្ច័យឱ្យកើតសឡាយតនៈ
- សឡាយតនៈ ជាបច្ច័យឱ្យកើតផស្សៈ
- ផស្សៈ ជាបច្ច័យឱ្យកើតវេទនា
- វេទនា ជាបច្ច័យឱ្យកើតតណ្ហា
- តណ្ហា ជាបច្ច័យឱ្យកើតឧបាទាន
- ឧបាទាន ជាបច្ច័យឱ្យកើតភព
- ភព ជាបច្ច័យឱ្យកើតជាតិ
- ជាតិ ជាបច្ច័យឱ្យកើតជរា
- ជរា ជាបច្ច័យឱ្យកើតមរណៈ ។

### ង. បញ្ហាសុខ

ដើម្បីបានសេចក្តីសុខ គឺលះបង់តណ្ហា ក៏ចាត់អវិជ្ជា មិនប្រមាថធ្វេសប្រហែស តម្កល់ចិត្តក្នុងសីល សមាធិ បញ្ញា និងលះបង់អត្តៈ (កុំប្រកាន់ថាខ្លួន ជារបស់ខ្លួន)

សម្បត្តិ ៣ប្រការ

- សម្បត្តិមនុស្ស ឬមនុស្សសម្បត្តិ គឺសម្បត្តិដែលប្រសើរជាងសត្វតិរច្ឆាន ។
- សម្បត្តិសួគ៌ ឬសួគ៌សម្បត្តិ គឺសម្បត្តិដែលកើតឡើងដោយចំណងនិស្ស័យនៃបុញ្ញកម្ម ។
- សម្បត្តិនិព្វាន ឬនិព្វានសម្បត្តិ គឺសម្បត្តិខ្ពស់បំផុតឥតមានភ័យណាមួយក្នុងលោកចូលមកបៀតបៀនបានឡើយ ។

ជារួម ទ្រឹស្ដីជាមេរៀននៃអង្គព្រះសម្មាសម្ពុទ្ធនៃយើង គឺជាប្រភពនៃអក្សរសិល្ប៍ពុទ្ធនិយមនេះឯង។ ដូច្នេះហើយតួនាទីនៃអក្សរសិល្ប៍ពុទ្ធនិយមត្រូវតែផ្សារភ្ជាប់ឥតដាច់ជាមួយនឹងមេរៀនត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ។ តួនាទីអក្សរសិល្ប៍ពុទ្ធនិយមដើម្បីស្វែងរកសច្ចភាពនៃជីវិតគឺឆ្លុះបញ្ចាំងតាមរយៈរឿងពុទ្ធនិយមសុទ្ធទាំង១០រឿង។

## ៧.២. តួនាទីកម្សាន្តបន្ធូរអារម្មណ៍ផ្សារភ្ជាប់ការអប់រំ

តួនាទីអក្សរសិល្ប៍បានរួមចំណែកជួយបន្ធូរបន្ថយភាពតានតឹងរបស់ប្រជាជន ហើយស្នាដៃអក្សរសិល្ប៍ទាំងនោះច្រើនជាអត្ថបទសាស្ត្រាល្បែងនានា ដែលច្រើនមានតែមានប្រភពមកពីគម្ពីរបញ្ញាសជាតក។ លក្ខណៈនេះអាចបង្ហាញថាសាស្ត្រាល្បែងទាំងនោះគឺបញ្ជាក់យ៉ាងច្បាស់ពីទំនោររបស់អ្នកនិពន្ធ គឺបានជ្រើសយកគោលសាសនាជាសំខាន់ក្នុងការតាក់តែងសាច់រឿងរបស់ខ្លួន។ ជាពិសេសសាស្ត្រាល្បែងទាំងនោះគឺចង់បង្ហាញពីឥទ្ធិពល នៃសាសនាទៅលើសន្ដានចិត្តសតិអារម្មណ៍របស់ប្រជាជន។ មួយវិញទៀតសិល្ប៍និពន្ធនៃសាស្ត្រាល្បែងទាំងនោះក៏អាចបកស្រាយពីជីវភាពស្មារតីរបស់ប្រជាជនផងដែរ។ មានន័យថាចាប់តាំងពីប្រទេសចុះខ្សោយមកជីវភាពប្រជាជនក៏លែងមានលំនឹង។ ដោយសារសង្គ្រាម ការព្រាត់ប្រាស និងមានគ្រោះទុរភិក្សក្នុងរយៈពេលដ៏វែងបានធ្វើ ឱ្យប្រជាជនឆ្អែតឆ្អន់នឹងការលំបាកវេទនានិងទុក្ខសោកទាំងនោះ។ ក្ដីប្រាថ្នាដែលពួកគេចង់រស់នៅ ក្នុងសង្គមមួយដ៏សុខដុមរមនាមិនអាចសម្រេចបានក្នុងសច្ចភាព។ ហេតុដូចនេះគេបានយកក្ដីប្រាថ្នា ទៅធ្វើក្នុងតថភាពគឺបកស្រាយតាមរយៈអក្សរសិល្ប៍ទៅវិញ ដើម្បីបំពេអារម្មណ៍ សម្រាលទុក្ខ បន្ធូរភាព គ្រោតគ្រាត និងជួរចត់ក្នុងជីវិតជាក់ស្ដែង។ ដោយហេតុនេះហើយបានជាសាស្ត្រាល្បែងក្នុងសម័យក្រោយអង្គររៀងមកដល់សម័យអាណានិគមមិនព្រមលើកឡើងពីជីវភាពសង្គមពីជីវិតពិតរបស់ប្រជាជនសោះ តែបែរជាបង្ហាញពីជីវិតដ៏រុងរឿង និងសម្បូរសប្បាយរបស់ត្រកូលស្ដេចទៅវិញ។ បើពុំដូច្នោះទេ កាលណាគេបង្ហាញពីការលំបាកវេទនាដ៏ហួសនិស្ស័យរួចហើយ ទីបំផុតអ្នកដែលទទួលទុក្ខទោស ដោយសារអយុត្តិធម៌ទាំងប៉ុន្មាន តែងបានវិលមកសោយសុខសុភមង្គលបរិបូរវិញជានិច្ច។ ជាតួយ៉ាងនៅក្នុងរឿងក្រុងសុភមិត្រ គឺពោរពេញដោយជីវិតខ្វាត់ព្រាត់រសាត់អណ្ដែត ព្រាត់មហេសី ព្រាត់បុត្រ បន្ទាប់ពីបាត់បង់នគរ និងរាជបល្ល័ង្ក ប៉ុន្តែនៅទីបញ្ចប់ក៏បានមកជួបជុំគ្នាវិញ ហើយបានទាំងនគរមួយ ផ្សេងទៀតមកគ្រប់គ្រងថែមទៀត។ ចំណែកឯក្នុងរឿងមរណមាតា គឺថានាងមរណមាតាបានស្លាប់ ហើយរស់ឡើងវិញស្ទើរតែដប់ដងទៅហើយ ដើម្បីបានមកវិលមកធ្វើជាអគ្គមហេសីរបស់ស្ដេចវិញ មុននឹងរឿងត្រូវបានបញ្ចប់។

## ៧.៣. តួនាទីអប់រំស្វែងរកសច្ចភាពនៃជីវិតតាមរយៈស្នាដៃអក្សរសិល្ប៍ទសជាតក

### ៧.៣.១. រឿងព្រះតេមិយជាតក

#### ក. ប្រធានរឿង

រឿងតេមិយ បង្ហាញពីព្រះពោធិសត្វ បំពេញនេក្ខកម្មបារមី គឺការសាងផ្នួស។

#### ខ. មូលបញ្ហារឿង

#### ទី១៖ បញ្ហាធ្វើទណ្ឌកម្មចោរ

សាច់រឿងបានលើកយករឿងចោរ៤នាក់មកធ្វើ ជាប្រធាននៃរឿងនឿយណាយមិន ចង់គ្រងរាជ្យជាស្ដេចផែនដី ហើយប្រាថ្នាលះបង់សម្បត្តិជាក្សត្ររបស់តេមិយដើម្បីយាងចូលព្រៃបួសជាឥសី។ រឿងចោរនេះមាន៤នាក់៖ ចោរម្នាក់ត្រូវវាយដោយរំពាត់១ពាន់ខ្វាប់, ចោរម្នាក់ចងដោយច្រវាក់ដាក់ក្នុងពន្ធនាគារ, ចោរម្នាក់ត្រូវចាក់សម្លាប់ដោយលំពែង,ចោរម្នាក់ទៀតត្រូវដោតឆ្កាងអណ្ដាតគឺដែកស្រួច។

ពោធិសត្វឃើញព្រឹត្តិការណ៍បែបនេះ ក៏ស្លុតស្មារតីគិតភ័យពន់ប្រមាណ ហើយទ្រង់ពិចារណាថា៖« **អាត្មាអញមកពីណា មកនៅក្រោមស្វេតច្ឆត្រនេះ** មកពីឋានតាវត្តិង្សមកនៅទីនេះ មកពីនរកទៅកាន់ឋានតាវត្តិង្ស ទៅពីកន្លែងនេះទៅនរក ព្រោះធ្លាប់ជាស្តេចសោយរាជ្យនៅនគរនេះអស់២០ឆ្នាំដោយទោសនៃការសោយរាជ្យបានជានៅវេទទុក្ខឧស្សុទនរក៨ម៉ឺនឆ្នាំ»។[29]

ដូចនេះបញ្ហាធ្វើទណ្ឌកម្មចោរដោយខ្លាចក័ន្តប្រឡំត្រូវជាខុសល្អជាអាក្រក់,ទោស...ទាំងអស់នេះហើយដែលធ្វើឲ្យពោធិសត្វតក់ស្លត់ភ័យខ្លាចចំពោះខ្លួនឯងខ្លាចនូវអំណោយទ្រព្យសម្បត្តិហើយនឿយណាយទៅជាមធ្យោបាយធ្វើគ ថ្លង់ ខ្វិនខ្វង់ ដើម្បីរំដោះខ្លួនចេញពីរាជសម្បត្តិ ដែលទ្រង់យល់ថា ជា**ចំណង** ជា**ទោស** ជាគ្រឿងសៅហ្មង ជាមន្ទិលអាចទាញព្រះអង្គធ្លាក់ចុះឋាននរកវេទនាខ្ទុះឈាមនោះ ។

**ទី២៖សកម្មភាព និងលក្ខណៈរបស់តេមិយ**

កាលបើពិចារណាឃើញបុព្វហេតុនៃទោសកំហុសយ៉ាងនេះ ទើបតេមិយទទួលស្តាប់នូវសម្លេង នៃ នាងទេពធីតាដែលជាសម្លេងវិចារណញ្ញាណ សម្លេងសុភនិច្ឆ័យ សំឡេងនៃមនសិការដោយធ្វើ ឧបាយជាគ ជាថ្លង់ ជាខ្វិនខ្វង់ លែងនិយាយស្តី ទោះបីព្រះបរបិតាខិតខំប្រើមធ្យោបាយបន្លាចបំភ័យ យ៉ាងណាក៏ដោយ ក៏ព្រះរាជកុមារនៅតែខិតខំរក្សា អាកប្បកិរិយា ជំហរស្មារតីរបស់ខ្លួនមិនតបឆ្លើយមិនព្រមនិយាយស្តី ធ្វើទាល់ តែព្រះមហាក្សត្របិតាទាល់តម្រិះខ្វាល់ប្រើរាជអាមាត្យនាំយកទៅជីកដីកប់ទាំងរស់។ សកម្មភាព និងលក្ខណៈរឹងប៉ឹង តាំងស្មារតីស៊ប់គ្មានប្រែប្រួលក្នុងឧត្តមគតិ ក្នុងគោលបំណង ត្រូវរបស់ខ្លួនបែបនេះ ដែលធ្វើឱ្យព្រះតេមិយ ឆ្លងផុតពីទោសច្រឡំ ទោសអគតិ អយុត្តិធម៌ឬ ចាកអំពើបាប គ្រោតគ្រាតបាន ។

**ទី៣ ៖ បញ្ហានេក្ខម្មបាមី**

នេក្ខម្មបារមី ឬការបួសជាមធ្យោបាយរំដោះខ្លួនឱ្យផុតអំពីកងកង្វល់ទុក្ខទោសក្នុងជីវភាពជាក្សត្រជាអ្នកកាន់អំណាច ជាអ្នកធ្វើទោសទណ្ឌគេ ជាមនុស្សស្រលាញ់ទ្រព្យសម្បត្តិ...។ តាមដំណើររឿង កំហុសនៃព្រះបាទកាសិករាជ ជាបិតាមានដល់ទៅ ពីរលើកស្ទួនៗគ្នា គឺ

- លើកទីមួយ ធ្វើទោសចោរបួននាក់នៅ ចំពោះមុខកូនធ្វើកូនភ័យខ្លាចស្អប់ខ្ពើមអំណាចបែប នេះយ៉ាងខ្លាំង
- លើកទីពីរ ធ្វើមធ្យោបាយ ដោយប្រើអំពើទណ្ឌកម្មបន្លាចបំបាក់ស្មារតីដោយពិសោធន៍ហេតុ ដប់ប្រាំមួយប្រការ ។រហូតដល់ប្រើនាយសុនន្ទសារថីឱ្យចាប់ចងយកទៅកប់ទាំងរស់ ។ ទាំងនេះ គឺជាអំពើដែលរាជ កុមារឃើញផ្ទាល់នឹងព្រះនេត្រដែលសឲ្យឃើញកំហុសច្រើនឥតគណនារបស់ស្តេចបិតាដែលខ្លួនត្រូវតែខ្លាចគេចចេញកុំទៅស្នងរាជ្យ ដើម្បីកុំឲ្យដើរតាមកំហុសបែបនេះទៀត។ដូច្នោះមានតែការបួសទេ គឺចាក ភាពជាគ្រហស្ថដើម្បីចូលព្រៃបួស ជាសមណៈឥសីលះបង់ នូវអំណាចទ្រព្យសម្បត្តិជាចំណងច្រើនប្រការ ។

សរុបមក **ការបួស** គឺជាការផ្តាច់ឫសគល់នៃលោភៈ ទោសៈ មោហៈ និងអវិជ្ជាដើម្បីស្វែង រកបរមសុខ មានមោក្សៈ ជាការត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ ជាទីអវសាន។ នៅក្នុងរឿងនេះបានបង្ហាញឱ្យ ឃើញថារឿងទូទៅក្នុងពុទ្ធនិយមសុទ្ធតែបានបង្ហាញថាព្រះពោធិសត្វលះបង់រាជសម្បត្តិដើម្បីយាងទៅបួស។ ដូចនេះរាជសម្បត្តិជាឧបសគ្គជាចំណងយ៉ាងមាំសម្រាប់ភ្ជាប់ពោធិសត្វនេះឯង ។ បើជាមនុស្សសាមញ្ញ គឺ សម្បត្តិទ្រព្យ កេរ្តិ៍អាករនេះឯងដែល

[29] ឈឹម សុមន៍ សង្ខេបទសជាតក ព.ស២៥០២ ទំព័រ៥

ជាចំណង។ ផ្តាច់ពារហិទ្រព្យនេះបានទើបរំដោះចិត្តគំនិតឱ្យផុតពី កាម តណ្ហា រាគៈ កិលេស កម្មអាក្រក់ អកុសលកម្មបាន។

**ទី៤ ៖ លក្ខណៈ និងសកម្មភាពរបស់ព្រះបាទកាសិករាជ និងនាងចន្ទាទេវី**

ព្រះបាទកាសិករាជ ជាក្សត្រស្រលាញ់បុត្រ ប៉ុន្តែមិនខ្លាចប្រើគ្រប់មធ្យោបាយ អាក្រក់ដើម្បី អូសទាញបុត្រឱ្យលុះក្នុងគន្លងគោលបំណងរបស់ព្រះអង្គបានឡើយ។ នេះក៏ ព្រោះអ្វី ? គឺព្រោះអកុសល កម្មរបស់លោកជាផ្លូវជាមធ្យោបាយពុំត្រូវ ពុំល្អនេះឯង។ ឯនាងចន្ទាទេវីជាមាតា គឺចេះថ្នាក់ថ្នមបុត្រ ប៉ុន្តែអូសទាញមក ក្នុងគោលបំណងរបស់ព្រះរាជស្វាមីពុំបានសម្រេច ព្រោះចិត្តគំនិតមធ្យោបាយដើរខុសគ្នា (មួយត្រជាក់ មួយក្តៅចូលគ្នាពុំកើត)។ ប៉ុន្តែទឹកចិត្តប៉ងប្រាថ្នាឲ្យព្រះរាជបុត្រលះបង់ឧត្តមគតិការបួសមកឡើង គ្រងរាជ្យ ជាក្សត្រ សុទ្ធតែខុសពីសច្ចាអធិដ្ឋានរបស់ព្រះតេមិយទាំងអស់។ ដូច្នោះមធ្យោបាយរបស់ក្សត្រទាំងពីរអង្គ ជាព្រះបវរបិតាមាតាត្រូវខកខានបរាជ័យជាអសារបង់។

**គ. តួនាទីអប់រំនៃរឿងតេមិយជាតក**

គ្រប់អក្សរសិល្ប៍ទាំងអស់ សុទ្ធមានតម្លៃអប់រំជានិច្ចមិនថាអក្សរសិល្ប៍បុរាណ ឬអក្សរសិល្ប៍ទំនើបឡើយ។ យ៉ាងណាមិញរឿងតេមិយជាតក ក៏បានលើកយកទស្សនៈនៃការអប់រំ មកពន្យល់ ឱ្យអ្នកអាន អ្នកទស្សនាស្គាល់និងយល់អំពីចលនាពុទ្ធនិយម។ តេមិយជាតក ជារឿងពុទ្ធនិយមដែលនិយាយពីការសាងបារមី ដោយការបួសដើម្បីបានត្រាស់ដឹង និងបានបង្ហាញអំពីតម្លៃអប់រំដែលមានលក្ខណៈល្អជាច្រើន។

ឆ្លងតាមការវិភាគទៅលើ ប្រធានរឿង និងមូលបញ្ហារឿង ធ្វើឱ្យយើងយល់អំពីគំនិតសំខាន់ៗ និងតម្លៃអប់រំជាច្រើនដូចជា ៖

- **អប់រំមនុស្សឱ្យជឿលើកម្មផល**

  អ្នកណាធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ កម្មសឲ្យផលស កម្មខ្មៅឲ្យផលខ្មៅ បានន័យថារាល់ទង្វើទាំងអស់ កាលណាយើងប្រព្រឹត្តិតែអំពើល្អ នោះអំពើល្អនឹងតបស្នងយើងវិញ ប៉ុន្តែបើយើងប្រព្រឹត្តិអាក្រក់ នោះអំពើអាក្រក់នឹងបៀតបៀនយើងវិញ ។ តួយ៉ាងដូចជាក្នុងរឿងបានបញ្ជាក់ថាព្រះ ពោធិសត្វធ្លាប់ ជាស្តេចសោយរាជ្យ អស់រយៈពេលម្ភៃឆ្នាំ ដោយសារទោសនៃសោយរាជ្យបានធ្វើឲ្យព្រះ អង្គរងទុក្ខក្នុងឧស្សុទនរកអស់៨ម៉ឺនឆ្នាំ។សរបញ្ជាក់ឱ្យឃើញថាកាលពីព្រះពោធិសត្វសោយរាជ្យបានប្រព្រឹត្តិខុសធ្វើឱ្យមានកម្មពារហេតុជាប់ក្នុងនរកអស់ប្រាំបីម៉ឺនឆ្នាំ។
- អប់រំកុំឱ្យលោភលន់ នឹងទ្រព្យសម្បត្តិបុណ្យសក្តិ ផលអាក្រក់ពីការចង់មាន ចង់បានហួសព្រំដែនហួស ពីសមត្ថភាពរបស់ខ្លួន ។ ជួនកាលទ្រព្យសម្បត្តិបែជានាំទុក្ខវេទនាដល់យើងទៅវិញដូចជាព្រះ ពោធិសត្វ នៅក្នុងរឿងតេមិយព្រះអង្គមិនចង់បានអ្វីឡើយ ទាំងទ្រព្យសម្បត្តិ ទាំងការឡើងសោយរាជ្យ ព្រោះព្រះអង្គខ្លាចរង ទុក្ខវេទនាទទួលផលបាបពីវត្ថុទាំងនោះទើបព្រះអង្គ ធ្វើគ ធ្វើថ្លង់ ធ្វើខ្វិនដើម្បីគេចពីការសោយរាជ្យ។
- ត្រូវមានភក្តីភាពនិងការដឹងគុណ សេចក្តីស្មោះត្រង់ នឹងគ្នាធ្វើឲ្យមនុស្សទទួលបានសេចក្តីសុខរាប់អានដោយភាពជឿជាក់ដែល ជាសេចក្តីប្រសើរបំផុតរបស់មនុស្ស។ ព្រះពោធិសត្វបានមានព្រះបន្ទូលទៅកាន់នាយសារថីអំពីបុគ្គលណា មិនទ្រុស្តមិត្ត គឺបុគ្គលនោះតែងទទួលផលល្អ មានកិត្តិសព្ទ មានអ្នកចាំជួយជានិច្ចមិនមាន បុគ្គលណាអាច គ្របសង្កត់បានឡើយ គឺដោយសារតែភាពស្មោះត្រង់របស់ខ្លួន។ ការដឹង

គុណរាល់បុគ្គលម្នាក់ៗត្រូវមានភាពកតញ្ញូចំពោះឪពុកម្ដាយ បងប្អូន ឬក៏អ្នកដែលធ្វើគុណមក លើយើងដូចជាព្រះពោធិសត្វមានបន្ទូលថា«បុគ្គលអង្គុយឬដេកក្រោមម្លប់ឈើណាមិនគប្បីកាប់មែកឈើនោះទេ។»

- អប់រំឱ្យមនុស្សខ្លាចអំពើបាបសាង នូវអំពើកុសលដូចការសាងផ្នួស ដើម្បីសន្សំកុសលស្វែងរក សេចក្ដីសុខឱ្យខ្លួនដោយមិនប្រកាន់ភ្ជាប់នូវកិលេសទាំងឡាយ។

### ៧.៣.២. រឿងមហាជនកជាតក

**ក. ប្រធានរឿង**

នៅក្នុងរឿងមហាជនកជាតកអ្នកនិពន្ធក៏បានបង្ហាញពីការតស៊ូ អំណត់ព្យាយាម និងភាពឈ្លាសវៃរបស់ព្រះពោធិសត្វដើម្បីបានត្រាស់ជាព្រះសាមណគោតម ។

**ខ. មូលបញ្ហារបស់រឿង**

ក្នុងការសិក្សាមូលន័យនៃរឿងណាមួយ ជាដំបូងយើងត្រូវស្គាល់ឲ្យច្បាស់ថាមូលន័យមានន័យយ៉ាងណា? មូលន័យជាសមិទ្ធផលនៃប្រធានរឿងនៃស្នាដៃជាក់ស្ដែងមួយ ឬជាគំនិតសំខាន់ឬច្បងនៅក្នុងសាច់រឿងទាំងមូល ។ អ្នកនិពន្ធបង្កើតស្នាដៃនេះឡើងក្នុងគោលបំណង ចង់អប់រំប្រៀនប្រដៅឱ្យបុគ្គលគ្រប់រូបចេះថ្លឹងថ្លែង មានអំណត់អត់ធន់ក្នុងការងារណាមួយច្បាស់លាស់ មានទំនួលខុសត្រូវលើការងារដែលបំពេញ មិនត្រូវចុះចាញ់នូវរាល់ ឧបសគ្គដែលកើតឡើងចំពោះមុខមិនថាតូចឬធំឡើយ ព្រោះការព្យាយាមរមែងឱ្យយើង ទទួលបាននូវជោគជ័យមួយពិតប្រាកដ។ ក្នុងនោះមូលន័យនៅក្នុងរឿងមហាជនក គឺចង់និយាយពីលក្ខណៈនៃការតស៊ូព្យាយាម អ្វីក៏ដោយក៏ អាចទទួលបានលទ្ធផលល្អដែរ ក៏អាស្រ័យដោយការខំប្រឹងប្រែងតែមួយគត់ ។

ក្នុងរឿងទាំងមូលគំនិតទូទៅ គឺត្រង់ការតស៊ូរបស់មហាជនក និងការលះបង់ដ៏ខ្ពស់របស់ទ្រង់បានបង្ហាញឱ្យយើងដឹងពីសារប្រយោជន៍នៃការព្យាយាមទោះតិច ឬច្រើនក្ដី។

**គ. តួនាទីអប់រំនៃរឿងមហាជនកជាតក**

នៅក្នុងរឿងមហាជនកជាតកនេះក៏និយាយពីការខិតខំប្រឹងប្រែងតស៊ូព្យាយាមរបស់តួអង្គ ព្រះពោធិសត្វពិសេសគឺបានបង្កប់នូវការអប់រំជាច្រើនដល់បុគ្គលគ្រប់រូប ក្នុងការធ្វើអ្វីមួយដើម្បីកុំឱ្យធាប់ចុះចាញ់ភ្លាមៗពេកព្រោះការចុះចាញ់នេះ វារមែងតែទទួលបាននូវផលអវិជ្ជមានជាមិនខាន។រឿងនេះមានគោលបំណង អប់រំឱ្យយើងចេះមានជំនឿជាក់លើសមត្ថភាពរបស់ខ្លួន មានភាពអង់អាច អំណត់មិនតក់ស្លុតភិតភ័យមានភក្ដីភាពចំពោះការងារដែលខ្លួនធ្វើមិនរាថយ ឬរុញរានៅពេលដែលជួបបញ្ហាចំពោះមុខ ។

ពិសេសទៅទៀតរឿងនេះក៏បានលើកឡើងពីការតស៊ូយ៉ាងមុតមាំរបស់តួអង្គព្រះពោធិសត្វ នៅពេល ដែលជួបវិបត្តិផ្ទាល់ខ្លួន។ មួយវិញទៀតបង្ហាញឲ្យយើងដឹងពីការប្រុងប្រយ័ត្នរាល់ឧបសគ្គទាំងឡាយ ជាពិសេសសកម្មភាពទាំងអស់ដែលកើតមានឡើងនៅអតីតកាលឬក្នុងសង្គមជាតិនាពេលបច្ចុប្បន្ននេះ ។ ចំណុចដែលគួរ កត់សំគាល់នោះ គឺអ្នកនិពន្ធយើងចេះលើកយកសមុទ្រមកបញ្ចូលក្នុងសាច់រឿងដើម្បីបញ្ជាក់ថាវាគឺជាការស្មុគ ស្មាញធំដុំធំហួសប្រមាណដែលមនុស្សខ្លះមិនអាចធ្វើបាន ហើយមានតែមហាជនកទេដែលបានលិចសំពៅ នៅកណ្ដាលមហាសាគរមិនអស់សង្ឃឹមខិតខំហែលរហូតដល់ចុងក្រោយ គឺមានទេវតារក្សាសមុទ្រមកជួយ ស្រោចស្រង់ឱ្យរស់

ពានមានជីវិត នេះហើយជាលទ្ធផលនៃការប្រឹង ប្រែងរបស់ទ្រង់។ ដូចនេះអត្ថន័យនៃសាច់រឿងទាំងមូលគឺ ***សេចក្ដីព្យាយាមអំណត់*** នេះឯង ។ អ្នកនិពន្ធបានបង្កប់នូវទស្សនៈសំខាន់ ៗសម្រាប់ការអប់រំទូន្មានប្រៀនប្រដៅដល់មនុស្សទូទៅតាំងពីអតីតកាលដល់បច្ចុប្បន្ន។ ដូច្នេះក្នុងរឿងនេះយើងអាចទាញបានទស្សនៈសំខាន់ៗដូចជា៖

- សេចក្ដីព្យាយាមនាំឱ្យសម្រេច
- តក់ៗពេញបំពង់
- សេចក្ដីព្យាយាមរមែងផុតទុក្ខ
- ចំណេះជាអាហារប្រាជ្ញាជាអាវុធ
- ចំណេះវិជ្ជាជាឃ្លាំងទ្រព្យ

រឿង**មហាជនកជាតក**ជារឿងពុទ្ធនិយមដែលមានលក្ខណៈបរិបូរពេញទៅដោយគោលដៅ អប់រំសមហេតុផល ម្យ៉ាងទៀតអ្នកនិពន្ធក៏បានលើកយកទ្រឹស្ដីពុទ្ធនិយមក្នុងព្រះពុទ្ធសាសនាមកបកស្រាយ យ៉ាងជាក់លាក់គឺ"**អត្តាហិអត្តនោនាថោ**" ខ្លួនទីពឹងខ្លួនរបស់ព្រះអង្គដែលជាតួព្រះពោធិសត្វ។ ទស្សនៈនៃការ អប់រំគឺអ្នកនិពន្ធបានយកតួអង្គមហាជនក ជាគោលដែលអនុវត្តនូវការព្យាយាមយ៉ាងខ្ជាប់ខ្ជួន តាំងពីដើមទីរហូតដល់ចប់។ ទោះជាមានឧបសគ្គធ្ងន់ធ្ងរយ៉ាងណាក៏ទ្រង់មិនរាថយហើយខំប្រឹងប្រែងលុះសម្រេចបានតាមបំណង។ ក្នុងរឿងនេះដែរក៏បានអប់រំដល់កូនចៅជំនាន់ក្រោយៗឱ្យចេះតែធ្វើអំពើល្អចេះគិតពិចារណាល្អិតល្អន់ ជឿលើសមត្ថភាពខ្លួនមានសីលធម៌ល្អក្នុងខ្លួនជាពិសេសមានសេចក្ដី អត់ធ្មត់ក្នុងការងារ ដែលខ្លួនត្រូវ បំពេញ។បញ្ហាដែលមនុស្សលោកជួបប្រទះក្នុងវាលវដ្ដសង្សារដ៏ធំធេង ហើយវាបានផ្ដល់បទពិសោធន៍យ៉ាងជោគជាំ សម្រាប់សត្វលោក ម្យ៉ាងទៀតរឿងនេះបានធ្វើឱ្យមនុស្សខ្មែរស្គាល់ និងយល់ច្បាស់ពីកំណើតការតស៊ូ និងលទ្ធផលនៃការតស៊ូផងដែរ ។

### ៧.៣.៣. រឿងសុវណ្ណសាមជាតក

### ក.ប្រធានរឿង

ក្នុងស្នាដៃអក្សរសិល្ប៍បែបពុទ្ធនិយមសុទ្ធសាធ ឬ ទសជាតក អ្នកនិពន្ធតែងតែលើកយកការកសាងបារមីរបស់ព្រះពោធិសត្វ ដើម្បីបានត្រាស់ដឹងជា ព្រះសម្មាសម្ពុទ្ធនៅអនាគតជាតិ ។ ចំពោះរឿងសុវណ្ណសាម គឺសម្ដែងពីការបំពេញមេត្តាបារមី របស់ព្រះពោធិសត្វ ដែលស្ដែងឡើងដូចខាងក្រោម ៖

**-មេត្តាចំពោះមាតាបិតា**

ការដឹងគុណចំពោះមាតាបិតា គឺជាទង្វើប្រកបដោយគុណធម៌ កតញ្ញូ កតវេទី របស់បុត្រធីតា ជាពិសេសនៅពេលលោកទាំងពីរចាស់ជរា និងមានជំងឺ ។ ជាក់ស្ដែងនៅពេលដែលតសីទាំងពីរ ជាមាតាបិតាត្រូវពស់ព្រួសពិសខ្វាក់ភ្នែកទាំងពីរ សុវណ្ណសាមទទួលខុសត្រូវចិញ្ចឹមថែរក្សា និងខិតខំថែទាំ ទាំងអាហារ ផ្លែឈើ ទឹក និងកិច្ចការបម្រើសព្វគ្រប់ទាំងអស់ ។"សុវណ្ណសាមទុកមាតាបិតាក្នុងអាស្រម ទៅសន្សំមូលផលាក្នុងព្រៃ ព្រឹកៗបោសលំនៅនៃមាតាបិតា ហើយកណ្ដៀតក្អមចុះទៅស្ទឹងមិគសម្មតា ដងទឹកសម្រាប់មាតាបិតាឆាន់ ប្រើប្រាស់ ហុចទឹកខ្ពុរព្រះឱស្ឋ និងឈើស្ទន្ត ហើយប្រគេនមធុរផលានុផល លុះមាតាបិតាឆាន់ឆ្អែតស្កប់ស្កល់ ទើបយកសំណល់មកឆាន់ខ្លួនឯង..."។

**- មេត្តាចំពោះសត្វ ( ម្រឹគ -កិន្នរ- ចតុបាទ )**

ការមិនសម្លាប់ជីវិតសត្វ ជាអំពើល្អ ជាកុសលកម្ម ដែលព្រះពោធិសត្វតែងតែមានចំពោះសព្វសត្វទាំងឡាយក្នុងភពត្រៃ ។ ដោយសេចក្តីមេត្តានោះហើយ ទើបនៅពេលសុវណ្ណសាម ចេញដំណើរស្វែងរកផលានុផល និងដងទឹកជូនមាតាបិតា តែងមានពួកកិន្នរាកិន្នរី ដើរដង្ហែរអមជានិច្ច ។ ដូចមានសេចក្តីថា ៖ "ពួកកិន្នរីតែងនាំគ្នាបេះផលានុផលប្រគេនដល់ពោធិសត្វ ˝

**- មេត្តាចំពោះបិលយក្ខក្សត្រដែនកាសី**

ការតាំងចិត្តមិនខឹងក្រោធ ចំពោះអ្នកដែលប្រព្រឹត្តអំពើមិនគប្បី ឬ ទង្វើព្រៃផ្សៃមកលើខ្លួន វាជាការ តាំងចិត្តដ៏ឧត្តម និងជាសកម្មភាពដ៏កម្រ ដែលមនុស្សទូទៅ ពុំអាចធ្វើបាន ។ ជាក់ស្តែងបិលយក្ខ ជាអ្នកចូលចិត្ត សាច់ម្រឹគ ហើយនៅពេលឃើញសុវណ្ណសាម ស្និទ្ធស្នាលជាមួយម្រឹគ ក៏ច្រណែន ហើយបានបាញ់ពោធិសត្វដោយព្រួញ ព្រួញនោះធ្វើឱ្យសុវណ្ណសាមឈឺចាប់ពើតផ្សាណាស់ ប៉ុន្តែពុំមានចិត្តខឹងសម្បារនិងបិលយក្ខឡើយ។"...ទូលបង្គំឈ្មោះសាម ជាកូនឥសី ថ្ងៃនេះ ទូលព្រះបង្គំដល់មាត់មច្ចុរាជ ហើយសូមទ្រង់ទតចុះ ទូលព្រះបង្គំទទួលព្រះរាជទានដំណោកត្រាំក្នុងឈាមរបស់ខ្លួន មានព្រួញមុតពីខាងស្តាំទៅធ្លាយឆ្វេង មានឈាមខ្ពុរ ចេញតាមមាត់ចាប់ពើតណាស់ព្រះអង្គអើយព្រះអង្គ! ˝

តើការកសាងបារមី( មេត្តាបារមី )របស់ព្រះពោធិសត្វជាប់ទាក់ទងនឹងបញ្ហាអ្វីខ្លះ ?

## ខ- មូលបញ្ហារឿង

ការកសាងបារមី គឺជាលក្ខណៈពិសេស នៅក្នុងរឿងទសជាតក ។តាមរយៈដំណើររឿងតួអង្គព្រះពោធិសត្វបានបំពេញនូវសកម្មភាពផ្សេងៗ ដើម្បីបានសម្រេចនូវ បារមីធម៌ របស់ខ្លួន។ ក្នុងរឿងសុវណ្ណសាម តួអង្គព្រះពោធិសត្វបំពេញនូវមេត្តាបារមី ហើយជុំវិញការបំពេញ មេត្តាបារមីនេះ ជាប់ទាក់ទងនឹងបញ្ហាដូចតទៅ ៖

### ក. បញ្ហាការចេញទៅបួសជាឥសីនៃទុកូល និងបារិកា

រឿង បានលើកយកបញ្ហាការមិនធ្វើបាណាតិបាត( មិនសម្លាប់ជីវិត )ការមិនសេពនូវកាម និងការចេញទៅបួស ជាឥសី នៃប្តីប្រពន្ធ ជាកូននាយនេសាទទាំងពីរគ្រួសារមកចងជាបញ្ហាក្នុងដំណើររឿង។ការបួសជាឥសីនិងការមិនប្រព្រឹត្តកាមជារឿងត្រេកអរនៃព្រះឥន្ទ្រ ប៉ុន្តែដោយការប្រមើលមើលរបស់ព្រះឥន្ទ្រទៅអនាគតឥសី ទាំងពីរ ( ទុកូល និងបារិកា )នឹងពិការភ្នែកទាំងពីរ ហេតុនេះទើបមានពោធិសត្វពីស្ថានទេវលោកមកចាប់កំណើត នៅពេលព្រះឥន្ទ្រឱ្យទុកូល យកដៃស្ទាបផ្ទៃបារិកា។

ដូច្នេះ ការចេញបួសជាឥសី ការមិនសម្លាប់ជីវិតសត្វ និងការមិនប្រព្រឹត្តក្នុងផ្លូវកាមនៃអ្នកទាំងពីរ គេថា ជាកិរិយាមួយប្រកបដោយធម៌ ធ្វើឱ្យព្រះឥន្ទ្រស្ថានទេវលោកមានចិត្តរំភើប ទើបយាងពោធិសត្វឱ្យច្យុតមកចាប់កំណើត ហើយមានចិត្តប្រកបដោយក្តីមេត្តាក្រៃលែង។

### ខ. បញ្ហាពិការភ្នែកនៃឥសីទាំងពីរជាមាតាបិតា

ការលើកយក បញ្ហាទុកូល-បារិកាឥសី ជាមាតាបិតានៃពោធិសត្វ រស់នៅក្នុងអាស្រមក្នុងព្រៃក្បែរស្ទឹងមិគសម្មតា ពេលចេញទៅរកបេះផ្លែឈើបានជ្រកភ្លៀងនៅក្រោមដើមឈើលើដំបូក ហើយត្រូវពស់វែកព្រួសពិស ឱ្យខ្វាក់ភ្នែកទាំងពីរនាក់។ ការពិការភ្នែកនៃមាតាបិតា ជាឱកាសល្អសម្រាប់ពោធិសត្វ( សុវណ្ណសាម ) ក្នុងការ ថែទាំបម្រើ តបស្នងសងគុណអ្នកទាំងពីរគ្រប់ពេលវេលា ហើយសុវណ្ណសាមបានសម្តែងនូវសេចក្តីរីករាយដោយ បាន

បម្រើមាតាបិតា។" ពោធិសត្វឋិតនៅពីចម្ងាយ ហុចឈើច្រត់មួយដ៏វែង ឱ្យមាតាបិតាតោងចុះអំពីដំបូករួចមកក៏យំ សោក សង្រេងសង្រៃ ដោយក្ដីអាណិតមាតាបិតា ហើយបែរជាសើចវិញដោយគិតថា នឹងបានបម្រើមាតាបិតាជាប់មិនដាច់។ ″

មួយវិញទៀត ទោះជាស្ថិតក្នុងស្ថានភាពបែបណាក៏ដោយ សុវណ្ណសាម នៅតែនឹកគិត និងព្រួយបារម្ភចំពោះមាតាបិតាពិការទាំងពីរជានិច្ច ។ ជាក់ស្ដែង ខ្លួនឯងត្រូវព្រួញឆ្លាយពីស្ដាំទៅឆ្វេង ហូរឈាម ឈឺចាប់ជិតដាច់ខ្យល់ស្លាប់ហើយនៅតែគិតគួរពីបញ្ហាសុខទុក្ខរបស់មាតាបិតាជានិច្ច នៅពេលដែលគ្មានរូបខ្លួន។

"ឱមាតាបិតាជាទីគោរពរបស់កូនអើយ! លោកមានជីវិតយ៉ាងយូរណាស់ត្រឹម៦ថ្ងៃប៉ុណ្ណោះ ព្រោះមាន ត្រឹមតែភោគជនជាផលានុផល ងងឹតងងល់រកទឹកពុំបាន មុខជានឹងស្លាប់ដោយឥតទឹកពុំខានឡើយ ព្រះអង្គអើយ ព្រះអង្គ! ការត្រូវកាំសរនេះ មិនជាសេចក្ដីទុក្ខធ្ងន់ របស់ទូលបង្គំទេ មានតែខានឃើញមាតាបិតា ទើបជាសេចក្ដី ទុក្ខធ្ងន់ដ៏ក្រៃលែងរបស់ទូលព្រះបង្គំ ... ។ ″

បញ្ហាការពិការភ្នែកនៃមាតាបិតានេះហើយ អាចឱ្យពោធិសត្វបម្រើគ្រប់សព្វទាំងថ្ងៃទាំងយប់ វាជាមូលដ្ឋាន ឬ ជាបច្ច័យក្នុងការកសាងនូវមេត្តាបារមី មិនតែប៉ុណ្ណោះវាជាដំណាក់កាលមួយសម្រាប់ដកពិសោធ និងជាឧបសគ្គដែលតម្រូវឱ្យពោធិសត្វត្រូវឆ្លងកាត់ ដើម្បីសម្រេចនូវសម្ពោធិញាណ ជាព្រះសម្មាសម្ពុទ្ធនៅអនាគតជាតិ ។

**គ. បញ្ហាព្រះបិលយក្ខក្សត្រដែនកាសីចូលចិត្តសាច់ម្រឹគ និងការបរបាញ់**

ដំណើរនៃការសាងបារមីនៃព្រះពោធិសត្វតែងតែជួបប្រទះនូវបញ្ហា ដែលជាឧបសគ្គរាំងស្ទះដែលធ្វើឱ្យអាក់ដំណើរបំពេញបារមីរបស់ពោធិសត្វជានិច្ច។ ម៉្យាងវិញទៀតការសាងបារមីបានសម្រេច លុះត្រាតែមានការពិសោធពីខ្លួនឯងផង និងពីអ្នកដទៃផង។ សកម្មភាពរបស់ បិលយក្ខ ជាផ្នែកមួយចូលរួមធ្វើឱ្យ សុវណ្ណសាម បានសម្រេចនូវមេត្តាបារមីរបស់ខ្លួន ។ នៅពេលត្រូវគ្រាប់ព្រួញរបស់បិលយក្ខហើយ សុវណ្ណសាម នៅតែសម្ដែងនូវ សេចក្ដីមិនខឹងក្រោធ ហើយថែមទាំងផ្សាយនូវសេចក្ដីមេត្តាចំពោះក្សត្រដែនកាសីអង្គនោះទៀតផង។ ពោធិសត្វ បានទូន្មានចំពោះបិលយក្ខក្សត្រ ឱ្យប្រព្រឹត្តនូវធម្មចរិយាចំពោះមាតាបិតា កូន ប្រពន្ធ និងអ្នកដទៃ ហើយប្រកាន់នូវ សីលប្រាំ ឬ សិក្ខាបទទាំង ប្រាំ ជាពុទ្ធបញ្ញត្តិ ទៀតផង។

" សត្វណាចិញ្ចឹមនូវមាតាបិតាដោយធម៌ ទេវតាទាំងឡាយតែងរក្សានូវសត្វនោះ បណ្ឌិតទាំងឡាយតែងសរសើរនូវសត្វនោះ ។ បពិត្រព្រះបាទបិលយក្ខ សូមព្រះអង្គប្រព្រឹត្តនូវធម្មចរិយាចំពោះមាតាបិតា បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តនូវធម្មចរិយាចំពោះមាតាបិតាក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ពុំខាន។ ″

**គ- តួនាទីអប់រំនៃរឿងសុវណ្ណសាមជាតក**

តាមរយៈសាច់រឿងទាំងមូល អ្នកនិពន្ធបានបង្ហាញពីគោលគំនិត (គំនិតអប់រំ)សំខាន់ៗ ដូចតទៅ៖

**- ការដឹងគុណចំពោះមាតាបិតា**

កូនត្រូវមានចិត្តកតញ្ញូ និងមានកាតព្វកិច្ចតបគុណចំពោះមាតាបិតា ព្រោះលោកជាអ្នកចិញ្ចឹមបីបាច់ថែរក្សាកូនតាំងពីតូចដល់ធំ និងផ្ដល់នូវអ្វីៗគ្រប់បែបយ៉ាងដល់កូន។ ឪពុកម្ដាយជាអ្នកមានគុណដ៏លើសលប់ និងជាបុគ្គលដែលជាទីសក្ការបូជាចំពោះកូនលោកតែងមានព្រហ្មវិហារធម៌ចំពោះកូន ការពារកូន ណែនាំកូនឱ្យដើរផ្លូវល្អ។ ឪពុកម្ដាយ ត្រូវបានគេចាត់ទុកថាជាព្រះកន្លោង នៅក្នុងផ្ទះ លោកជាបុព្វទេវតា ថែរក្សាកូនមុនគេបង្អស់ និង ជាបុព្វាចារ្យ គឺជាគ្រូ បង្រៀននូវអ្វីៗដល់កូន មុនគ្រូដទៃណាណា ទាំងអស់។ ដូចនេះ កូនត្រូវតែមានចិត្តកតញ្ញូ និងកតវេទី ចំពោះ

មាតាបិតា ត្រូវដើរតាមគន្លងធម៌ និងស្តាប់តាមការទូន្មានប្រៀនប្រដៅរបស់លោកទាំងពីរ ។ បុគ្គលដែលបានធ្វើនូវការតបស្នងសងគុណចំពោះមាតាបិតា តែងទទួលបាននូវសព្ទសាធុការពរ និង កុសលធម៌ដែលអាចជៀសផុតពីឧបសគ្គ និងគ្រោះថ្នាក់ផងទាំងពួងបានថែមទៀតផង។ ជាក់ស្តែង សុវណ្ណសាម ជាបុគ្គល ដឹងគុណមាតាបិតា និងមានមេត្តាចំពោះមនុស្ស សត្វ ដទៃ ទទួលបាននូវការស្រលាញ់រាប់អានពីសព្វសត្វក្នុងព្រៃ មនុស្ស ទេវតា ជាពិសេសដោយអានុភាពនៃ ការដឹងគុណចំពោះមាតាបិតា និងសេចក្តីមេត្តាចំពោះ មនុស្ស សត្វ ធ្វើឱ្យទេវតារំភើប ផ្តល់ពរសព្ទសាធុការ ឱ្យរស់រានមានជីវិតឡើងវិញ ក្រោយពេលដែលត្រូវព្រួញរបស់បិលយក្ខ ។

**- ឱ្យមនុស្សប្រព្រឹត្តអំពើល្អ មានសេចក្តីមេត្តា ប្រកាន់នូវចរិយាធម៌ និងសីលប្រាំ**

អំពើបាប ជាប្រភពនៃទុក្ខ ដែលនាំទៅកាន់ភាពលំបាកវេទនា និងនរក។ ដូចនេះ សេចក្តីមេត្តា ការមិនចងគំនុំ និងការរក្សានូវសីលប្រាំ គឺ ៖

១- បាណាតិបាតា គឺ ការមិនសម្លាប់សត្វ

២- អទិន្នា គឺ ការមិនឆក់ប្លន់ លួចទ្រព្យសម្បត្តិអ្នកដទៃ

៣-កាមេសុមច្ឆាគឺការមិនប្រព្រឹត្តខុសក្នុងផ្លូវកាម (ប្រព្រឹត្តខុសលើ ប្រពន្ធ កូនអ្នកដទៃ)

៤- មុសា គឺការមិនពោលពាក្យកុហក

៥- សុរា គឺការមិនសេពនូវគ្រឿងស្រវឹងផ្សេងៗ (សុរា និង មេរាយ)

ការប្រកាន់នូវធម្មចរិយា និងសីល៥ នេះ នាំមកនូវសេចក្តីសុខចំពោះ ខ្លួនឯងគ្រួសារ និងសង្គម នៅក្នុងបច្ចុប្បន្នជាតិ និងអនាគតជាតិ ។ ដូចមានសេចក្តីនៅក្នុងទំព័រ៧០-៧១ ថា ៖

"... បពិត្រព្រះរាជា លុះទ្រង់ប្រព្រឹត្តធម្មចរិយាក្នុងលោកនេះហើយ ទ្រង់នឹងទៅកាន់ឋានសួគ៌ ធម្មចរិយាដែលទ្រង់ប្រព្រឹត្តល្អហើយ តែងនាំមកនូវសេចក្តីសុខ។ ...ទេវតាឥន្ទ្រព្រហ្មទាំងឡាយ ដែលបានទៅកាន់ឋានសួគ៌ក៏ព្រោះតែធម្មចរិយាដែលខ្លួនប្រព្រឹត្តល្អនេះឯង សូមព្រះអង្គកុំប្រហែសធ្វេស នឹងធម្មចរិយាឡើយ។ ព្រះពោធិសត្វថ្វាយដំបូន្មានដល់ព្រះរាជាយ៉ាងនេះហើយ ទើបថ្វាយសីលប្រាំតទៅទៀត ។"

**- អប់រំឱ្យមនុស្សចេះរស់នៅជាមួយគ្នាប្រកបដោយសន្តិភាព**

ការអធ្យាស្រ័យឱ្យគ្នាទៅវិញទៅមក និងចេះជួយគ្នាក្នុងគ្រាមានអាសន្ននាំមកនូវសន្តិភាព ។ មនុស្សមិនអាចរស់នៅតែម្នាក់ឯងបានឡើយ គឺតែងមានការពឹងពាក់គ្នាទៅវិញទៅមក ជួយយកអាសារគ្នាពេលជួបបញ្ហាអ្វីមួយដោយយថាហេតុ ។ ជាក់ស្តែងដូច ទេវធីតាសុន្ទរី បានណែនាំបិលយក្ខ ឱ្យមានការភ្ញាក់រលឹក និងទំនួលខុសត្រូវចំពោះទង្វើខ្លួន ហើយថែមទាំងជួយអាសារដល់សុវណ្ណសាម ពេលជួបនឹងគ្រោះថ្នាក់ទៀតផង ។ ជាពិសេសទៅទៀត មនុស្សត្រូវមាន ការដោះស្រាយបញ្ហាប្រកបដោយសន្តិវិធី ជៀសវាងការប្រើកម្លាំងបាយ កំហឹងទល់នឹង កំហុស គំនុំគំគួន សងសឹកគ្នាទៅវិញទៅមក ដែលនាំឱ្យចំណងកាន់ជ្រៅដោះស្រាយមិនបាន។

### ៧.៣.៤. រឿងនេមិរាជជាតក

### ក.ប្រធានរឿង

រឿងនេមិរាជ បានបង្ហាញពីការអធិដ្ឋានបារមី គឺការជឿស៊ប់ទៅលើកុសលកម្ម។

### ខ. មូលបញ្ហារឿង

ជុំវិញប្រធានរឿងនេះយើងអាចកំណត់នូវបញ្ហាជាច្រើន ជាមែកធាង ដែលស្ថិតនៅជុំ វិញការអធិដ្ឋានបារមី

(ការជឿស៊ប់) យើងអាចដឹងនូវបញ្ហាមួយចំនួនដូចជា៖

- ការចេញទៅសាងផ្នួសរបស់ព្រះអង្គ
- ការរក្សាសីលឧបោសថ
- ការធ្វើកុសលបរិច្ចាគទាន
- ការធ្វើទណ្ឌកម្មចំពោះអ្នកដែលធ្វើអំពើបាបផ្សេងៗ
- ការសោយសុខលើទិព្វសម្បត្តិ ដែលបានមកពីការកសាងបុណ្យ

តាមរយៈការលើកឡើងនេះ ពិតជាបានធ្វើឲ្យយើងដឹងពីមូលហេតុនៃការជឿស៊ប់ទៅ លើការកសាងអំពើបុណ្យ ដែលផ្តល់ជាកុសល និងការសាងអំពើបាប ។

**គ.តួនាទីអប់រំនៃរឿងនេមិរាជជាតក**

**+បញ្ហាទី១ ការយាងចេញទៅសាងផ្នួសរបស់ព្រះអង្គ**

ដើម្បីសម្រេចសម្មាសម្ពោធិញាណ ត្រាស់ដឹងជាព្រះពុទ្ធ ព្រះអង្គត្រូវយាងចេញទៅ សាងភ្នួស ស្វែងរកធម៌នៅ ក្នុងព្រៃព្រឹក្សា ។ ព្រះអង្គយល់ថា ការចេញទៅសាងភ្នួសអាច ជួយឲ្យខ្លួនព្រះអង្គផ្ទាល់ និងប្រជារាស្ត្រ បានជ្រះស្រឡះពីកាមកិលេស និងអាច ជំរះអស់ នូវ បាបកម្មទាំងឡាយ ។ ក្នុងពុទ្ធសាសនាគេច្រើននិយាយពីការ ចេញទៅសាងផ្នួសបំពេញ បារមី ដែលអាចរកឃើញនូវផ្លូវត្រឹមត្រូវ វៀរចាកអំពើអកុសល ។ ដូច្នេះការចេញសាងភ្នួស មានសារៈសំខាន់ណាស់ចំពោះព្រះពុទ្ធសាសនា។ ក្នុងការចេញទៅសាងផ្នួសរបស់ព្រះអង្គ ព្រះអង្គបានរក្សា នូវសីលឧបោសថ និងការធ្វើកុសល បរិច្ចាគទាន។ ព្រះអង្គបានឱ្យទាន ដល់ជនទុគ៌តគ្រប់ពេលវេលា ហើយបានយកចិត្តទុកដាក់ទេសនា អប់រំណែនាំអាណា ប្រជានុរាស្ត្រ មន្ត្រីតូចធំ ឲ្យសាងនូវអំពើសុចរិត កុំលោភលន់ កុំកេងប្រវ័ញ្ចគ្នាកុំកាប់សម្លាប់គ្នា កុំបង្កវិនាសកម្មផ្សេងៗដល់សង្គម។ ព្រះអង្គបានរក្សានូវព្រហ្មវិហារធម៌ទាំង៤ ក្នុងការដឹកនាំចាត់ចែងនគរ ហើយតែងតែរក្សានូវសីលប្រាំយ៉ាងខ្ជាប់ខ្ជួន ដើម្បីតម្រង់ផ្លូវចិត្ត ឱ្យតាំងចិត្តនូវក្នុងផ្លូវល្អ។ ព្រះអង្គមិនប្រព្រឹត្តអំពើប្រទូស្តនឹងផលប្រយោជន៍អ្នកដទៃ ដោយព្រះអង្គតែងតែបានណែនាំឱ្យពលរដ្ឋគ្រប់ៗគ្នា កសាងនូវប្រយោជន៍ ជៀសវាងកុំឱ្យមានការក្តៅក្រហាយដល់ខ្លួនទៅថ្ងៃក្រោយ។ ដូចនេះ ការចេញទៅសាងផ្នួស រក្សាសីល និងការធ្វើនូវកុសល អាចធ្វើឱ្យព្រះអង្គសម្រេចត្រាស់ដឹងជាព្រះពុទ្ធ ។

**+បញ្ហាទី២ ការធ្វើកុសលបរិច្ចាគទាន**

ការធ្វើកុសលបរិច្ចាគទាន វាមានសារៈសំខាន់ណាស់ក្នុងការជួយសង្គ្រោះគ្នាទៅវិញ ទីមក ហើយវាក៏បានបង្ហាញនូវចិត្តមេត្តាសន្តោសប្រោសប្រណី និងចិត្តសប្បុរសធម៌ពីសំ ណាក់ព្រះអង្គ។ ព្រះនេមិរាជ ព្រះអង្គបានបរិច្ចាគទានយ៉ាងច្រើនដល់ប្រជានុរាស្ត្រ ដូចជាទ្រង់
ឲ្យកសាងនូវសាលាទានប្រាំខ្នង ទ្រង់បរិច្ចាគប្រាក់ព្រះរាជទ្រព្យមួយពាន់កហាបណៈ សំរាប់ ព្រះរាជទានដល់អ្នកកំសត់ទុគ៌ត ក្នុងសាលានីមួយៗរាល់ៗថ្ងៃ ដោយព្រទ័យជ្រះថ្លា និងសទ្ធាដ៏ មហិមារបស់ព្រះអង្គ។ ការបរិច្ចាគទានរបស់ព្រះ ព្រះអង្គចង់បង្ហាញអោយឃើញនូវកុសល ផលបុណ្យដែលទទួលបានពីផលទាន គឺអោយខិតខំកសាងអំពើល្អ នឹងអាចកើតនៅឋាន សួគ៌ ដែលជាឋានរបស់ទេវតា។

**+បញ្ហាទី៣ ការរក្សាសីលឧបោសថ**

ព្រះអង្គបានរក្សាសីល៥ជានិច្ច តែព្រះអង្គក៏មិនភ្លេចការរក្សាសីលឧបោសថផងដែរ ទ្រង់តែងបបួលប្រជានុ

រាស្ត្រក្នុងការធ្វើបុណ្យជាកុសល ទ្រង់តែងសំដែងធម៌ប្រាប់ផ្លូវឋាន សួគ៌ ព្រមទាំងនាំប្រជានុរាស្ត្រឲ្យចេះខ្លាចនរក។

**+បញ្ហាទី៤ ការធ្វើទណ្ឌកម្មចំពោះអ្នកដែលធ្វើអំពើបាបផ្សេងៗ**

មនុស្សម្នាក់ៗ ដែលកសាងអំពើអាក្រក់ តែងតែទទួលបាននូវផលអាក្រក់ជាពុំខាន ហើយក៏មិនអាចទូទាត់ដោយអំពើល្អបានឡើយ។ តួយ៉ាងព្រះអង្គបានយាងទៅដល់ឋាននរក នៅទីនោះមាតុលីបានបង្ហាញពីគ្រប់សត្វនរកដែលទទួលទណ្ឌកម្មសព្វសារពើ ដែលបានធ្វើបាបកាលពីនៅមានជីវិតរស់រាន ជាមនុស្សមិនបានធ្វើបុណ្យសាងកុសលទេ ដល់ពេលស្លាប់ទៅធ្លាក់ទៅនរក ហើយទទួលទណ្ឌកម្មដែលបានធ្វើ អ្នកដែលមានកម្មច្រើន ទទួលការធ្វើទារុណកម្មច្រើន ដូចជា ពីដើមជាស្រីលេងល្បែងផ្សេងៗ ដើរលេងមិនឆ្អែត លះបង់ស្វាមី អ្នកសម្លាប់សត្វ កេងបន្លំស្រូវអង្ករ .... ។

**+បញ្ហាទី៥ ការសោយសុខលើទិព្វសម្បត្តិ ដែលបានមកពីការកសាងបុណ្យ**

ដើម្បីរស់នៅប្រកបដោយសេចក្ដីសុខ សុភមង្គល មនុស្សត្រូវកសាងអំពើ ដែលជា កុសល លះបង់នូវកិលេសទាំងឡាយ ប្រកាន់ខ្ជាប់នូវសីលប្រាំ ខិតខំធ្វើបុណ្យទាន ដើម្បីសម្រេចបំណងប្រាថ្នារបស់ខ្លួន។ ព្រះអង្គបានទៅទតនៅ ឋានសួគ៌ ដែលជាឋានដែលល្អវិចិត្រ ប្រណិតទៅដោយវិមានដ៏រុងរឿង សំបូរទៅដោយកែវពិទូរ្យសុកាន្ត នេះក៏ដោយការធ្វើអំពើរបស់ទេវបុត្រ ទេវធីតាដែលបានធ្វើបុណ្យ នៅពេលដែលព្រះអង្គរស់នៅជាមនុស្សពួក គេខិតខំប្រព្រឹត្ត និងប្រតិបត្តិនូវអំពើល្អ កសាងនូវអំពើជាកុសល ចែកទាន កសាងសួនច្បារ ស្រះទឹក អណ្ដូងទឹក ផ្លូវថ្នល់ និងស្ពាន ហើយរក្សានូវសីលឧបោសថ ម្ល៉ោះហើយនៅពេលពួកគេស្លាប់ទៅ ក៏កើតនៅឋានសួគ៌ ដែលមនុស្សជាច្រើនប្រាថ្នាចង់ទៅ ពីព្រោះនៅទីនោះជាឋានដែលសប្បាយរីករាយ មានគ្រប់អម្ពរគ្រប់បែបយ៉ាង និងសូរតន្ត្រីទិព្វ ជាសំឡេង ដ៏ពិរោះរងំគួរឱ្យចង់ស្ដាប់ ។

**+គំនិតទូទៅរបស់រឿង**

-**កុសលកណ្ឌ** ជាការបរិយាយរៀបរាប់ពីការធ្វើបុណ្យ បរិច្ចាគទានដោយការកសាងសាលាទានប្រាំខ្នង និងប្រាក់ផ្ទាល់ព្រះអង្គ សម្រាប់ពួកកំសត់ទុរគតនិងរក្សាសីលឧបោសថ។ ការធ្វើអំណោយទានរបស់ទ្រង់បានផ្ដល់ ជំនឿនិងសទ្ធាជ្រះថ្លារបស់ប្រជាជន រឹងរិតតែឱ្យ គេមានជំនឿលើពុទ្ធសាសនាកាន់តែខ្លាំង និងមានការកោតខ្លាច គោរពប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួន។ កុសលរបស់ទ្រង់បានធ្វើឲ្យទ្រង់មានសំណាងបានជួបព្រះឥន្ទ្រ ដែលជាស្ដេចទេវតា មិនត្រឹមតែប៉ុណ្ណោះ ព្រះឥន្ទ្របានបំភ្លឺឱ្យឃើញពីព្រហ្មចរិយាធម្មថ្លៃថ្លាជាងផលនៃទានធម្មតា។ កិត្តិនាមរបស់ទ្រង់បានល្បីរន្ទឺដល់ឋានលើ ធ្វើឱ្យទេវតាទាំងឡាយ ចង់ស្ដាប់នូវពុទ្ធឱវាទរបស់ទ្រង់ ធ្វើឱ្យទ្រង់មានភព្វសំណាងបានចុះទតឋាននរក និងឋានសួគ៌ ឃើញពីភាពខុស ប្លែកគ្នារវាងស្ថានទាំងពីរ ។

- **និរយកណ្ឌ** ការចុះទតឋាននរករបស់ព្រះបាទនេមិរាជ លោកបានឃើញ នូវសត្វ នរក ទាំងឡាយទទួលទោសទណ្ឌដែលខ្លួនបានសាង ។ អ្នកណាធ្វើបែបណា នឹងទទួល បាន ផលនោះមកវិញ ។ មាតលី បានរៀបរាប់សព្វគ្រប់នូវសត្វនរក ដែលទទួលរងនូវអំពើ ទារុណកម្មដូច នេះ មកពីជាតិមុនបានសាងអ្វីខ្លះដល់ព្រះបាទនេមិរាជ ។ ការរៀបរាប់ របស់ មាតលី ធ្វើឲ្យយើងមានអារម្មណ៍ព្រឺព្រួចគួរខ្លាច ហើយអំពើទាំងនោះកើតមាន ក្នុងសង្គម មនុស្សជាក់ស្ដែង វា កាន់តែធ្វើឲ្យមនុស្សខ្លាចបាបកាន់តែខ្លាំង ។ ដូចនៅក្នុងឃ្លាដែលរៀប រាប់ពីសត្វនរក ដែលត្រូវពួកនិរយកាន់អាវុធ ដេញវាយសំពងធ្លាក់ចុះក្នុងស្ទឹងវេតរណីស្ទឹង នោះដេរដាសដោយព្រៃផ្ដៅមានបន្លាប៉ុនៗចំពុះទង់ ។ សត្វនរកទាំងនោះស្ទុះទម្លាក់ធ្លាក់ ទៅលើព្រៃផ្ដៅ ត្រូវបន្លាមុតថ្ពក់រយេះរយាយដូចគេអង្គន់ ភ័យស្លន់កញ្ជ្រោល ទម្លាក់ខ្លួន

ទៅ លើ ចម្រូងដែកស្រួចប៉ុនដែមត្នោត ប្រឹងលីច្រឡោតធ្លាក់ទៅលើស្លឹកឈូកដែក មានឡាមមុតដូចកាំបិតកោ ...... ធ្លាក់ក្នុងស្នឹងនោះទៅទៀត ។ ពួកនេះពីមុនជាមនុស្ស មានកម្លាំង មានអានុភាព មានចិត្តអាក្រក់ បៀតបៀនរំលោភលើអ្នកទន់ខ្សោយ។ សត្វ នរកដែលធ្វើបាបកម្មអ្វីទទួលផលគួរឱ្យតក់ស្លុត ។ មនុស្សដែលមានជំនឿកាន់ឧបោសថនៅ ពេលស្លាប់ និងទទួលពុទ្ធឱវាទ ពួកគេមានសទ្ធាជ្រះថ្លានឹងទទួលបានផលល្អពីអំពើរបស់គេ ។

- **សគ្គកណ្ឌ** បន្ទាប់ពីទតឋាននរក ការវេទនាវុណរបស់សត្វនរក ដែលប្រព្រឹត្តអំពើបាប ព្រះនេមិរាជបានទតនូវឋានសួគ៌ ដែលជាឋានរបស់ទេវតាឃើញភាពល្អ ល្អះនៃឋានសួគ៌ និងពពួកទេវតាដែលសោយសុខនៅលើទិព្វសម្បត្តិ។ ព្រះបាទនេមិរាជមិនបានភ្លើតភ្លើននឹងភាពឡូយឆាយទាំងនោះឡើយ ទ្រង់នូវតែ ប្រកាន់ខ្ជាប់ការធ្វើកុសលដោយការឲ្យទាន ទ្រង់មិនព្រមទទួលនៅអ្វីដែលគេឱ្យឡើយ។ នៅត្រង់ឃ្លាមួយដែលព្រះបាទនេមិរាជដោះស្រាយប្រស្នាតបនឹងព្រះឥន្ទ្រថា " ខ្ញុំព្រះអង្គ អរព្រះគុណ ណាស់ហើយ ប៉ុន្តែ**វត្ថុណាដែលបានព្រោះគេឱ្យ វត្ថុនោះមិនខុសពីទ្រព្យដែលខ្ចីគេទេ** "។ នេះជាទស្សនៈ អប់រំដ៏ល្អ ការឱ្យទានរបស់ទ្រង់ដោយកុសលជ្រះថ្លា តែក៏ បង្កប់ទៅដោយខ្លឹមសារអប់រំមួយចំនួន ដូចជាពាក្យដែលទ្រង់និយាយជាមួយព្រះឥន្ទ្រ អប់រំដល់មនុស្សទូទៅត្រូវចេះពឹងលើខ្លួនឯងពុំគប្បីពឹងទៅលើការឱ្យទានរបស់គេឡើយ។ ត្រូវសង្វាតស្វាធ្យាយរកបរចិញ្ចឹមជីវិតប្រកបដោយផ្លូវធម៌ មិនគេងប្រព្រឹត្តដណ្តើមឈ្នា នីសរបស់ទ្រព្យអ្នកដទៃ ត្រូវស្ថិតនៅក្នុងភាពស្មើភាពនោះ ទើបជីវិតស្លាប់ទៅជួបសុខជួបឋានសួគ៌ ។

**+គោលដៅអប់រំ**

រឿងនេមិរាជជាតក៍ ជារឿងដែលលើកយកទស្សនៈនៃការអប់រំមកពន្យល់បង្ហាញដល់ អ្នកអានឱ្យយល់ច្បាស់ពីចលនាពុទ្ធនិយម ដូចជា៖

- អប់រំមនុស្សឱ្យកសាងអំពើល្អ ដែលជាកុសលដើម្បីឲ្យខ្លួនវៀរចាកឱ្យផុតពីទុក្ខលំបាកវេទនា ដែលយើងមើលមិនឃើញទៅថ្ងៃអនាគត។ ជាពិសេសការកសាងអំពើល្អអាចធ្វើ ឱ្យមនុស្សជ្រះស្រឡះពីអំពើបាបផ្សេងៗនិងមានសេចក្តីសុខហើយក៏ជាគំរូដ៏ល្អ មួយសម្រាប់ អ្នកកាន់ពុទ្ធសាសនា ។
- អប់រំមនុស្សឱ្យប្រកាន់ខ្ជាប់នូវសីលប្រាំ ដែលជាផ្នែកនៃព្រះពុទ្ធសាសនាដែលអប់រំ មនុស្សឱ្យវៀរឆ្ងាយពី អំពើអបាយមុខផ្សេងៗ ដូចជាសម្លាប់សត្វ ផឹកស្រាលួចឆក់ទ្រព្យ សម្បត្តិ និយាយកុហក និងលួចប្តីប្រពន្ធគេ អ្វីដែល មិនមែនជារបស់ខ្លួនឯង។
- អប់រំមនុស្សឱ្យប្រកាន់នូវសីលឧបោសថ (សីលប្រាំបី) ដែលវាបន្ថែមទៅលើសីលប្រាំ ហើយត្រូវតែ ប្រកាន់ឱ្យបានខ្ជាប់ខ្ជួន និងប្រតិបត្តិតាម ជាពិសេសត្រូវវៀរចាកនូវការ ស្លៀកពាក់ឆើតឆាយ ពាក់គ្រឿងអលង្ការគ្រែដេកមិនឲ្យលើសពីកន្លះម៉ែត្រ និងមិនត្រូវ លេងល្បែងស៊ីសង។
- អប់រំមនុស្សឱ្យចេះបែងចែកខុសត្រូវ អាក្រក់ល្អ សខ្មៅឱ្យដាច់ស្រឡះពីគ្នា។

## ៧.៣.៥. រឿងមហោសថជាតក

### ក. ប្រធានរឿង

ក្នុងចលនាអក្សរសិល្ប៍ពុទ្ធនិយម ច្រើនលើកយកប្រធានបទ "ការកសាងបារមី "មកចោទ និងដោះស្រាយ។ ក្នុងរឿងព្រះមហោសថ គឺបានបង្ហាញពីការកសាងបញ្ញាបារមីទាំង ១៩ របស់ តួអង្គព្រះពោធិសត្វ ។

### ខ. មូលបញ្ហារឿង

មូលបញ្ហារឿងជាគំនិតសំខាន់នៅក្នុងសាច់រឿងហើយវាជាសមិទ្ធផលរបស់ប្រធានរឿង។ មូលបញ្ហា

ដែលធ្វើឱ្យព្រះមហោសថទទួលបាននូវបញ្ញាបារមីមានៈ

**បញ្ហាទី១ ការដោះស្រាយលើបញ្ហាទាំង១៩ ដែលមានរូបភាពផ្សេងៗគ្នាដូចខាង ក្រោមៈ**

-**ទី១ មំសំ( សាច់ )**មានសត្វខ្លែងមួយបានឆាបឆក់យកសាច់មួយដុំពីជ្រុញអ្នកលក់ហើរឆ្ពោះ ទៅកាន់អាកាស ហើយក្មេងឃើញក៏តេដេញ ខ្វះដួល តែសត្វនោះមិនព្រមទម្លាក់ ព្រះមហោសថ ក៏ឃាត់ក្មេងទាំងនោះ ពេលនោះ មហោសថបានស្ទុះមួយទំហឹងទៅជាន់ស្រមោលសត្វខ្លែងហើយ ស្រែកខ្លាំងៗ ធ្វើឱ្យលកសំឡេងនោះ ទៅប៉ះនឹង សត្វខ្លែង ហើយធ្វើឱ្យសត្វខ្លែងភ័យក៏ទម្លាក់ដុំសាច់នោះមក ។

- **ទី២ គោណោ ( សត្វគោ )** ការដោះស្រាយបញ្ហាវវាងបុរសម្ចាស់គោ និងចោរ។ ការប្តឹង គ្នារវាងម្ចាស់គោ និង ចោរ ធ្វើឱ្យព្រះមហោសថចេញមុខដោះស្រាយប្រកបដោយ យុត្តិធម៌ ។

- **ទី៣ កណ្ឋិ ( សង្វារ )** ដោះស្រាយបញ្ហាដោយឱ្យស្ត្រីម្ចាស់សង្វារឈ្នះលើស្ត្រីជាចោរ ។

- **ទី៤ សុត្តំ(អំបោះ )** មានស្ត្រីម្នាក់រវៃអម្បោះដាក់ផ្លែទម្លាប់ខាងក្នុងធ្វើជាហុងអម្បោះ ពេលធ្វើដំណើរទៅដល់ ស្រះបោក្ខណីមួយ ក៏ទុកហុងអំបោះនៅលើសំពត់ ហើយក៏ចុះទៅងូតទឹក ពេលនោះមានស្ត្រីចោរម្នាក់មកលួច ហើយ ម្ចាស់មកទាន់ទាយកវិញ ស្រីចោរមិន ព្រមឱ្យរឿង នេះបានដឹងដល់ព្រះមហោសថ ហើយមហោសថបានហៅអ្នក ទាំងពីរមកសួរ តាមដំណើររឿង ពេលដឹងរឿងហើយក៏បានកាត់ក្តីស្រីជាម្ចាស់ហុងអំបោះឈ្នះ ។

**- ទី៥ បុត្តោ ( កូន )** ការដោះស្រាយទៅលើបញ្ហាមានស្រីម្នាក់មានកូនមួយទុកចោល នៅមាត់ស្រះ ហើយចុះ ទៅងូតទឹកក្នុងស្រះបោក្ខណី ពេលនោះមានយក្ខមួយប្រែក្រឡា យកកូននោះបំរុងហែកស៊ី ម្តាយមកទាន់ក៏ដណ្តើម យក្ខនោះមិនព្រមហើយប្រកែកឮដល់ មហោសថ ហើយមហោសថក៏បានគូសរង្វង់ដាក់កូននោះនៅចំកណ្តាលឱ្យ ស្រីទាំង២នាក់ នោះដណ្តើមគ្នា ម្ខាងចាប់ដៃ ម្ខាងចាប់ជើង ម្តាយពិតជាមានចិត្តអាណិតអាសូរកូនក៏បាន លែងទៅ ពេលនោះមហោសថក៏បានដឹង ហើយបង្ហាញនូវស្រីជាយក្ខនោះ ។

- **ទី៦ គោឡោ** ( បុរសឈ្មោះគោឡកាឡ ) មានបុរស និងស្ត្រីជាប្តីប្រពន្ធនឹងគ្នាបានធ្វើ ដំណើរទៅលេងស្រុក កំណើតខាងប្តីទៅដល់មាត់ស្ទឹងមួយមិនហ៊ានឆ្លងពេលនោះមានបុរសម្នាក់មកជួយចម្លង តែការចម្លងនោះយក ប្រពន្ធទៅមុនហើយក៏បង្ហួសទៅបុរសជាប្តីខឹងយ៉ាងខ្លាំង ហើយឆ្លងទៅទាន់ក៏ប្រកែកគ្នាដំណឹងនេះឮដល់មហោសថ មហោសថក៏បានដោះស្រាយបញ្ហានេះប្រកបដោយយុត្តិធម៌ ។

- **ទី៧ រថោ ( រទេះ )** ការដោះស្រាយទៅលើបញ្ហាការក្រឡាខ្លួនរបស់ព្រះឥន្ទ ទៅលួចរទេះ បុរសម្នាក់ ដើម្បី សាកល្បងប្រាជ្ញាព្រះមហោសថ។ ព្រះមហោសថបានដោះស្រាយ ប្រកបដោយ ភាពវាងវៃ និងត្រឹមត្រូវ ។

- **ទី៨ ទណ្ឌោ** ( កំណាត់ឈើ ) ព្រះរាជាបានល្បងប្រាជ្ញាមហោសថដោយយកកំណាត់ ឈើឈ្លូសយ៉ាងស្អាត ទៅឱ្យអ្នកស្រុកបាចីនគ្រាមទាយថាខាងណាចុងខាងណាគល់ អ្នកស្រុកពុំដឹង ក៏ទៅពិគ្រោះជាមួយសេដ្ឋី សេដ្ឋីក៏ បានហៅមហោសថមកសួរ ហើយមហោសថ ក៏បានពន្យល់ មនុស្សគ្រប់គ្នាឲ្យយល់ ដោយឲ្យយកសូត្រមកចងត្រង់ កណ្តាលកំណាត់ឈើ នោះទម្លាក់ទឹក ហើយមហោសថប្រាប់ថា ខាងដែលលិចទឹកមុនជាគល់ ខាងដែលលិចទឹក ក្រោយជាចុង ។

- **ទី៩ សីសំ ( ក្បាល )** ព្រះរាជាពិសោធបញ្ញាមហោសថ ដោយឱ្យយកក្បាល់ខ្មោចប្រុស មួយ ស្រីមួយឱ្យអ្នក ស្រុកបាចិនគ្រាមទាយអ្នកស្រុកមិនដឹងក៏ទៅសួរមហោសថ ពេលនោះ មហោសថ បានបកស្រាយថា លលាដ៍ក្បាល ដែលមានថ្នេរត្រង់ៗ ជាលលាដ៍ក្បាលមនុស្ស ប្រុសឯលលាដ៍ ក្បាល មានលក្ខណៈវៀចវិល ជាលលាដ៍ក្បាលមនុស្សស្រី។

**-ទី១០ អហិ (ពស់)**ព្រះរាជាបានបញ្ជូនពស់ញីឈ្មោល១គូទៅឲ្យអ្នកស្រុកបាចីនគ្រាមទស្សន៍ទាយ អ្នកស្រុក បាចិនគ្រាមមិនស្គាល់ថាណាមួយញីណាមួយឈ្មោល ក៏ទៅ ពិគ្រោះជាមួយ មហោសថ ពោធិសត្វក៏បានប្រាប់ថា ពស់ឈ្មោលក្បាលក្រាស់រាងក្រមឹប ភ្នែកធំ សង្វារធ្មេត អន្លាយៗ ឯពស់ញីក្បាលស្តើង រាងឆ្លឹម ភ្នែកតូច សង្វារធ្មេតកំបុតៗ ។

**- ទី១១ កុក្កដោ(មាន់)** ព្រះបាទវិទេហរាជបានឲ្យអ្នកស្រុកបាចិនគ្រាម បញ្ជូនឧសភ មាន សម្បុរសសុទ្ធមានស្នែងឮដ៏ជើងមានបួរលើក្បាល ស្រែករពេទ៍មួយថ្ងៃ៣កាលទៅឱ្យជាប្រញាប់។ អ្នកស្រុកមិនស្គាល់ ក៏ទៅពិគ្រោះជាមួយមហោសថ ព្រះមហោសថបានប្រាប់ថា ឱ្យយកមាន់ស ឈ្មោលដែលមានដុះផ្គាល់នាជើង ដុះសិរលើក្បាល រងាវ៣ដងក្នុង១ព្រឹកទៅថ្វាយ ។

**- ទី១២ មណិ (កែវមណី)** មានកែវមណីមួយដោតសូត្រចូលទៅ ហើយដាច់យកមិន បាន ព្រះរាជាបានបញ្ជូនទៅឱ្យអ្នកស្រុកបាចីនគ្រាមហូតចេញ ហើយបញ្ចូលសូត្រថ្មី អ្នកស្រុកគ្មាន វិធីដោះស្រាយក៏ទៅសួរព្រះមហោសថ មហោសថក៏បានប្រាប់ឱ្យយកកែវមណី លាបទឹកឃ្មុំ ត្រង់ រន្ធសងខាង ហើយត្របាញ់សូត្រថ្មីលាបទឹកឃ្មុំទៅដាក់បញ្ចូលបន្តិចទៅក្នុងរន្ធ ទើបឱ្យយកទៅ ដាក់ត្រង់រន្ធស្រមោចស្រមោចធុំក្លិនក៏ចូលមកហើយបានខាំទាញសូត្រ ចាស់ចេញ សូត្រថ្មីក៏ចូលទៅ ។

**- ទី១៣ វិជាននំ (ការប្រសូត្រ)** ព្រះរាជាបានបញ្ជូនគោឈ្មោល ពោះធំឱ្យអ្នកស្រុកបាចីនគ្រាមបង្កើតកូន គ្មានវិធីអ្នកស្រុកក៏ទៅសួរព្រះមហោសថ ពោធិសត្វក៏បានប្រាប់ឱ្យរកអ្នកមាន ថ្វីមាត់ ធ្វើជាយំស្រែកដើរតំរង់ទៅរាជវាំង ពេលនោះស្តេចក៏ហៅ សួរ បុរសនោះក៏ប្រាប់ថាឪពុក កើតកូនមិនរួចឱ្យព្រះអង្គជួយបង្កើត ស្តេចមានបន្ទូលថាមិន ដែលមានទេរើយ ! បុរសនោះក៏តបវិញថាម្តេចក៏ព្រះអង្គបញ្ជូនគោឈ្មោលឱ្យខ្ញុំម្ចាស់បង្កើតកូន ?

**- ទី១៤ ឱទនំ (បាយ)** ស្តេចបានប្រាប់ដល់អ្នកស្រុកបាចីនគ្រាមថា ចំអិនបាយប្រកបដោយ អង្គ៨ ដោយវៀរចាកអង្ករ ទឹក ឆ្នាំង ចង្រ្កាន ភ្លើង អុស មនុស្សប្រុសស្រី ហើយកុំដើរ យកទៅ តាមផ្លូវ អ្នកស្រុកបានទៅពិគ្រោះនឹងមហោសថ មហោសថក៏បានប្រាប់ឲ្យយកចុងអង្ករទឹក សន្សើម ភាជន៍ដីថ្មីមិនមែនជាឆ្នាំង ឱ្យចោះគល់ឈើតម្កល់ភាជន៍នោះ ហើយឱ្យយកភ្លើង រន្ទះ បង្កាត់ នឹងស្លឹកឈើ ឲ្យមនុស្សខ្ទើយ នាំយកទៅដើរក្បែរផ្លូវ ។

**-ទី១៥ វាលុកា(ដីខ្សាច់)** ស្តេចបង្គាប់ឱ្យអ្នកស្រុកបាចីនគ្រាមវេញខ្សែពួរដីខ្សាច់មួយ បញ្ជូន ទៅរាជវាំង ជនទាំងបានទៅសួរមហោសថ ព្រះមហោសថក៏បានឱ្យរកបុរសពីរនាក់ ចេះសម្តី ហើយបង្គាប់ថា អ្នកត្រូវចូលទៅក្រាបបង្គំព្រះរាជាថា សូមទ្រង់មេត្តាប្រោស ពួកអ្នកស្រុកពុំដឹង ពីទំហំខ្សែពួរនោះតូចឬធំទេ សូមព្រះអង្គកាត់ខ្សែពួរចាស់ប្រវែងមួយចំអាម ទូលបង្គំនឹងបានយក ធ្វើជាគម្រូ ស្តេចតបថា មិនធ្លាប់មានខ្សែពួរវេញពីដីខ្សាច់ពីកាលណាទេ បើគ្មានម្តេច ព្រះអង្គ ឱ្យអ្នកស្រុកបាចីនគ្រាមវេញខ្សែពួរខ្សាច់ដូចម្តេចកើត។

**- ទី១៦ តឡាកំ(ស្រះ)** ព្រះរាជាបានបង្គាប់ឱ្យអ្នកស្រុកបាចីនគ្រាមបញ្ជូនស្រះបោក្ខណី ទៅរាជវាំងដើម្បីក្រសាល អ្នកស្រុកគ្មានមធ្យោបាយក៏បានទៅសួរមហោសថពោធិសត្វក៏បានឱ្យ ហៅមនុស្សពីរបីនាក់ដែលមានថ្វីមាត់ កាន់ដំបង និងខ្សែពួរ ចុះទៅមុជទឹកស្រះលេង ឱ្យភ្នែក ក្រហម និងប្រលាក់ភក់ ហើយឡើងទៅទូលស្តេចថាស្រះដែលព្រះអង្គឱ្យខ្ញុំយកមក ថ្វាយនោះ បានផ្អើលដាច់ចូលទៅព្រៃវិញហើយ សូមព្រះអង្គប្រទានស្រះចាស់ឱ្យទូលបង្គំ យកទៅធ្វើជ្នាក់ ទាក់ស្រះនោះមកវិញផង។ ស្តេចថាមិនធ្លាប់មានស្រះនាំមកពីព្រៃទេ បើមិនមាន ម្តេចឱ្យអ្នក ស្រុកបាចីនគ្រាមបញ្ជូនស្រះបោក្ខណីមកថ្វាយដូចម្តេចកើត ។

- **ទី១៧ឧទ្យាន (សួនឧទ្យាន)** ព្រះរាជាត្រាស់បង្គាប់ឱ្យបញ្ជូនឧទ្យានថ្មីមានដើមឈើលាស់ខ្ចីទៅរាជវាំង អ្នកស្រុកក៏ទៅសួរ មហោសថ ពោធិសត្វបានហៅមនុស្សពីរបីនាក់ឱ្យ យកខ្សែព្យួរ និងដំបងដើរទៅរាជវាំងទូលព្រះរាជាថា ខ្ញុំនាំឧទ្យានដ៏ធំមកថ្វាយ ប៉ុន្តែឧទ្យាននោះធ្លាប់តែនៅក្នុងព្រៃ បានឃើញបុរីក៏ផ្អើលដាច់បោលចូលព្រៃវិញទៅ សូមព្រះអង្គប្រទានឧទ្យានចាស់ឱ្យទូលបង្គំ ដើម្បីយកទៅផ្សាំងជាធ្នាក់ ព្រះរាជាថាមិនធ្លាប់មានឧទ្យាននាំ មកពីព្រៃទេ អ្នកទាំងនោះថា បើគ្មានព្រះអង្គឱ្យបញ្ជូនឧទ្យានថ្មីម្ដេចកើត ។

- **ទី១៨ កទ្រភោ (សត្វលា)** អស្សតរព្រះរាជាបាក់ជើង ហើយបង្គាប់ឱ្យមហោសថយកអស្សតរ ដែលប្រសើរដូចអស្សតរស្ដេចឬប្រសើរជាងទៅថ្វាយ ពេលនោះមហោសថយក សត្វលាទៅថ្វាយ ដោយទូលថាអស្សតរដែលប្រសើរ គឺកើតចេញពីមេសេះអាជានេយ្យ និងបាជា សត្វលាដូច្នេះសូមព្រះអង្គទទួលយកសត្វលានេះចុះព្រះរាជាក៏យល់ព្រមថែមទាំង យកមហោសថ ធ្វើជារាជបុត្ររបស់ព្រះអង្គ ។

- **ទី១៩ មណិ (កែវមណី)** មានកែវមណីមួយនៅក្នុងសំបុកក្អែកលើដើមត្នោតក្បែរស្រះ បោក្ខណី ចាំងស្មើទៅក្នុងទឹកស្រះ ។ ព្រះរាជាឲ្យអាចារ្យសេនកៈយកចេញឲ្យបាន តែ អាចារ្យយក មិនបានទាល់តែសោះ ស្ដេចក្រុងមិថិលាសួរមហោសថថា ហៃបាឯងអាចឲ្យ យកកែវមណីនោះ បានឬទេ មហោសថទូលថាការនេះពុំធ្ងន់ធ្ងរទេ មហោសថបានបង្ហាញ ដោយឲ្យយកភាជន៍ទឹក មកដាក់ក្បែរដើមត្នោតនោះ ឃើញពន្លឺចាំងមកក្នុងភាជន៍នោះ ទើបក្រាបបង្គំទូលព្រះរាជាថាកែវ មណីនៅលើចុងត្នោតឯនោះទេ ។

លើសពីនេះទៅទៀត ក៏នៅមានការដេញដោលប្រស្នារវាងនាងភេរីបរិព្វាជិកាដែលជាទី រាប់អាននៃព្រះបាទចុល្លនី និងព្រះមហោសថ អំពីសញ្ញាក្នុងការល្បងប្រាជ្ញា ។

**បញ្ហាទី២** បញ្ហាបំពេញបញ្ញាបារមីជុំវិញបញ្ហាការធ្វើសង្គ្រាម។ ក្នុងការធ្វើសង្គ្រាមជាមួយ ព្រះបាទចុល្លនីក្សត្រនគរឧត្តរបញ្ចាល ព្រះមហោសថបានប្រើបញ្ញាក្នុងដោះស្រាយរាល់ឧបសគ្គ ដែលកើតឡើងចំពោះមុខប្រកបដោយសន្តិវិធី។ ព្រះមហោសថបានប្រើប្រាស់បញ្ញាបូកផ្សំជាមួយយុទ្ធវិធីក្នុងការធ្វើសង្គ្រាម ដើម្បីទទួលបានជោគជ័យលើសត្រូវ ហើយបានប្រើគ្រប់វិធីដូចជា សង់កំពែង ជីកស្រះជុំវិញ ចិញ្ចឹមក្រពើ មានទ្វារតូចធំ ប្រកបដោយ អាវុធយុទ្ធភ័ណ្ឌ ពិសេស បានបញ្ជូនសេកទៅស៊ើបការណ៍ថែមទៀតផង ។

### គ. តួនាទីអប់រំនៃរឿងមហោសថជាតក

តាមរយៈសាច់រឿងទាំងមូលអ្នកនិពន្ធបានបង្ហាញពីគោលគំនិត(គំនិតអប់រំ)សំខាន់ៗដូចតទៅៈ

- អប់រំមនុស្សទូទៅឱ្យចេះកសាងសមិទ្ធផលផ្សេងៗ ដើម្បីជាប្រយោជន៍ដល់គ្រួសារ សហគមន៍ និងសង្គមជាតិទាំងមូល ។ ជាក់ស្ដែងយើងឃើញថា តួអង្គព្រះមហោសថនៅ ពេលមាន អាយុ៧ឆ្នាំ ក៏មានគំនិតរៃអង្គាសប្រាក់ដើម្បីកសាង នូវសាលាជាច្រើនទុកសម្រាប់ ជួយដល់ទុគ៌ត ជន ស្ត្រីមានផ្ទៃពោះអាណាថា ពួកឈ្មួញ និងព្រាហ្មណ៍ដទៃទៀត ។
- អប់រំមនុស្សទូទៅឲ្យចេះសាមគ្គីគ្នា រួបរួមគ្នា ក្នុងការដោះស្រាយបញ្ហាដែលកើតមាន ចំពោះមុខ ដូចជាពួកអ្នកស្រុកបាចីនគ្រាម ពេលជួបបញ្ហាដោះស្រាយប្រស្នាពុំរួច ក៏ពិគ្រោះ ផ្លាស់ ប្ដូរយោបល់គ្នា ដើម្បីរកដំណោះស្រាយ ។
- អប់រំឱ្យយើងឱ្យចេះប្រើប្រាស់ប្រាជ្ញា សម្រាប់យកទៅដោះស្រាយបញ្ហាផ្សេងៗ ដែលជួបប្រទះនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ។ ឧទាហរណ៍ ព្រះមហោសថ បានយកបញ្ញា ទៅដោះ ស្រាយប្រស្នាទាំង១៩ នៅក្នុងដំណើររឿង ។

- អប់រំមនុស្សទូទៅឱ្យចេះស្រឡាញ់គ្នា កុំមានការច្រណែន ឈ្នានីសគ្នាកុំតាមព្យាបាទគ្នា ឱ្យចេះលើកតម្កើងអ្នកមានចំណេះដឹង ចេះរស់នៅជាមួយគ្នាប្រកបដោយសេចក្ដីសុខសន្តិភាព។
- អប់រំអ្នកដឹកនាំទូទៅ ឱ្យចេះស្រឡាញ់សន្តិភាព ជៀសវាងការបង្កសង្គ្រាម ដែលជាហេតុ នាំមកនូវក្ដីវិនាសអន្តរាយចំពោះប្រទេសជាតិ។ តាមរយៈរឿងមហោសថ ព្រះបាទចុល្លនី ព្រហ្មទត្ត បានបង្កសង្គ្រាម ទីបំផុតត្រូវបាត់បង់ធនធានមនុស្ស ចំណែកឯ ព្រះបាទវិទេហរាជ ជាស្ដេចប្រកបដោយទសពិតរាជធម៌ស្រឡាញ់សន្តិភាពនាំឱ្យនគរមានភាពថ្កុំថ្កើងប្រជារាស្ត្រសម្បូរសប្បាយ ។
- អប់រំមនុស្សទូទៅឱ្យស្រឡាញ់យុត្តិធម៌ មិនលំអៀង ភាពទៀងត្រង់ ក្នុងការវិនិច្ឆ័យ ឬ ការកាត់ក្ដី។
- អប់រំមនុស្ស កុំឲ្យមានចិត្តលោភលន់ ចង់បានទ្រព្យសម្បត្តិរបស់អ្នកដទៃ។
- អប់រំមនុស្សឲ្យចេះគិតពិចារណាឲ្យបានត្រឹមត្រូវមិនត្រូវល្មោភកាមតណ្ហាតាមការស្រេក ឃ្លាននោះទេ ដូចជាព្រះបាទវិទេហរាជដែលលង់នឹងសម្រស់នាងបញ្ចាលចន្ទី ដែលធ្វើឲ្យខ្លួនស្ទើរ តែបាត់បង់ជីវិត ។

### ៧.៣.៦. រឿងភូរិទត្តជាតក

**ក. ប្រធានរឿង**

តាមរយៈការសិក្សារឿងនេះ បានបង្ហាញអ្នកសិក្សាឱ្យស្វែងយល់អំពីការបំពេញបារមីរបស់ព្រះពោធិសត្វពេល"សីលបារមី"។ ភូរិទត្តជាតកនេះគឺ លោកចង់ឆ្លុះបញ្ចាំងឱ្យយើងបានយល់អំពីគុណតម្លៃរបស់សីលបារមីប្រៀបបានជាមេសន្តិភាពសម្រាប់មនុស្សជាតិទូទៅ ។

**ខ. មូលបញ្ហារឿង**

ជុំវិញប្រធានរឿងនេះ យើងអាចកំណត់បញ្ហាជាច្រើន ដែលស្ថិតនៅជុំវិញការកសាងនូវ សីលបារមីរបស់ព្រះពោធិសត្វ បញ្ហាទាំងនោះរួមមាន ៖

- ការបំពេញនូវទានបារមីរបស់ព្រះពោធិសត្វ
- បញ្ហាទ្រឹស្ដីកម្មផល(អំពើបាបកម្មរបស់នាយព្រហ្មណ៍នេសាទ)
- អណ្ដាតជាអាថកន្លងបានសុខទុក្ខផងពីព្រោះអណ្ដាត
- ការបំពេញបារមីរបស់ព្រះពោធិសត្វ

**បញ្ហាទី១ ៖ ការបំពេញនូវទានបារមីរបស់ព្រះពោធិសត្វ**

តាមរយៈការសិក្សាវិភាគស្នាដៃរឿងនេះមក យើងដឹងថាបញ្ហាដែលកើតមានដំបូងឡើង នោះបណ្ដាលអំពីការបំពេញបារមី"សីល"នេះឯង ដែលព្រះពោធិសត្វទ្រង់បានបំពេញ និងអនុវត្តយ៉ាងខ្ជាប់ខ្ជួនបំផុត។ យើងដឹងស្រាប់មកហើយថាភូរិទត្តជាបុគ្គលមួយរូបមាន សមត្ថ ភាពខាងប្រាជ្ញា អាចំកំបាំង ហេតុទៅដល់ឋានព្រះឥន្ទ្រ ដោះ ប្រស្នានានាផងទៀត ។ ដោយព្រះអង្គឈ្វេងយល់ឃើញអំពីសីលបារមីនេះមានសារៈសំខាន់ ទើបធ្វើឱ្យព្រះអង្គលាព្រះមាតាបិតាឋានកុជង្គនាគមកធ្វើសីលនៅឋានមនុស្សលោក។[30] តមកព្រះអង្គលាព្រះមាតាបិតា ចេញទៅរក្សាឧបោសថសីលនៅឋានមនុស្សលោក នៅនាដំបូកក្រោមដើមជ្រៃជិតស្ទឹងយមុនា ព្រះអង្គតាំងអធិដ្ឋានបារមី ផ្ដោតព្រះទ័យចំពោះឧបោសថសីល ... ។

[30] រឿងភូរិទត្តជាតក ទំ.១៧៧-១៧៨

សរុបខ្លី បញ្ហាការបំពេញបារមីនេះ វាជាប្រកពដំបូងដែលធ្វើឲ្យរឿងបង្កជាបញ្ហាចំពោះ តួអង្គព្រះពោធិសត្វ ក្នុងការរក្សានូវឧបោសថសីល សម្រាប់ការស្វែងរកសេចក្ដីសុខផ្ទាល់ខ្លួន និងមនុស្សជាតិ ។

ដូចនេះ សេចក្ដីសុខកើតមានចំពោះបុគ្គលបាន លុះត្រាបុគ្គលនោះប្រព្រឹត្តផងដែរ គ្មានសេចក្ដីស្ងប់នោះ ។

**បញ្ហាទី២ ៖ បញ្ហាទ្រឹស្ដីកម្មផល(អំពើបាបកម្មរបស់នាយព្រាហ្មណ៍នេសាទ)**

មុនឆ្លងចូលដល់ការបកស្រាយបញ្ហានេះ យើងគម្បីស្វែងយល់ន័យរបស់គុណធម៌ និងការគប់មិត្តសិន ។

គុណធម៌ តាមវចនានុក្រមជួន ណាត លោកឱ្យន័យថា[31] ៖ ធម៌ដែលមានដំណើរចម្រើន សេចក្ដីសុខទុក្ខទៅតាមជាន់ថ្នាក់ បានខាងអំពើល្អអាក្រក់ គឺបុណ្យបាបដែលបុគ្គលធ្វើ។

ការគប់មិត្តៈ ដំណើររាប់រកគ្នា ចងសម្ពន្ធជាមួយគ្នា ។ យើងដឹងស្រាប់មកហើយ មនុស្សនៅក្នុងសង្គម មិនមានបុគ្គលណាមួយអាចរស់ឯកឯងនោះទេ ។ ម្ល៉ោះហើយគេត្រូវតែមានទំនាក់ទំនងជាមួយគ្នា ក្នុងជីវភាពរស់នៅនេះជាចាំបាច់ ហៅថា ការសេពគប់មិត្ត។ ប៉ុន្តែក្នុងទំនាក់ទំនងនេះ គេត្រូវពិនិត្យលើចិត្តសាស្ត្ររបស់បុគ្គលនោះ ដែរ មុនឈានចូលដល់ការរាប់អាននោះ។ តាមរយៈសៀវភៅស្រីហិតោបទេស[32] ដែលជាស្នាដៃ រៀបរៀងរបស់អាចារ្យវិរិយបណ្ឌិតោ ប៉ាង ខាត់ នៅត្រង់អារម្ភកថាលោកក៏បានបញ្ជ្រាបអំពីគម្ពីរ បញ្ចសស្ត្រៈ ក្នុងនោះដែរលោកក៏បានបង្ហាញអំពីការគប់មិត្តដែរ ។ ចំណែកសៀវភៅគតិលោក របស់អ្នកនិពន្ធសុត្តន្តប្រីជាឥន្ទ លោកបានពង្រីកគំនិតលោកិយ៍សច្ចៈមនុស្សនិយម(អក្សរសិល្ប៍ ទំនើប) បង្ហាញប្រាប់ត្រង់អំពីការគប់មិត្តនេះដែរ[33]។ មិនត្រឹមតែប៉ុណ្ណោះ ការសិក្សារឿងភូរិទត្តជាតកនេះ លោកបង្ហាញឲ្យយើងដឹងអំពីឫសគល់នៃការចងសម្ពន្ធមិត្តនេះដែរដូចមានឃ្លាលើកឡើង៖

.....[34]ព្រះពោធិសត្វ កាលបានជ្រាបថា ព្រានឃើញព្រះអង្គហើយក៏នឹកថា "សេចក្ដីអន្តរាយនឹងមាន បើដូច្នេះ គួរតែអាត្មាអញនាំព្រាននេះទៅបំប៉នដោយគ្រឿងសក្ការៈ និងសេចក្ដីរាប់អាន ឯឋានភុជង្គនាគ .... សោមទត្តកូនអើយយើងនឹងបានកែវមណីវិញហើយ កូនសួរថា ធ្វើម្ដេចនឹងបាន? យើងត្រូវបង្ហាញផ្លូវភូរិទត្តដល់អាលម្ពាយន៍នេះណា ... ទេឪ! ពុំត្រូវទេ ខុសមនុស្សធម៌ឆ្ងាយ ណាស់ ។ ... កូនតបថាៈ គិតតែខាងបានប៉ុណ្ណោះ មិនល្អទេឪ! ព្រោះថាភូរិទត្តបានធ្វើសក្ការៈបូជា ដល់ឪ ឱ្យទីនៅសំណាក់អាស្រ័យយ៉ានេះ ឈ្មោះថាកល្យាណមិត្តប្រពៃ ... ។ បើយើងពិនិត្យតាម សង្គមជាក់ស្ដែងវិញគេតែងតែឮសូរតាមបណ្ដាញព័ត៌មាននានា អំពីការចាញ់បោកមិត្តភ័ក្តិជាដើម មិនខុសប្លែកអំពីអក្សរសិល្ប៍ប៉ុន្មានឡើយ ព្រោះថាអក្សរសិល្ប៍ជាកញ្ចក់ឆ្លុះបញ្ចាំងអំពីតថភាពនៃ សង្គម អក្សរសិល្ប៍បែបណា សង្គមយ៉ាងនោះដែរ ។

ដូចនេះយើងឃើញថា បញ្ហាអក្សរសិល្ប៍ជាបញ្ហារបស់មនុស្សក្នុងសង្គម ។ ផ្អែកតាមការ រៀបរាប់ត្រួសៗ មកនេះ សបញ្ជាក់ឱ្យឃើញថាការសេពគប់មិត្ត វាតែងផ្សារភ្ជាប់អំពីគុណធម៌។

**បញ្ហាទី៣ ៖ អណ្ដាតជាអាទិកន្លងបានសុខទុក្ខផងពីព្រោះអណ្ដាត**

តាមរយៈរឿងភូរិទត្តជាតកនេះ លោកបានបង្ហាញអំពីហឹង្សា ក្នុងគ្រួសាររបស់នាយ ព្រាហ្មណ៍នេសាទ និងប្រពន្ធ ។ ក្រោយពេលដែលនាយព្រាហ្មណ៍នេសាទ វិលត្រឡប់ពីឋាន ភុជង្គនាគកុហកព្រះពោធិសត្វថា មកបួសនៅ

---

[31] ជួន ណាត "វចនានុក្រមខ្មែរ" ទំ. ៩៩

[32] វិរិយបណ្ឌិតោ ប៉ាង ខាត់ "ស្រីហិតោបទេស"

[33] ឧកញ្ញា សុត្តន្ត ប្រីជាឥន្ទ "សៀវភៅគតិលោក"

[34] រឿង ភូរិទត្តជាតក ទំ.១៨៣

ឯឋានមនុស្សលោកនោះ ពេលធ្វើដំណើរទៅដល់ ផ្ទះវិញនោះ នាយព្រាហ្មណ៍នេសាទបានចូលទៅរកកន្លែងសម្រាក ព្រោះអស់កម្លាំងពេក ។ ប្រពន្ធ គ្រេកអរខ្លាំងណាស់ បានសួរកូនចំពោះការបាត់ខ្លួនមួយរយៈនោះ កូនសោមទត្ត កុមារជាមនុស្ស ល្អ មិនកុហកបានរៀបរាប់ប្រាប់អ្នកម្ដាយទៅតាមដំណើររឿងទាំងអស់ នៅពេលបានសេចក្ដីជ្រាប ហើយ នាងប្រពន្ធទៅយកដំបងវាយសំពងប្ដីកំពុងសម្រាន្តនោះ ។ នាយព្រាហ្មណ៍នេសាទរត់ ចោលភូមិស្រុកពីនោក់ ឪពុកកូន ។ ... កូនអើយ អ្នកនាំគ្នាទៅណាបាត់យូរម្ល៉េះ ? ប្រាប់ថាៈ ទៅឋានកុជង្គនាគ។ សួរថាៈ បានមាសពេជ្រកែវ មណីមកទេ? ប្រាប់ថាៈ ឪពុកពុំព្រមយកមកទេ ព្រោះគាត់ថានឹងបួស បានខ្លះមកបាត់អស់ទៅ ។ ភរិយាឮតែ ប៉ុណ្ណោះស្ទុះទៅសំពងប្ដី ....[35] ។

ដូចនេះយើងឃើញថា មនុស្សយើងមុននឹងនិយាយត្រូវចេះ គិតពិចារណាឱ្យបានត្រឹមត្រូវ សិនសមតាម សុភាសិតបុរាណ បានពោលថាអណ្ដាតជាអាថកន្លងបានសុខទុក្ខ ផងពីព្រោះអណ្ដាត។

**បញ្ហាទី៤ ៖ ការបំពេញបារមីរបស់ព្រះពោធិសត្វ**

គ្រប់អក្សរសិល្ប៍បុរាណផ្នែកពុទ្ធនិយម ទោះបីអ្នកនិពន្ធនិម្មិតបង្កើតស្នាដៃរបស់ខ្លួន លើក និយាយអំពីរឿងរ៉ាវ ទាក់ទងជាមួយសាសនាក៏ដោយ ប៉ុន្តែរឿងនោះបានស្ដែងចេញអំពីជីវភាពរស់ នៅរបស់មនុស្សនៅក្នុងសង្គម ។ យើងដឹងស្រាប់មកហើយថា កអក្សរសិល្ប៍បុរាណ អ្នកនិពន្ធ បញ្ជ្របពីអច្ឆរិយៈហួសហេតុពីការពិតមែន តែក្នុងគោល បំណងឱ្យអ្នកអានសប្បាយរីករាយប៉ុណ្ណោះ។ អំពីអច្ឆរិយៈនេះ ក៏អ្នកនិពន្ធមិនភ្លេចអំពីលោកិយសច្ចៈនៅក្នុងអក្សរ សិល្ប៍ដែរ។ តាមរយៈអក្សរសិល្ប៍កបុរាណ ភូរិទត្តជាតកនេះ លោកបានបញ្ចូលចង្អុលប្រាប់អំពីលោកិយសច្ចៈ ត្រង់ៗ ដល់អ្នកសិក្សាសម្រាប់ការត្រិះរិះពិចារណា ។ តាមឯកសារបង្រៀនគរុកោសល្យ យើង ឃើញគំនិតរបស់អ្នកប្រាជ្ញម៉ាស្លូ លោកបានឲ្យតម្លៃសំខាន់ទៅលើមនុស្សនិយម ហៅថាតម្រូវការ សរីរៈ ឬតម្រូវការមូលដ្ឋាន ក្នុងនៅលោកក៏បាន និយាយអំពីភាពចាំបាច់របស់មនុស្សមុនគេគឺ ការ ហូបចុក ស្នាក់នៅ សំលៀកបំពាក់ ទ្រព្យសម្បត្តិ .... ។ ដោយផ្អែក លើទ្រឹស្ដីនេះ យើងអាចទាញ តាមលក្ខណៈលោកិយ៍សច្ចៈ រឿងភូរិទត្តជាតក ដូចមានបង្ហាញតាមរយៈសកម្មភាព របស់តួអង្គ ខាងក្រោម ៖

**+ តួអង្គនាយព្រាហ្មណ៍នេសាទៈ** ដោយមានភាពចំណង់ចង់បាន ទ្រព្យសម្បត្តិរបស់គាត់ នេះហើយ ទើបធ្វើ ឱ្យនាយព្រាហ្មណ៍នេសាទភ្លេចអស់នូវសីលធម៌ គុណធម៌របស់ខ្លួនភ្លេចអស់ នូវការជួយសង្គ្រោះពីជនដទៃ សូម្បីតែ ពោធិសត្វដែលធ្លាប់ជួយសង្គ្រោះ ផ្ដល់ការឱ្យស្នាក់នៅ អាស្រ័យទំនុកបំរុងឱ្យមាស ប្រាក់ ទ្រព្យសម្បត្តិ កែវមណីនោះ ដោយការខ្វះខាតក្រីក្រលើតម្រូវការសរីរៈនេះហើយ ទើបមករស់នៅក្នុងព្រៃរសាត់អណ្ដែតពីនាក់ឪពុកកូន ដោយ កំសត់វេទនា ព្រោះតែប្រពន្ធដេញវាយមិនឱ្យចូលផ្ទះ ។ តាមរយៈរឿងនេះទៀតសោត លោកឆ្លុះបញ្ចាំងឱ្យយើង ដឹង ការបាត់បង់គុណធម៌នេះ បណ្ដាលមកពីកត្តាខាងក្រោមនេះ ៖

- ភាពក្រីក្រ សេចក្ដីទុក្ខលំបាកវេទនា
- ភាពអនាថា រស់នៅដោយគ្មានអ្នកទីពឹង
- ភាពអវិជ្ជា តណ្ហា លោភៈ មោហៈ ទោសៈចាក់ស្រេះ
- សេចក្ដីបម្រើខាងអំណាច ការពារកិត្តិយស បុណ្យសក្តិ
- ភាពអួតអាង បម្រើមហិចតា មិនចេះចប់មិនចេះហើយ

[35] រឿងភូរិទត្តជាតក ទំ.១៨១

– បាត់បង់មនសិកា សីលបារមី ជាដើម

**+តាមរយៈតួអង្គហ្មពស់ (ព្រាហ្មអាលម្ពាយន៍)**

ព្រាហ្មអាលម្ពាយន៍ ក្រោយពេលជួបជាមួយព្រាហ្មណ៍នេសាទ ហើយគេទាំងពីរនេះមាន ទំនាក់ទំនងជាមួយគ្នាអំពីបញ្ហាត្បូងកែវមណីនោះ។នាយព្រាហ្មណ៍នេសាទបានណែនាំព្រាហ្មណ៍ឱ្យទៅជួបព្រះពោធិសត្វ..។ ព្រាហ្មណ៍អាលម្ពាយន៍ ជាមនុស្សលោភលន់ចង់មានបានហួសពីតម្រូវការ។ ដោយភាពអវិជ្ជា លោភៈ ទោសៈ មោហៈ ធ្វើឱ្យព្រាហ្មណ៍អាលម្ពាយន៍ ភ្លេច អស់គុណធម៌ សីលធម៌ ពុំស្គាល់គុណទោស បុណ្យបាប គេដើរបៀតបៀនអ្នកដទៃឱ្យរងទុក្ខវេទនា ក្រោមកណ្តាប់ដៃដ៏កខ្វក់ប្រកបដោយបាបមិត្រ ធ្វើឱ្យព្រះពោធិសត្វភូរិទត្ត រងទុក្ខលំបាកហួរ ឈាម ដើរសម្តែងសិល្បៈគ្រប់ទីកន្លែងទាំងអស់ តាមការបញ្ជារបស់ព្រាហ្មណ៍អាលម្ពាយន៍ ។

សរុបន័យមកឃើញថា លោកិយ៍សច្ចៈតាមរយៈរឿងនេះ ពិតជាបានស្តែងអំពីតម្រូវការរស់ នៅរបស់មនុស្សក្នុងសង្គម ជាពិសេសបង្ហាញអំពីចរិតលក្ខណៈចិត្តសាស្ត្ររបស់មនុស្ស ។

**គ. តួនាទីអប់រំនៃរឿងភូរិទត្តជាតក**

រឿងភូរិទត្តជាតក ជាប្រភេទអក្សរសិល្ប៍បុរាណផ្នែកពុទ្ធនិយម ដែលបង្ហាញអំពីរឿងរ៉ាវផ្សេងៗ របស់តួអង្គព្រះពោធិសត្វ ទាក់ទងជុំវិញការបំពេញសីលបារមីរបស់ព្រះអង្គ នៅជាតិទីប្រាំមួយ។ ឆ្លងតាមរយៈការសិក្សារឿងនេះមក ក្រុមយើងខ្ញុំអាចទាញជាឧត្តមគតិរឿងនេះ គឺអ្នក និពន្ធលោកចង់អប់រំយើងដូចតទៅ ៖

– អប់រំមនុស្សយើងកុំឱ្យប្រកាន់បក្សពួក រើសអើងប្រកាន់វណ្ណៈ
– អប់រំមនុស្សឱ្យចេះស្រឡាញ់គ្នា ចេះជួយសង្គ្រោះ
– អប់រំមនុស្សឱ្យចេះធ្វើទាន រក្សាសីលបារមី
– អប់រំមនុស្សឱ្យចេះអំណត់ព្យាយាម អត់ធ្មត់ ខន្តី មិនក្រោធខឹង
– អប់រំមនុស្សឱ្យប្រើវិធីដោះស្រាយសមស្រប
– អប់រំមនុស្សកុំឱ្យប្រើអំពើហិង្សា
– អប់រំមនុស្សកុំឱ្យដើរបៀតបៀនសេចក្តីសុខអ្នកដទៃ
– អប់រំកុំឱ្យមនុស្សភ្លេចគុណអ្នកដទៃ
– បណ្តុះស្មារតីមនុស្សឱ្យចេះសេពគប់មិត្ត
– អប់រំមាតាបិតាត្រូវមានព្រហ្មវិហារធម៌
– អប់រំមនុស្សឱ្យជឿលើកម្មផល
– អប់រំមនុស្សឱ្យធ្វើអំពើល្អទាំងកាយ វិចារ

សរុបសេចក្តីមកយើងឃើញថា អក្សរសិល្ប៍ខ្មែររឿងភូរិទត្តជាតកនេះ ឆ្លុះបញ្ចាំងឲ្យឃើញ អំពីសមត្ថភាពទេពកោសល្យរបស់អ្នកប្រាជ្ញ កាលពីសម័យបុរាណ បង្កប់នូវទស្សនៈវិស័យ ចក្ខុវិស័យយ៉ាងវិសេសវិសាលសម្រាប់សង្គមជាតិ ។

### ៧.៣.៧. រឿងចន្ទកុមារជាតក

#### ក. ប្រធានរឿង

ក្នុងរឿងចន្ទកុមារនេះគឺ"ការបំពេញបារមី(ខន្តីបារមី)របស់ព្រះពោធិសត្វ"។រឿង "ចន្ទកុមារជាតក"ជារឿងនៃជាតិទី៧ ក្នុងជាតិចុងក្រោយទាំង១០របស់ព្រះពុទ្ធសមណគោតមដែលបានរៀបរាប់ពីដំណើរជីវិតរបស់ ព្រះពោធិសត្វ ក្នុងការកសាង និងសន្សំបារមីដើម្បីការត្រាស់ដឹង។

#### ខ. មូលបញ្ហារឿង

មូលបញ្ហាក្នុងរឿងនេះគឺ និយាយពីទំនាស់ដែលកើតចេញពីការគុំគួន តាមព្យាបាទព្រះចន្ទកុមាររបស់កណ្ឌហាលព្រាហ្មណ៍។

នៅក្នុងដំណើររឿងនេះ បានរៀបរាប់ពីការចង់បានរបស់ព្រះបាទឯករាជាព្រះបិតារបស់ចន្ទកុមារដែលចង់ទៅកើតនៅស្ថានសួគ៌ទើបប្រឹក្សាជាមួយកណ្ឌហាលព្រាហ្មណ៍។ កណ្ឌហាលព្រាហ្មណ៍ជាមនុស្សអាក្រក់អន្ធពាលដែលមានចិត្តគុំគួនជាមួយព្រះចន្ទកុមារបរមពោធិសត្វដោយសារទំនាស់កន្លងមក គឺថាកណ្ឌហាលព្រាហ្មណ៍នេះពីមុនត្រូវព្រះរាជាតែងតាំងជាអ្នកទទួលកាត់ក្តីក្នុងរឿងវិវាទឲ្យប្រជានុរាស្រ្ត ដោយចិត្តលោភព្រាហ្មណ៍នេះតែងតែទទួលសំណូកសូកប៉ាន់ពីគេ ហើយកាត់ក្តីមួលបង្កាច់ឱ្យអាក្រក់ទៅជាល្អ សជាខ្មៅ ម្ចាស់ទៅជាចោរ ឯចោរទៅជាម្ចាស់ទៅវិញ។ ក្រោយមកប្រជារាស្ត្រស្លូតត្រង់ដែលចាញ់ក្តីបានទៅប្តឹងព្រះចន្ទកុមារ ទ្រង់ក៏សើរើកាត់ក្តីជាថ្មី ដោយយុត្តិធម៌។ ព្រះរាជាទ្រង់ជ្រាបរឿងនេះ ក៏ដកសេចក្តីទុកចិត្តពីកណ្ឌហាលព្រាហ្មណ៍ ដែលធ្វើឱ្យព្រាហ្មណ៍ទទួលការខាតបង់លាភសក្ការៈ។ ការណ៍នេះហើយដែលនាំឱ្យកណ្ឌហាលព្រាហ្មណ៍អន្ធពាលមានចិត្តគុំគួនខ្លាំងជាមួយចន្ទកុមារ ។ ដោយសារបានឱកាសសម្រាប់ការសងសឹកជាមួយចន្ទកុមារ កណ្ឌហាលព្រាហ្មណ៍បានទូលព្រះរាជាទាំង ទោសាគតិថា"សូមឱ្យព្រះអង្គធ្វើទានដ៏ក្រៃលែងគឺសម្លាប់នូវបុគ្គលដែលមិនគួរសម្លាប់"។ ការទូលបែបនេះគឺដើម្បីឲ្យព្រះរាជាសម្លាប់ព្រះចន្ទកុមារតែម្តង។

នៅក្នុងរឿង "ចន្ទកុមារ" គេសង្កេតឃើញថា មានទំនាស់តូចៗជាច្រើនដែលជាបច្ច័យឈានទៅដល់ទំនាស់ធំរួចក៏ឈានដល់ដំណោះស្រាយជាចុងក្រោយ។ ទំនាស់ទាំងអស់បានផ្ទួចឡើងជារឿងតាមដំណាក់ៗដូចតទៅៈ

- **ទី១៖ ការចងគំនុំរបស់កណ្ឌហាលព្រាហ្មណ៍ចំពោះព្រះចន្ទកុមារ**

ទំនាស់ផ្តើមចេញដំបូងគឺដោយសារតែកណ្ឌហាលព្រាហ្មណ៍ជាបុគ្គលមានចិត្តលោភ ប្រព្រឹត្តទុច្ចរិតស៊ីសំណូករួចវិនិច្ឆ័យដោយអយុត្តិធម៌។ ដោយមូលហេតុនេះ ធ្វើឲ្យអ្នកចាញ់ក្តីមានសេចក្តីក្តៅក្រហាយ និងបានទូលរឿងរ៉ាវដល់ព្រះចន្ទកុមារ ទ្រង់ក៏វិនិច្ឆ័យរឿងក្តីសារជាថ្មី។ កណ្ឌហាល ត្រូវបាត់បង់មុខតំណែង និងលាភសក្ការៈ ក៏ចេះតែមានចិត្តគុំគួនគួចចង់សងសឹកនឹងព្រះចន្ទកុមារជានិច្ច។

ឧទាហរណ៍៖ "កណ្ឌហាលព្រាហ្មណ៍នោះកាន់តំណែងខាងការវិនិច្ឆ័យផង គាត់តែងស៊ីសំណូកធ្វើម្ចាស់ឱ្យមិនមែនជាម្ចាស់វិញ........ផលអាក្រក់របស់កណ្ឌហាលព្រាហ្មណ៍ក៏ដាច់រលត់ទៅ បានជាព្រាហ្មណ៍កើតក្តីមួម៉ៅគិតផ្តន្ទាព្រះចន្ទកុមារ"។ (សង្ខេបទសជាតក ទំ.១៩៣-១៩៤)

- **ទី២៖ បញ្ហាការសុបិនរបស់ព្រះបាទឯករាជ**

ព្រះបាទឯករាជទ្រង់សុបិននិមិត្តឃើញឋានត្រៃត្រឹង្ស ក៏មានព្រះទ័យចង់ទៅកើតសោយសុខនាស្ថាននោះ។ ព្រះអង្គទ្រង់ទៅពិភាក្សាជាមួយកណ្ឌហាលព្រាហ្មណ៍ ពីរឿងថា តើត្រូវធ្វើយ៉ាងណាដើម្បីបានទៅកើតនៅស្ថានសួគ៌។

ជាឱកាសល្អសម្រាប់ការសងសឹក កណ្ឌហាលព្រាហ្មណ៍ដែលជាមនុស្សអន្ធពាលឥតដឹងការណ៍អ្វីសោះ ក៏ទូលថ្វាយព្រះបាទឯករាជដោយមោហៈនិងទោសៈឱ្យទ្រង់ធ្វើនូវទានក៏ក្រៃលែងគឺការសម្លាប់នូវបុគ្គលដែលមិនគួរសម្លាប់។ ការទូលបែបនេះ កណ្ឌហាលព្រាហ្មណ៍មានគោលបំណងធំមួយគត់ គឺដើម្បីឱ្យព្រះរាជាសម្លាប់ព្រះ ចន្ទកុមារ។

ឧទាហរណ៍នៅក្នុងរឿង៖ "ថ្ងៃមួយទ្រង់សុបិននិមិត្តថាៈ បានទៅឃើញឋានត្រៃត្រឹង្ស........ទើបសួរកណ្ឌហាលព្រាហ្មណ៍ថា ខ្ញុំត្រូវធ្វើបុណ្យដូចម្ដេចដើម្បីនឹងបានទៅកើតឯស្ថានត្រៃត្រឹង្ស?" (សង្ខេបទសជាតក ទំ.១៩៤-១៩៥) "ព្រាហ្មណ៍ក្រាបបង្គំទូលថាៈ សូមទ្រង់ព្រះមេត្តាប្រោស ជនទាំងឡាយឲ្យទានដ៏ក្រៃលែង សម្លាប់បុគ្គលដែលមិនគួរសម្លាប់ទើបបានទៅកើតនៅឋានសួគ៌"។ (សង្ខេបទសជាតក ទំ.១៩៥)

- **ទី៣៖ បញ្ហាការបូជាយញ្ញរបស់ព្រះបាទឯករាជ**

ដោយសារជាមនុស្សល្ងង់អាប់ប្រាជ្ញា ព្រះបាទឯករាជក៏ទទួលជឿតាមពាក្យមុសាផ្ដេសផ្ដាសប្រកបដោយគំនិតយ៉ាងអាក្រក់របស់កណ្ឌហាលព្រាហ្មណ៍ ប្រៀបដូចជាមនុស្សដែលវង្វេងផ្លូវមួយសប្ដាហ៍ទៅសួររកផ្លូវចំមនុស្សដែលវង្វេងផ្លូវកន្លះខែដូច្នោះ។ ដើម្បីបានទៅកើតនាស្ថានត្រៃត្រឹង្ស ព្រះអង្គសុខចិត្តបញ្ជាឲ្យគេសម្លាប់ បុត្រ មហេសី សេដ្ឋី គោឧសភរាជ សេះជា អាជានេយ្យ ដំរីរាជ គឺចំនួន៤ៗក្នុងមួយមុខ។ ដំណាក់កាលនេះព្រះចន្ទកុមារកំពុងជួបបញ្ហាព្រោះនឹងត្រូវគេយកទៅបូជាយញ្ញជាមួយមនុស្ស និងសត្វជាច្រើនទៀត។ ដំណើររឿងកាន់តែតានតឹងឡើងជាលំដាប់។ ព្រះរាជកុមារព្រះចន្ទកុមារទ្រង់ព្យាយាមដោះស្រាយបញ្ហាដែលកើតឡើងចំពោះមុខដោយចិត្តខន្តី។ ព្រះចន្ទកុមារបានទូលអង្វរ ដល់ព្រះរាជាជាបិតាដោយសុខចិត្តធ្វើជាទាសៈរបស់កណ្ឌហាលព្រាហ្មណ៍ ឬត្រូវនិរទេសពីនគរ ទ្រង់សុខចិត្តដើរ សុំទានគេចិញ្ចឹមជីវិត។ ក្នុងនាមជាមហាឧបរាជដែលមានអំណាចសុខចិត្តបន្ទាបខ្លួន ធ្វើជាទាសៈមនុស្សអាក្រក់ដូចកណ្ឌហាលព្រាហ្មណ៍នេះ សបញ្ជាក់ថាព្រះចន្ទកុមារមានចិត្តអំណត់ អត់ធ្មត់ខ្លាំងណាស់ដើម្បីទប់ទល់នឹងបញ្ហា។ ទោះបីជាការអង្វររបស់ព្រះចន្ទកុមារធ្វើឲ្យបិតាទ្រង់មានចិត្តអាណិត និងបញ្ជាឲ្យបញ្ឈប់យញ្ញពិធីពិតមែន ប៉ុន្តែព្រាហ្មណ៍កណ្ឌហាលនៅតែទទូចតវ៉ាឲ្យព្រះបាទឯករាជបន្តការបូជាយញ្ញដដែល។ ព្រះចន្ទកុមារមិនព្រមចុះចាញ់នៅតែព្យាយាមពន្យល់ព្រះបិតាដោយលើកយកហេតុផលជាច្រើន ថាទង្វើបែបនេះមិនមែនជាដំណើរទៅសួគ៌លោកទេ តែជាដំណើរទៅកាន់នរកដោយពិតប្រាកដ។ ឯកណ្ឌហាលក៏នៅតែតវ៉ាដូចមុនដដែលៗទៀត។ ទំនាស់កាន់តែតានតឹងដោយព្រះនាងចន្ទាទេវីសម្រេចចិត្តសម្លាប់ខ្លួនតាមព្រះចន្ទកុមារជាស្វាមី និងបួងសួងសូមឲ្យពួកអមនុស្ស ទេវតាជួយថែរក្សាព្រះនាង និងស្វាមីផង។

ឧទាហរណ៍៖ "ព្រះមាតានៃព្រះបាទឯករាជ និងព្រះបាទវសវតីជាព្រះបិតាទ្រង់ឃាត់ថាៈ ម្នាលកូន! អ្នកកុំជឿកណ្ឌហាលព្រាហ្មណ៍........ផ្លូវហ្នឹងជាផ្លូវទៅកាន់នរកទេកូន"។ (ទំ.១៩៧)

"ព្រះចន្ទកុមារអង្វរថាៈ បពិត្រព្រះបិតា សូមព្រះអង្គកុំសម្លាប់ទូលព្រះបង្គំជាខ្ញុំឡើយ សូមព្រះអង្គរាជទានទូលបង្គំជាខ្ញុំទាំងឡាយឲ្យជាទាសៈនៃកណ្ឌហាលព្រាហ្មណ៍ចុះ ..........ទូលបង្គំជាខ្ញុំទាំងឡាយសុខចិត្តដើរសុំទានគេចិញ្ចឹមជីវិតដែរ"។ (ទំ.១៩៨)

- **ដំណោះស្រាយបញ្ហាដោយអន្តរាគមន៍របស់ព្រះឥន្ទ្រាធិរាជ**

ខណៈដែលទំនាស់ចេះតែតានតឹង និងឈានដល់កម្រិតកំពូលហើយនោះ ដំណោះស្រាយចុងក្រោយនៃដំណើររឿងគឺមានការជួយអន្តរាគមន៍ពីព្រះឥន្ទ្រាធិរាជ។ ក្រោយពីទ្រង់ព្រះសណ្ដាប់ពាក្យរបស់ព្រះនាង-ចន្ទាទេវីរួចមក សក្កទេវរាជទ្រង់គ្រវីដំបងដែកស្រែកគម្រាមដល់ព្រះបាទឯករាជ កុំឲ្យសម្លាប់ជីវិតព្រះចន្ទកុមារដែលជា

មនុស្សប្រកបដោយគុណធម៌យ៉ាងវិសេសឲ្យសោះ។ វត្តមានរបស់ព្រះឥន្ទ្រាធិរាជ បានធ្វើឲ្យព្រះរាជា និងកណ្ឌហាល មានការភិតភ័យយ៉ាងខ្លាំង ហើយទ្រង់បានចេញបញ្ជាយ៉ាងប្រញាប់ឲ្យគេដោះលែងព្រះចន្ទ-កុមារ ជនទាំងឡាយ និងសត្វទាំងឡាយ។ ចំណែកកណ្ឌហាលព្រាហ្មណ៍ត្រូវមនុស្សទាំងឡាយគប់នឹងដុំដី ដល់នូវមរណាទៅសោយទុក្ខនៅនរក។ ព្រះចន្ទកុមារត្រូវបានអភិសេកដោយមានសក្កទេវរាជ និងទេវបរិស័ទ ទេពកញ្ញា សម្ដែងសេចក្ដីអបអរពាសពេញអាកាស។ ព្រះចន្ទកុមារសោយរាជសម្បត្តិប្រកបដោយធម៌ ត្រេកអរក្នុងការបរិច្ចាគទាន លុះអវសានជីវិតបានទៅកើតនៅស្ថានសួគ៌។

ឧទាហរណ៍៖ "ព្រះឥន្ទ្រាធិរាជ ទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយក៏គ្រវីដែកស្រែកគម្រាមព្រះបាទឯករាជថាៈ ម្នាលស្ដេចកាឡកណ្ណិអប្រិយលាមក ចូរឯងដឹងចុះកុំឲ្យអញសំពងក្បាលទាន់! ឯងកុំសម្លាប់បុត្រច្បង ដែលជាអ្នកអង់អាចដូចរាជសីហ៍ឥតសេចក្ដីប្រទូស្ដ!.......ក៏ស្ទុះទៅស្រាយចំណងពីជនទាំងឡាយមួយរំពេច"។(ទំ.២០៣)

**គ. តួនាទីអប់រំក្នុងរឿងចន្ទកុមារជាតក**

ជាការពិតណាស់ រឿង"ចន្ទកុមារ"ស្ថិតក្នុងចលនាពុទ្ធនិយម ដែលចង់បង្ហាញនូវការអប់រំដ៏ជ្រាលជ្រៅដល់មនុស្សឱ្យចេះប្រើធម៌ខន្តីក្នុងការដោះស្រាយបញ្ហាដើម្បីសម្រេចបានជោគជ័យ។

មួយវិញទៀត រឿងនេះបានចូលរួមបង្ហាញទស្សនៈកម្មពៀរដែលជាទ្រឹស្ដីសំខាន់របស់ព្រះពុទ្ធសាសនាគឺថា បុគ្គលណាបានប្រព្រឹត្តអ្វីតែងតែបានទទួលផលចំពោះទង្វើរបស់ខ្លួន ជាក់ស្ដែងកណ្ឌហាលព្រាហ្មណ៍ដែលជាមនុស្សចិត្តបាបមានគំនិតប្រទូស្ដជាមួយមនុស្សល្អមានគុណធម៌យ៉ាងប្រសើរ ចុងបញ្ចប់ត្រូវគេគប់នឹងដុំដីរហូតដល់ស្លាប់ ហើយថែមទាំងទៅសោយទុក្ខនៅនរកទៀត។ ចំណុចនេះធ្វើឲ្យមនុស្សមានទឹកចិត្តប្រព្រឹត្តអ្វីដែលវៀរចាកអកុសល ពោលគឺធ្វើតែអំពើល្អជាកុសលដែលជាកត្តានាំមកនូវសន្តិភាព សាមគ្គីភាព ភាតរភាព សណ្ដាប់ធ្នាប់ និងភាពរីកចម្រើនរុងរឿងដល់សង្គមជាតិ។

ម្យ៉ាងទៀតបុគ្គលជាចៅក្រមដែលមានការវិនិច្ឆ័យក្ដីប្រកបដោយសុគតិ យុត្តិធម៌នោះ រមែងទទួលនូវការគាំទ្រ កោតសរសើរ និងគោរពស្រឡាញ់ពីអ្នកដទៃ។ ផ្ទុយទៅវិញបុគ្គលជាចៅក្រមដែលកាត់ក្ដីប្រកបដោយលោភាគតិ គឺកាត់ក្ដីដោយអយុត្តិធម៌ព្រោះតែលាភសក្ការៈនោះតែងតែទទួលនូវការស្អប់ខ្ពើមពីមនុស្សទូទៅ ចៀសមិនផុតត្រូវទទួលការបាត់បង់តំណែងថែមទៀត។

លើសពីនេះរឿងនេះអប់រំមនុស្សថា មុននឹងធ្វើអ្វីមួយត្រូវចេះគិតពិចារណាឱ្យបានល្អិតល្អន់ និងត្រឹមត្រូវជាមុនសិន ជាពិសេសគឺកុំសេពគប់នឹងបុគ្គលពាលព្រោះបុគ្គលជំពូកនេះតែងនាំខ្លួន ក្រុមគ្រួសារ និងសង្គមជាតិទៅរកសេចក្ដីវិនាសជាក់ជាពុំខាន។ ឧទាហរណ៍ ព្រះបាទឯករាជដែលទៅភប់ប្រសព្វរាប់អានបុគ្គលពាលដូចជាកណ្ឌហាលព្រាហ្មណ៍ រិះតែនឹងធ្វើឱ្យក្រុមគ្រួសាររាជវង្សានុវង្ស និងប្រជារាស្ត្រទូទាំងនគរមានអន្តរាយ នេះក៏ដោយសារការសេពគប់បុគ្គលពាលទាំងងងឹតងងល់ដែរ។

ជាចុងក្រោយរឿងនេះអប់រំយើងឱ្យចេះអត់ធ្មត់ ទប់ទល់ចំពោះកំហឹង ប្រើធម៌អហិង្សាក្នុងការដោះ-ស្រាយបញ្ហា នោះទើបជាជោគជ័យពិតប្រាកដជាជោគជ័យដែលមានន័យយ៉ាងទូលាយសម្រាប់មនុស្សជាតិ។ជាក់ស្ដែងការដែលព្រះចន្ទកុមារអង្វរព្រះរាជាដោយសុខចិត្តធ្វើជាទាសៈកណ្ឌហាល ឬដើរសុំទានគេ។ តាមរយៈទង្វើរបស់ព្រះចន្ទកុមារនេះ យើងអាចយកមកធ្វើជាគំរូមួយដ៏ល្អ សម្រាប់យកមកអនុវត្តក្នុងជីវភាពប្រចាំថ្ងៃផងដែរ។

### ៧.៣.៨. រឿងនារទព្រហ្មជាតក

**ក. ប្រធានរឿង**

ព្រះពោធិសត្វជានារទព្រហ្មគឺនិយាយពីបំពេញឧបេក្ខាបារមីដើម្បីត្រាស់ជាព្រះសម្មាសម្ពុទ្ធ។

**ខ. មូលបញ្ហារឿង**

**បញ្ហាទី១៖ មិច្ឆាទិដ្ឋិរបស់អាលាតអាមាត្យ និងព្រាហ្មណ៍គុណាជីវកៈ**

អាលាតអាមាត្យ ជាមនុស្សប្រកាន់ខ្ជាប់នូវមិច្ឆាទិដ្ឋិ ខ្វះការឈ្វេងយល់ ត្រិះរិះពិចារណារកហេតុផល មិនស្គាល់ល្អអាក្រក់។ គាត់បានណែនាំព្រះរាជាឱ្យធ្លាក់ក្នុងអំពើអកុសល បង្កសង្គ្រាមជាមួយនគរដទៃ។ ម្យ៉ាងទៀតអាលាតអាមាត្យនេះបានរកឧបាយកលញុះញង់ឱ្យព្រះរាជាទៅជួបនឹងគ្រូគុណាជីវកៈ ដែលជាគ្រូរបស់ខ្លួន និងជាមនុស្សមានមិច្ឆាទិដ្ឋិដូចខ្លួន។ មនុស្សប្រភេទនេះនាំគ្រោះថ្នាក់ដល់នគរណាស់ ព្រោះគេមិនខ្វល់ខ្វាយអ្វីទាំងអស់ក្រៅពីប្រយោជន៍ផ្ទាល់ខ្លួនរបស់គេ។ ចំណែកអាចារ្យគុណាជីវកក៏ជាបុគ្គលមិច្ឆាទិដ្ឋិ គឺយល់ខុសពីសច្ចភាពដឹកនាំមនុស្សទៅរកផ្លូវខុសធ្លាក់នរក ព្រោះគាត់យល់ថាក្នុងលោកនេះមិនមានផលល្អ ផលអាក្រក់ មិនមានលោកដទៃ ជីដូនជីតាឪពុកម្តាយគ្មានគុណ គ្រូអាចារ្យក៏គ្មានគុណដែរ ព្រោះថាសត្វទាំងឡាយជាប់គ្នាដូចជាទូកតូចជាប់នឹងទូកធំទៅតាមខ្សែទឹកដូច្នោះដែរ ព្រោះថាបុគ្គលដែលគេទូន្មានមិនបាននៅតែគេទូន្មានមិនបានដដែល បុគ្គលណាដែលគេរាប់អានថាជាមនុស្សគេទូន្មានបាន ក៏ជាអ្នកមានបទស្រាប់ៗមកទេ។ មនុស្សបែបនេះរឹតតែគ្រោះថ្នាក់ខ្លាំងណាស់ទៅទៀត ពោលគឺនាំឱ្យប្រទេសជាតិធ្លាក់ក្នុងក្តីអន្តរាយ។ ដោយសារការអូសទាញប្រកបដោយភាពប៉ិនប្រសប់របស់គុណាជីវកបណ្តាលឱ្យព្រះរាជាជឿស៊ប់ស្លុងគំនិតលែងចែកទាន លែងធ្វើបុណ្យអ្វីទាំងអស់ ព្រោះយល់ថាជាការឥតប្រយោជន៍។

**បញ្ហាទី២៖ ការវង្វេងស្មារតីរបស់ព្រះបាទអង្គតិ**

ក្រោយពីបានគ្រូគុណាជីវកអូសទាញកុំឱ្យជឿបុណ្យបាប ល្អ អាក្រក់ ហូរហែមក ព្រះបាទអង្គតិក៏វង្វេងស្មារតីជឿស្លុងគំនិតក្នុងផ្លូវអកុសល លែងស្គាល់បុណ្យបាប គុណទោសដូចមុនទៀតហើយ ទៅជាស្តេចចិត្តអាក្រក់អាត្មានិយម ទោះបីជាព្រះនាងរុចាបុត្រីជាទីស្រឡាញ់ខិតខំលើកហេតុផលមកពន្យល់បែបណាក៏ដោយ។ ព្រះរាជាអង្គតិត្រូវអំពើអកុសលដឹកនាំឱ្យលែងដឹងខុសត្រូវ លែងជាស្តេចមានព្រហ្មវិហារធម៌ ទសពិធរាជធម៌ចំពោះរាស្ត្រទៀតរបស់ព្រះអង្គហើយ។ ប្រការនេះ គឺជាគ្រោះថ្នាក់ណាស់សម្រាប់អ្នកដឹកនាំប្រទេសដោយសារតែការបាត់បង់នូវចិត្តឧបេក្ខាស្តាប់តែការញុះញង់របស់មនុស្សតែមួយក្រុម។ អ្នកដឹកនាំត្រូវមានចិត្តកណ្តាលស្តាប់ហេតុផលឱ្យបានគ្រប់ជ្រុងជ្រោយ ឈរលើគោលការណ៍ត្រឹមត្រូវទើបសង្គមមានសន្តិភាព។

**បញ្ហាទី៣ ការបំពេញនូវឧបេក្ខាបារមីរបស់ព្រះពោធិសត្វ(នារទព្រហ្ម)**

នៅពេលឃើញបិតាស្លុងទៅក្នុងលទ្ធិរបស់គុណាជីវកហើយ ព្រះនាងរុចាខិតខំប្រើប្រាជ្ញារបស់ខ្លួនពន្យល់អូសទាញព្រះបិតាឱ្យងាកមកសភាពជាមនុស្សដូចដើមវិញ។ ប៉ុន្តែបំណងព្រះនាងមិនបានសម្រេច ព្រះនាងក៏បួងសួងថ្វាយបង្គំគ្រប់ទិសទាំងដប់រកអ្នកទ្រទ្រង់មកជួយ។ គ្រានោះព្រះនារទព្រហ្ម ដែលតែងតែប្រមើលមើលជីវិតសត្វលោក ព្រះអង្គក៏និម្មិតជាឥសីចុះពីអាកាសមកឈរចំពោះព្រះភក្ត្រព្រះបាទអង្គតិ។ ព្រះពោធិសត្វនទព្រហ្មបានទូន្មានព្រះបាទអង្គតិឱ្យយល់ជ្រួតជ្រាបអំពីទោសនៃអំពើអកុសល និងផលនៃអំពើកុសល។ ព្រះរាជាក្រោយពីទ្រង់

ព្រះសណ្ដាប់ព្រះមហាបុរសបរមពោធិសត្វទូន្មានរួចមក ព្រះអង្គក៏ភិតភ័យតក់ស្លុតញាប់ញ័រចំពោះអំពើអកុសល ដែលនាំឱ្យធ្លាក់ទៅក្នុងអបាយភូមិ ហើយត្រេកអរប្រែស្មារតីមករកអំពើកុសលវិញ។

**គ. តួនាទីអប់រំនៃរឿងនារទព្រហ្មជាតក**

ឧត្តមគតិសំខាន់នៃរឿងនារទព្រហ្មនេះផ្ដោតជាសំខាន់ទៅលើឧបេក្ខាធម៌ គឺធម៌ទី៤នៃព្រហ្មវិហារធម៌។ រឿងនេះអប់រំមនុស្សពិសេសឱ្យអ្នកដឹកនាំចេះត្រិះរិះពិចារណាឱ្យបានម៉ត់ចត់ កុំចេះតែស្ដាប់តាមពាក្យញុះញង់របស់ជនអគតិមួយចំនួន ហើយត្រូវចេះស្ដាប់ឱវាទរបស់ជនជាបណ្ឌិតដែលដឹកនាំក្នុងផ្លូវធម៌ឆ្ពោះទៅរកសេចក្ដីសុខចម្រើន បានសេចក្ដីថាត្រូវប្រកាន់ផ្លូវកណ្ដាល(មជ្ឈិមាបដិប្បទា) តាមមាគ៌ាអដ្ឋង្គិកមគ្គរបស់ព្រះសម្មាសម្ពុទ្ធ ជាមាគ៌ាដ៏ឧត្ដុង្គនាំសត្វទៅកាន់បរមសុខ។ ឧបេក្ខាបារមី សំដៅដល់ការតាំងចិត្តព្រងើយកន្តើយ មិនមានសោមនស្ស ទោមនស្សក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ក្នុងទ្វារទាំង៥ ក្ដី ការតាំងចិត្តឱ្យនៅជាកណ្ដាល មិនត្រេកអររីករាយ មិនមានថ្នាំងថ្នាក់អាក់អន់ ចំពោះសត្វ និងសង្ខារទាំងឡាយ ទោះមានឧបការគុណក្ដី មិនមានឧបការគុណក្ដី ឬក៏សត្វដែលគួរស្រឡាញ់រាប់អានក្ដី សត្វដែលគួរស្អប់ខ្ពើមធុញទ្រាន់ក្ដី ក៏នៅតែតាំងចិត្តឲ្យព្រងើយ។ តាមប្រក្រតីទៅបាន តែងមានស្មារតី នឹកឃើញដឹងខ្លួនជានិច្ចមិនភ្លាំងភ្លាត់ យ៉ាងនេះ ហៅថាឧបេក្ខាបារមីៗប្រែថា គុណជាតិជាគ្រឿងដល់នូវត្រើយគឺព្រះនិព្វាន ព្រោះតែការតាំងចិត្តព្រងើយៗ កណ្ដាលៗ។ បារមីនេះ ចែកចេញជា៣យ៉ាងគឺៈ

- **បុត្តទារស្សបិ** ការតាំងចិត្តឲ្យព្រងើយកន្តើយចំពោះបុត្រភរិយា ព្រមទាំងសត្វនិងសង្ខារ ចិត្តដែលតាំងស៊ប់នៅជាកណ្ដាលយ៉ាងនេះ ហៅថា **ឧបេក្ខាបារមី។**
- **អត្តនោ អង្គស្សបិ** ការតាំងចិត្តព្រងើយកន្តើយ ចំពោះអវយវៈរបស់ខ្លួន ព្រមទាំងចំពោះសត្វនិងសង្ខារ ចិត្តដែលតាំងនៅស៊ប់យ៉ាងនេះ ហៅថា **ឧបេក្ខាឧបបារមី។**
- **ជីវិតស្សបិ** ការតាំងចិត្តព្រងើយកន្តើយ ចំពោះជីវិតព្រមទាំងចំពោះសត្វនិងសង្ខារ ចិត្តដែលតាំងស៊ប់នៅជាកណ្ដាលយ៉ាងនេះហៅថា **ឧបេក្ខាបរមត្ថបារមី**។

**៧.៣.៩. រឿងវិធុរបណ្ឌិតជាតក**

**ក. ប្រធានរឿង**

រឿងវិធុរបណ្ឌិត បានបង្ហាញឲ្យឃើញពីការកសាងបារមីដ៏មហាអស្ចារ្យរបស់ព្រះពោធិសត្វ ដើម្បីបានត្រាស់ដឹងជាព្រះពុទ្ធ ដែលអាចកំណត់បានថា ជាការកសាងសច្ចៈបារមី របស់វិធុរបណ្ឌិតនេះឯង ។

**ខ. មូលបញ្ហារឿង**

ជុំវិញប្រធានរឿង យើងអាចកំណត់បាននូវបញ្ហាជាច្រើន ដែលជាមែកធាងជុំវិញការកសាងសច្ចៈបារមីរបស់វិធុរបណ្ឌិត នូវបញ្ហាមួយចំនួនដូចជា ៖

**បញ្ហាទី១ : ការវិវាទគ្នារបស់ស្ដេចទាំងបួន ជុំវិញបញ្ហាសីល**

ព្រះវិធុរបណ្ឌិត ជាបុគ្គលដែលពោរពេញដោយប្រាជ្ញាឈ្លាសវៃ ទាំងក្នុងគតិលោក និងគតិធម៌ គឺបានសម្ដែងនូវធម៌ដល់ជនទាំងឡាយ ដែលស្ថិតនៅក្រោមឱវាទនៃព្រះធម៌។ ព្រះបាទធនញ្ជ័យកោរព្យ ក៏ស្ថិតនៅក្រោមឱវាទនៃព្រះវិធុរបណ្ឌិត ដែលទ្រង់តែងតែធ្វើឧបោសថរក្សាសីលជាប្រចាំ ជួនជាថ្ងៃមួយបានជួបស្ដេចបីអង្គ កំពុងធ្វើសមណៈធម៌ដែរ។ ស្ដេចទាំងបួនបានជួបគ្នា ក៏អួតអាងបង្ហាញពីសីលរបស់ខ្លួនរៀងៗខ្លួន ថាសីលរបស់ខ្លួនគឺប្រសើរជាងហេតុនេះទើបបង្កឱ្យមានបញ្ហាស្មុគស្មាញ មានទំនាស់ វិវាទគ្នាកើតឡើង ដោយដោះស្រាយបញ្ហាមិនបាន ទ្រង់បាន

ទៅជួបព្រះវិធុរបណ្ឌិត ឱ្យជួយស្រាយចម្ងល់ពីការរក្សាសីលនេះ។ វិធុរបណ្ឌិតបានស្រាយចម្ងល់រួច ក៏សម្តែងនូវធម៌ទេសនា ដែលធ្វើឱ្យស្តេចទាំងបួនយល់ជ្រួតជ្រាបពីសីលដ៏ពិតប្រាកដ គឺគ្មានសីលណាល្អជាងសីលណានោះទេ សីលរបស់ព្រះអង្គនីមួយៗ ល្អប្រសើរទាំងអស់ គឺសុទ្ធតែធ្វើឱ្យមានចិត្តជ្រះថ្លាមានចិត្តស្ងប់ វៀរចាកនូវកិលេសបានដូចគ្នា ទើបកើត បានជាសីលនេះឯង។ ដោយក្តីអំណរយ៉ាងល្អគុណពេក ស្តីពីការសម្តែងធម៌នេះ ស្តេចទាំងបួនបានថ្វាយនូវវត្ថុមានតម្លៃ ដូចជាសំពត់ទិព្វ សុវណ្ណមាលា គោ១ពាន់ និងស្តេចនាគ គឺកែវមុណី ដល់ការបូជាដែល ប្រកបដោយសទ្ធាជ្រះថ្លា ស្តីអំពីការសម្តែងនូវព្រះធម៌ដ៏ចម្រើនធ្វើឱ្យមនុស្សចេះរក្សាសីល ទើបនាំមកនូវចិត្តស្ងប់ ទើបអាចបំបាត់នូវមូលហេតុនៃទំនាស់ឱ្យកាន់តែជ្រាបច្បាស់ថែមទៀត ។

**បញ្ហាទី២ : ការឈឺស្គមស្គាំងរបស់នាងវិមលាទេវី ព្រោះចង់បរិភោគបេះដូងវិធុរបណ្ឌិត**

បញ្ហាចម្បង ដែលជាមូលហេតុបង្កឱ្យមានរឿងរ៉ាវផ្សេងៗ កើតឡើងជុំវិញការស្វែងរកបេះដូង វិធុរបណ្ឌិតឱ្យនាងវិមលាទេវី ដែលទ្រុឌទ្រោមស្គមស្គាំងព្រះកាយ បញ្ហានេះកើតឡើង ពីព្រោះក្រោយពីស្តេចវិរុណនាគរាជ ត្រឡប់មកពីការធ្វើឧបោសថវិញ ព្រះអង្គបានប្រគល់កែវមុណីបូជាឱ្យវិធុរបណ្ឌិត ជាមនុស្សប្រកបដោយបញ្ញាបារមី មានវាចាពីរោះ ពេលទ្រង់សម្តែងធម៌ទេសនាដ៏ប្រសើរក្រៃលែង។ ក្រោយពីបានស្តាប់ព្រះស្វាមីនិយាយពីព្រះវិធុរជាមនុស្សជាទីប្រសើរនេះរួចមក ធ្វើឱ្យនាងកើតមានចិត្តចង់ស្តាប់ព្រះធម៌ទេសនា របស់ព្រះវិធុរឱ្យខានតែបាន រហូតទៅជាធ្លាក់ទ្រុឌទ្រោម ស្គាំងស្គមព្រះកាយ។ ស្តេចនាគដោយឃើញវិមលាទេវីឈឺដូច្នេះក៏សួរ។ នាងប្រាប់ថាចង់ទទួលទានបេះដូងព្រះវិធុរបណ្ឌិត បើពុំបានមុខជាស្លាប់ហើយ។ ក៏ប៉ុន្តែសំណើរនេះ ត្រូវបានស្តេចវិរុណនាគបដិសេធដោយថានាងចង់បានព្រះអាទិត្យ ព្រះចន្ទ យើងធានានឹងយកឱ្យនាងបាន ប៉ុន្តែវិធុរបណ្ឌិតគ្រាន់តែចង់ឃើញ លោកក៏ មិនងាយនឹងបានឃើញផង កុំថាឡើយរហូតដល់ទៅចង់ទទួលទានបេះដូងទៀតនោះ វាប្រាកដជាពុំបានឡើយ ។ វិធុរបណ្ឌិតជាបុគ្គលថ្លៃថ្លាពិសេស សូម្បីតែព្រះបាទធនញ្ជ័យកោរព្យ ក៏គោរពស្រឡាញ់ព្រមទាំងចាត់ទុកជាមនុស្សជាទីគាប់ចិត្តប្រសើរក្នុងជីវិតផ្ទាល់ ដោយធ្វើឱ្យរាស្ត្រក្នុងនគរកុរុរដ្ឋ មានសេចក្តីសុខ ចម្រើន ក្រោយពីស្តាប់នូវឱវាទនៃធម៌ទេសនារួចហើយ ។

ទាំងនេះជាបញ្ហាដែលពិបាកស្មុគស្មាញ របស់ស្តេចវិរុណនាគ ដែលចង់ឱ្យមហេសីជាសះស្បើយនោះ គឺពិតជាពិបាកដោះស្រាយណាស់។ ក្រោយមកនាងឥរន្ទតីជាបុត្រី បានមើលឃើញពីអាការ នៃមាតាដូច្នេះ ក៏សម្រេចចិត្តតាមបិតាឱ្យយកប្តីដែលជាអ្នកមានអំណាចសក្តិសិទ្ធ មានសមត្ថភាពខ្លាំង ពូកែ ទើបអាចយកអាសារឿងនេះបាន ។ ពេលនោះនាងក៏បាន ក្លែងខ្លួនជាស្រីក្រមុំច្រៀងរាំរពើន ហើយប្រកាសថា "**បើនរណាអាចយកបេះដូងវិធុរបណ្ឌិតបាន ខ្លួននឹងក្លាយជាភរិយានៃអ្នកនោះ**"។ ពេលនោះបុណ្ណកយក្ស បានលង់នឹងសម្រស់នាង ហើយក៏ព្រមយកអាសាដោយធានាថានឹងយកបេះដូង វិធុរបណ្ឌិតឱ្យបាន ។ នេះជាបញ្ហាដែល នាំឱ្យកើតមាននូវបញ្ហាផ្សេងៗ ទៀតជុំវិញការស្វែងរកបេះដូង វិធុរបណ្ឌិតនេះឯង ។

**បញ្ហាទី៣ : ការគោរពពាក្យសច្ចៈ**

នៅពេលដែលបុណ្ណកយក្ស បានក្លែងខ្លួនជាមាណពមកនគរកុរុរដ្ឋ មកសុំព្រះបាទធនញ្ជ័យ កោរព្យលេងភ្នាល់ល្បែងបាស្កា ដោយដាក់សេះមនោម័យមានល្បឿនលឿន និងកែវមណីមនោហរ ដែលអាចឆ្លុះមើលឃើញរូបភាពអ្វីៗនៅក្នុងពិភពលោកបានតាមចិត្តចង់ គឺក្នុងគោលបំណងដើម្បីយកបេះដូងវិធុរបណ្ឌិត។ ស្តេចយល់ព្រមហើយថាបើចាញ់នឹងប្រគល់ទ្រព្យសម្បត្តិក្នុងនគរ តាមតែត្រូវការ លើកលែងតែព្រះអង្គ និងមហេសី ព្រមទាំងសិរីរាជ

សម្បត្តិចេញ។ បុណ្ណកយក្សភ្នាល់ឈ្នះក៏សុំតែវិធុរបណ្ឌិតប៉ុណ្ណោះ តែស្ដេចធនញ្ជ័យកោរព្យមិនយល់ព្រម គឺចាត់ទុកវិធុរបណ្ឌិត ជាមនុស្សជាទីគាប់ចិត្តស្មើជីវិតខ្លួន ទ្រង់មិនអាចឱ្យបានឡើយ។ រួចក៏កើតមានការវិវាទប្រកែកគ្នា ដោយស្តេចមិនគោរពពាក្យសត្យរបស់ខ្លួន ដូចនេះទើបបុណ្ណកយក្សសុំឱ្យវិធុរបណ្ឌិតមកដោះស្រាយបញ្ហានេះ។ វិធុរបណ្ឌិតសុខចិត្តលះបង់ជីវិត គឺដើម្បីពាក្យពិតរបស់របស់ចៅហ្វាយនាយ និងនគរកុំឱ្យកើតអន្តរាយមានទំនាស់វិវាទកើតឡើងព្រោះតែខ្លួននិងដើម្បីសេចក្តីសុខរាស្ត្រទូទាំងនគរ ព្រមទាំងឱ្យស្តេចគោរពនូវពាក្យសច្ចៈរបស់ទ្រង់ ដែលទ្រង់បានសន្យានោះកុំឱ្យខុសនឹងពាក្យពិតទៀងត្រង់របស់ស្តេច។ ដូចនេះវិធុរបណ្ឌិត គិតថាមានតែការប្រកាន់ខ្ជាប់នូវពាក្យសច្ចៈជាត្រីមុខ គឺលះបង់ជីវិតផ្ទាល់ខ្លួន ដើម្បីប្រយោជន៍ជាតិរួម ជាសំខាន់ នោះមានតែការគោរពពាក្យសច្ចៈទេ ដែលជាគុណធម៌ដ៏ប្រសើរ នាំឱ្យសត្វលោកមានសេចក្តី សុខចម្រើន ទើបសម្រេចចិត្តទៅតាម បុណ្ណកយក្សដោយឥតលក្ខខណ្ឌ ទាំងនេះជាដំណោះស្រាយដោយសន្តិវិធីរបស់ព្រះវិធុរបណ្ឌិត ។

ដោយសេចក្តីពិតទៀតត្រង់ ទោះបីយក្សចាប់បោះបោកសម្លាប់យ៉ាងណាក៏មិនស្លាប់ ដោយសារអំណាចនៃពាក្យសច្ចៈ នោះទើបខាខាំងរាំង មិនឱ្យអន្តរាយកើតមានដល់ជីវិតបាន។ ដោយទ្រង់បាន សួរដឹងពីដំណើររឿង ថាហេតុអ្វីក៏ចង់យកបេះដូងរបស់ខ្លួនទៅឱ្យវិរុណនាគនោះ ក៏បានសម្តែងនូវធម៌ ទេសនាឱ្យបុណ្ណយក្សស្តាប់។ បុណ្ណកយក្សស្តាប់ហើយកើតមានចិត្តបុណ្យមានចិត្តជ្រះថ្លាបានដឹងនូវកំហុសរបស់ខ្លួនថាយកខ្លួនមនុស្ស ដែលជាទីប្រសើរក្រៃលែងទៅសម្លាប់នោះ គឺជាការប្រព្រឹត្តខុសនូវ សាធុនរធម៌ហើយតើគិតហើយទើបសម្រេចចិត្តដោះលែងវិធុរវិញ ប៉ុន្តែវិធុរបណ្ឌិតដោយចង់គោរព ពាក្យសច្ចៈពាក្យពិតហើយនឹងចង់ឱ្យបុណ្ណកយក្សគោរពពាក្យសន្យា ក៏បានសម្រេចចិត្តទៅពិភពនាគបន្តទៀត ប៉ុន្តែដោយសេចក្តីធម៌នាងវិមលាទេវីគ្រាន់តែស្តាប់ ឮនូវព្រះធម៌ទេសនាភ្លាមនោះធ្វើឱ្យនាងជាសះស្បើយមួយរំពេច ទើបស្តេចថាព្រះធម៌ទេសនានេះហើយ ជាបញ្ញារបស់វិធុរបណ្ឌិតទើបជាបេះដូងរបស់ព្រះវិធុរបណ្ឌិតពិតប្រាកដ ។

**គ. តួនាទីអប់រំនៃរឿងវិធុរបណ្ឌិតជាតក**

- កតញ្ញូ ជាប្រភពនៃសេចក្តីចម្រើន សេចក្តីស្រឡាញ់ ជាប្រភពនៃសុភមង្គល
- លះបង់ប្រយោជន៍បុគ្គល ដើម្បីប្រយោជន៍រួម
- ការលេងល្បែងភ្នាល់ នាំឱ្យវិនាសបាត់បង់ប្រយោជន៍ ការត្រិះរិះពិចារណា ជាប្រភពនៃជ័យជំនះ
- បញ្ញា ជាអាវុធសម្រាប់ដោះស្រាយបញ្ហាដោយសន្តិវិធី
- ការប្រកាន់ខ្ជាប់នូវពាក្យសច្ចៈ នាំឱ្យមានសីលធម៌ល្អ និងសេចក្តីថ្លៃថ្នូរ
- ការគោរពពាក្យសច្ចៈ គឺជាប្រភពនៃគុណធម៌ដ៏ល្អប្រសើរ
- ការគោរពពាក្យសន្យា ជាប្រភពនៃជោគជ័យ និងក្តីសង្ឃឹម
- ការរក្សាសីល គឺរក្សាបាននូវចិត្តស្ងប់ ចិត្តជ្រះថ្លា វៀរចាកនូវអំពើបាប
- ការស្តាប់នូវព្រះធម៌ទេសនា នាំឲ្យមនុស្សកើតមាននូវបញ្ញា
- សភាវៈ ដែលគួរឱ្យខ្លាច គឺកាយវាចា ចិត្ត ជាទុច្ចរិត
- ប្រភពនៃសេចក្តីទុក្ខ គឺកើតឡើងអំពីតណ្ហានៃចិត្ត

រឿងរ៉ាវផ្សេងៗ ក្នុងគម្ពីរទេសជាតក សុទ្ធតែបានលើកយកទស្សនៈនៃការអប់រំមកពន្យល់បង្ហាញ អ្នកអានអ្នកស្តាប់ឱ្យបានស្គាល់ និងយល់ច្បាស់នូវចលនាពុទ្ធនិយមពិតប្រាកដ។ រឿងវិធុរបណ្ឌិតជា រឿងដែលពោរពេញទៅ

ដោយទស្សនៈអប់រំ ហើយបានបង្ហាញពីការប្រកាន់ខ្ជាប់នូវពាក្យសច្ចៈ គឺសេចក្តីពិតទៀតត្រង់តាំងពីដើមរហូតដល់ចប់ ជាតួអង្គគំរូមានលក្ខណៈពិសេស មានប្រាជ្ញាវាងវៃ មានព្រះទ័យ ទូលំទូលាយចំពោះមនុស្សទូទៅ ដោយសទ្ធាជ្រះថ្លា ហ៊ានលះបង់នូវជីវិតផ្ទាល់ខ្លួន ដើម្បីប្រយោជន៍ជាតិ។ ហេតុនេះទើបធ្វើឲ្យតួអង្គអាក្រក់ ដែលចង់យកបេះដូងវិធុរបណ្ឌិត ដែលជាមនុស្សជាទីគោរពស្រឡាញ់ របស់រាស្ត្រ បែរទៅជាទន់ចិត្ត ទន់កាយ ត្រឡប់ជាមានសទ្ធាជ្រះថ្លា ក៏ព្រោះតែសេចក្តីពិត ក្រោយពីការ សម្តែងនូវធម៌ទេសនាអប់រំនេះហើយ ក៏ធ្វើឱ្យអ្នកទាំងអស់នោះ ប្រែក្លាយទៅជាមានចិត្តស្ងប់ ចូលចិត្ត គោរពស្រឡាញ់ ចង់ស្តាប់ ចង់ឮនូវការសម្តែងព្រះធម៌ទេសនាដ៏ប្រពៃថ្លៃថ្លានេះទៅវិញ ។

ក្រោយពីបានសិក្សារឿង វិធុរបណ្ឌិតនេះរួចមក យើងអាចបង្ហាញបាននូវតម្លៃអប់រំដូចតទៅ ៖

- អប់រំឱ្យមានភាពកតញ្ញូចំពោះមាតាបិតា និងចេះតបស្នងសងគុណ ចំពោះអ្នកមានគុណ។
- អប់រំឱ្យចេះប្រកាន់ខ្ជាប់នូវពាក្យសច្ចៈ គឺសេចក្តីពិតទៀតត្រង់ ដែលជាប្រភពនៃសេចក្តីថ្លៃថ្នូរ និង សីលធម៌ល្អ នោះទើបជាគុណធម៌ដ៏ប្រសើរ ។
- អប់រំឱ្យចេះយកបញ្ញាមកដោះស្រាយបញ្ហាដោយសន្តិវិធី គឺជៀសវាងការប្រើប្រាស់នូវកម្លាំងបាយ នេះជាដំណោះស្រាយដ៏ប្រសើរ ។
- អប់រំឱ្យចេះលះបង់នូវប្រយោជន៍បុគ្គល ដើម្បីប្រយោជន៍រួមជាសំខាន់ ។
- អប់រំឱ្យមានភក្តីភាព និងស្មោះត្រង់ចំពោះស្នេហា គឺជាប្រភពនៃសុភមង្គល ។
- អប់រំកុំឱ្យលេងល្បែង នាំឱ្យវិនាសបាត់បង់ទ្រព្យសម្បត្តិ និងមនុស្សជាទីគាប់ចិត្ត ។
- អប់រំឱ្យចេះត្រិះរិះពិចារណាឲ្យសមហេតុផលជាមុនសិន មុននឹងធ្វើការសម្រេចចិត្ត ។
- អប់រំឱ្យចេះរក្សាសីលប្រកបដោយចិត្តជ្រះថ្លា ដើម្បីជៀសផុតអំពីសេចក្តីទុក្ខ ដែលកើតឡើងអំពីតណ្ហានៃចិត្ត គឺរក្សាបាននូវចិត្តស្ងប់ ។

### ៧.៣.១០. រឿងវេស្សន្តរជាតក

#### ក. ប្រធានរឿង

ព្រះវេស្សន្តរជាជាតិកំណើតពោធិសត្វចុងក្រោយបង្អស់របស់ព្រះពុទ្ធ។ ក្នុងរឿងនេះ ព្រះពោធិសត្វមាននាមថា "វេស្សន្តរ" ។ ឯដំណើររឿងទាំងមូលបានលាតត្រដាងពីដំណើរជីវិតព្រះអង្គដែលផ្សារភ្ជាប់តែ "ការដាក់ទាន" តែប៉ុណ្ណោះ ។ ដូចនេះប្រធានរឿងគឺ "ការបំពេញទានបារមីរបស់ព្រះពោធិសត្វព្រះនាមវេស្សន្តរ"។ ការបំពេញទានបារមីនេះ គឺការបំពេញមហាបរិច្ចាគ៥គឺ ធនបរិច្ចាគបុត្តបរិច្ចាគ ភរិយាបរិច្ចាគ អង្គបរិច្ចាគ និងជីវិតបរិច្ចាគ ។

#### ខ. មូលបញ្ហារឿង

តាមរយៈសាច់រឿងព្រះវេស្សន្តរឃើញថា ការបរិច្ចាគទានទាំង៥នេះ មនុស្សធម្មតាមិនអាចធ្វើបានទេ។ ដូចនេះការបំពេញទានបារមីរបស់ព្រះវេស្សន្តរអាចសម្រេចបានដោយរបៀបណា? ហើយការបរិច្ចាគទាំងនេះជាការងារធម្មតាចំពោះព្រះអង្គ ឬវាស្ថិតក្នុងដំណាក់ការតស៊ូព្យាយាមដែរឬទេ?

តាមដំណើររឿងយើងឃើញថាថ្វីត្បិតតែព្រះវេស្សន្តរជាទេវបុត្រ ដែលច្យុតមកលើផែនដីដើម្បីបំពេញទានបារមីក៏ដោយ ក៏ការបំពេញទាននោះវាមិនមែនជាការងារធម្មតាចំពោះព្រះអង្គឡើយ ព្រោះពេលដែលបំពេញទានព្រះអង្គថា "មនុស្ស" ពោលមិនទាន់ក្លាយជាព្រះនៅឡើយទេ ។

តាមរយៈការបំពេញទានបារមីនេះគេអាចឃើញនូវបញ្ហាចោទសំខាន់ៗមួយចំនួនដូចខាងក្រោម៖

**បញ្ហាទី១-បញ្ហាបុគ្គល និងកម្លាំងប្រជាប្រជាធិបតេយ្យ**

ទោះបីព្រះវេស្សន្តរកើតក្នុងត្រកូលក្សត្រ ឬក៏ក្នុងគំនរទ្រព្យសម្បត្តិងាយស្រួលក្នុងការបំពេញទានក៏ដោយ ក៏ព្រះអង្គត្រូវជួបប្រទះបញ្ហាមួយក្នុងសង្គមមនុស្ស គឺការមិនយល់ស្របពីសំណាក់ប្រជារាស្ត្រទេ។ អ្នកនគរស្រីពិរាស្ត្រ គេមិនទាន់យល់ពីការដាក់ទាននោះទេ ហើយការដែលព្រះវេស្សន្តរបរិច្ចាគទ្រព្យសម្បត្តិរបស់ប្រទេសជាតិ ដោយមិនទាន់បានពន្យល់ដល់មហាជន នោះព្រះអង្គត្រូវតែជួបនឹងឧបសគ្គដែលជា " មតិប្រជាធិបតេយ្យ " នេះដោយខានពុំបាន។ ដូចនេះហើយទើបពេលព្រះអង្គប្រទានដំរីមង្គលឈ្មោះ«បច្ច័យនាគេន្ទ្រ» ទៅពួកព្រាហ្មណ៍នៅស្រុកកលិង្គរាស្ត្រ ព្រះអង្គត្រូវអ្នកនគរស្រីពិរាស្ត្របះបោរបណ្តេញចេញពីនគរ ។

**បញ្ហាទី២-បញ្ហាបុគ្គលនិងព្រហ្មវិហារធម៌**

ជាការពិតណាស់ដែលព្រះវេស្សន្តរបានធ្វើការបរិច្ចាគទានដោយគ្មានរួញរា សូម្បីពេលដែលត្រូវគេបំបរបង់ហើយក៏នៅតែហ៊ានលះបង់គ្មានស្តាយស្រណោះ ដូចជាតាមផ្លូវទៅភ្នំគិរីវង្គត ព្រះអង្គបានដាក់ទានអាជានេយ្យទាំង៤ព្រមទាំងរាជរថទៅពួកព្រាហ្មណ៍ ហើយចែកកូនគ្នាពធ្វើដំណើរដោយជើង។ ប៉ុន្តែប្រការមួយដែលមនុស្សធម្មតាហួតដល់ព្រះពោធិសត្វពិតជាពុំអាចចៀសផុតបាន គឺមនោសញ្ចេតនាជាព្រហ្មវិហារធម៌របស់ឪពុកចំពោះកូន។ ព្រះអង្គអាចដាក់ទានវត្ថុគ្មានវិញ្ញាណដោយគ្មានបង្ខំចិត្ត តែព្រះអង្គត្រូវតែខ្លោចចិត្តអាណិតបុត្រពេលដែលដាក់ទានបុត្រឱ្យទៅព្រាហ្មណ៍ឬស្យាដោយព្យាចាត្តូញត្អែរ យំស្រែកពីការឈឺចាប់របស់បុត្រ ។

ដូចនេះហើយទើបព្រះអង្គរិះតែនឹងប្រហារជូជកចោល។ នេះមិនមែនជាឥទ្ធិពលនៃកំហឹងទេ តែវាជាការជំរុញនៃព្រហ្មវិហារធម៌ ។ល

**បញ្ហាទី៣-បញ្ហាបុគ្គល និងប្រយោជន៍អ្នកដទៃ**

បើនិយាយដល់សម័យកាលនោះ ការចំណាយទ្រព្យធនរបស់ព្រះវេស្សន្តរពុំអាចចាត់ទុកថាជាការប៉ះពាល់ដល់ផលប្រយោជន៍ប្រជាជនឡើយ។ ប៉ុន្តែតាមដំណើររឿង ដំរីបច្ច័យនាគេន្ទ្រ គឺជាកម្មសិទ្ធិផ្ទាល់របស់ព្រះអង្គជាអំណោយរបស់មេដំរីសួគ៌ដែលហោះមកថ្វាយ ។ ដូចនេះហើយទើបព្រះអង្គមិននឹកនាដល់ការប្រឆាំងពីអ្នកនគរស្រីពិរាស្ត្រ។ មុនពេលត្រូវគេបណ្តេញទើបព្រះអង្គយល់ពីបញ្ហានេះ ហើយសុខចិត្តចាកចោលនគរដោយគ្មានប្រកែក។ ប្រការនេះហើយទើបនាំឱ្យព្រះវេស្សន្តរតែងតែស្នាបស្ទង់ ឬអង្វរអ្នកដែលទាក់ទងដល់ផលប្រយោជន៍នៃទានរបស់ព្រះអង្គជានិច្ច ។

- ពេលធ្វើបុត្តបរិច្ចាគ ព្រះអង្គបានអង្វរបុត្រយ៉ាងច្រើន ទាល់តែបុត្រយល់ព្រមដោយខ្លួនឯង ។
- ហើយពេលដាក់ទានភរិយាទៅឱ្យឥន្ទ្រព្រាហ្មណ៍ ក៏ព្រះអង្គចោលកន្ទុយភ្នែកស្ទាបស្ទង់ចិត្តព្រះនាងមទ្រី ទាល់តែព្រះនាងឆ្លើយថាយល់ព្រម ទើបទ្រង់ធ្វើ "ភរិយាបរិច្ចាគ " ។

និយាយរួមការបរិច្ចាគតាមបែបរឿងព្រះវេស្សន្តរ គឺជាការបរិច្ចាគដ៏តឹងតែងជាទីបំផុតដែលមនុស្សសាមញ្ញប្រាកដជាមិនអាចធ្វើបាន មានតែព្រះវេស្សន្តរទើបអាចសម្រេច ។

**បញ្ហាទី៤- សីលធម៌សាសនាតាមរយៈរឿងព្រះវេស្សន្តរ**

ចំពោះមហាបរិច្ចាគទានរបស់ព្រះវេស្សន្តរនេះ អ្នកនិពន្ធមានគំនិតមួយអប់រំមនុស្សឱ្យហ៊ានលះបង់អ្វីៗទាំងអស់ដើម្បីឱ្យមនុស្សជាតិទូទៅពិសេស គឺការដាក់ទានចំពោះជនអ្នកក្រីក្រតោកយ៉ាក។ ព្រះវេស្សន្តរតែងព្យាយាមបំពេញទានបារមីនោះ គឺដើម្បីបានត្រាស់ជាព្រះពុទ្ធ និងបានជួយប្រោសសត្វលោកឱ្យផុតចាកពីអវិជ្ជា។ យើងឃើញ

ថាតួអង្គសំខាន់ៗដទៃទៀតក៏ឯកភាពក្នុងឧត្តមគតិនេះដែរ ដូចជាកុមារជាលីនិងក្រស្នា ទោះបីត្រូវទទួលទណ្ឌកម្មយ៉ាងខ្លោចផ្សាពីតាជូជក ក៏គេនៅតែជួយការពារឧត្តមគតិឪពុករបស់ខ្លួន។ ឯនាងមទ្រីដោយបាត់កូន នាងយំសោកស្វែងរកហួតសន្លប់បាត់ស្មារតី តែនៅពេលដឹងថាព្រះស្វាមីឱ្យកូនជាទានដល់ព្រាហ្មណ៍នោះ ព្រះនាងក៏ស្ងប់ដែរ។ ពិសេសទៅទៀត នាងហ៊ានលះបង់ខ្លួនថ្វាយព្រះឥន្ទ្រដែលប្រែជាភេទព្រាហ្មណ៍ដើម្បីជួយបំពេញបារមីរបស់ស្វាមី ។ ដូចនេះសូម្បីតែទេវតា ព្រះឥន្ទ ក៏ជួយជ្រោមជ្រែងឱ្យព្រះវេស្សន្តរសម្រេចឧត្តមគតិនេះដែរ។ ឧត្តមគតិនេះជាសំណូមពរនៃយុគសម័យដែលមនុស្សកំពុងស្ថិតក្រោមឥទ្ធិពលលទ្ធិព្រាហ្មណ៍ ដែលនិយមគិតតែប្រយោជន៍ផ្ទាល់ខ្លួន។ ឧត្តមគតិនេះហើយជាសីលធម៌និងជាទិសដៅសំខាន់បំផុតនៃលទ្ធិព្រះពុទ្ធសាសនា។ ដូចនេះហើយទើបអ្នកនិពន្ធបានជំរុញឱ្យតួអង្គទាំងអស់បែរឆ្ពោះទៅរកសីលធម៌នេះ ទោះបីបន្សារតួអង្គទាំងឡាយដែលពីដំបូងមិនយល់បញ្ហានេះក៏ដោយ ក៏ទីបញ្ចប់បានអបអរសាទរនឹងទានបារមីរបស់ព្រះវេស្សន្តរដែរ ។

ដោយឡែកពួកព្រាហ្មណ៍ដែលតំណាងឱ្យគុណវិបត្តិនៃសម័យកាលត្រូវបានអ្នកនិពន្ធនិយាយតែពីលក្ខណៈអាក្រក់ និងអន្តរាយ។ មរណភាពរបស់តាជូជក វាស្ថិតក្នុងន័យអត្តទត្ថបុគ្គលលោភលន់ចង់មានបានកេងកិបពីអ្នកដទៃនោះត្រូវវលាយបន្ទាប់ពីការកើតឡើងនូវការដាក់ទាន ពោលគឺការបរិច្ចាគដល់អ្នកដទៃ។

**បញ្ហាទី៥- ការរិះគន់ទស្សនៈបរិច្ចាគបែបពុទ្ធសាសនា**

ការលះបង់ដើម្បីមនុស្សជាតិជាគោលការណ៍ដ៏ប្រពៃ ដូច្នេះបើមនុស្សម្នាក់ៗគិតដល់អ្នកដទៃច្រើនជាងខ្លួននោះពិភពលោកនឹងបានសេចក្តីសុខសាន្ត។ ក៏ប៉ុន្តែតាមការពិនិត្យជីវភាពជាក់ស្តែង យើងឃើញថា ការគិតដល់អ្នកដទៃមានតែតាមរយៈការដាក់ទានតែមួយមុខនេះវាពុំអាចលុបបំបាត់ភាពក្រីក្រតោកយ៉ាករបស់មនុស្សបានឡើយ។ ម្យ៉ាងទៀតវិធីដាក់ទានអាចមានចំណុចអសកម្មជាច្រើនៈ

- អ្នកទទួលមិនអាចលុបបំបាត់ភាពតោកយ៉ាកបានរហូតទេ ពេលអស់ជំនួយត្រូវធ្លាក់ក្នុងសភាពដើមវិញ ។
- អ្នកទទួលអាចក្លាយជាជនអសកម្ម មិនខិតខំដោយខ្លួនឯង អាងលើជំនួយអ្នកដទៃ។
- និយាយរួមទៅគឺ មិនអាចជួយបានគ្រប់អ្នកក្រីក្រតោកយ៉ាកនោះឡើយ ។

ដូចនេះគោលការណ៍មនុស្សធម៌នៃពុទ្ធសាសនាជាគោលការណ៍ល្អប្រសើរ ក៏ប៉ុន្តែវិធីដាក់ទានតាមបែបព្រះវេស្សន្តរ មិនអាចនាំឱ្យយើងអាចសម្រេចគោលការណ៍នេះបានឡើយក្នុងសង្គមបច្ចុប្បន្ន។ ហេតុនេះយើងអាចឈរលើគោលការណ៍នេះបាន តែគួរអនុវត្តវិធីផ្សេងៗដែលជឿនលឿនជាងនេះដូចជាៈ

- តាមរយៈការអប់រំស្មារតីឥស្សូ ឬការអប់រំវិជ្ជាជីវៈ និងសីលធម៌រស់នៅ ។
- ជួយតាមរយៈមធ្យោបាយសាងសង់សាលារៀន មន្ទីរពេទ្យ វត្តអារាម ផ្លូវថ្នល់ ជីកស្រះ ... ។ល ។

ការជួយដូចនេះវាអាចមានប្រសិទ្ធភាពច្រើន និងយូរអង្វែងជាងការដាក់ទានប្រាក់កាស ឬសម្ភារៈ ជាក់ស្តែងចំពោះមុខ។ និយាយរួមគោលការណ៍និងវិធីបែបពុទ្ធសាសនា វាកើតឡើងក្នុងសម័យកាលមួយដែលមនុស្សជាតិកំពុងស្រេកឃ្លាន ការសន្តោសទៅវិញទៅមក ដូចនេះវាមានតម្លៃយ៉ាងលើសលប់។ បច្ចុប្បន្ននេះប្រជាជនដែលគោរពព្រះពុទ្ធសាសនាក៏នៅតែរក្សាគោលការណ៍ និងវិធីនេះដោយមិនបានចាប់អារម្មណ៍ពីការវិវឌ្ឍពីទស្សនៈនិងវិធីសាស្ត្ររស់នៅដែលចេះតែរីកចម្រើនជាលំដាប់។

### ៧.៤. តួនាទីកម្សាន្តតាមរយៈស្នាដៃអក្សរសិល្ប៍មរណមាតា

### ក. ប្រធានរឿង

តាមរយៈការអានរឿងនេះជាច្រើនលើកច្រើនសារ ក្រុមយើងខ្ញុំរកឃើញនិងសំរេចជ្រើសរើសយក ប្រធានរឿងដែលក្តោបសាច់រឿងទាំងមូលនោះគឺ ការមានប្រពន្ធច្រើនគឺជាប្រភពនៃសេចក្តីសុខផងនិងទុក្ខផង ។ ប្រការនេះជាដើមចមនិងជាមូលហេតុដែលនាំឱ្យកើតមាននូវសោកនាដកម្ម ភាពកំសត់ និងទុក្ខវេទនាដែលតែងតែកើតឡើងក្នុងសង្គមគ្រប់សម័យកាលទាំងអស់។ ដូចនេះយើងអាចនិយាយបានថា រឿងមរណមាតាក៏គួរត្រូវគេដាក់បញ្ចូលជាអក្សរសិល្ប៍ដែលមានតំលៃកល ព្រោះយើងឃើញថារឿងនេះ មិនមែនត្រឹមតែអប់រំតាមបែបពុទ្ធសាសនាប៉ុណ្ណោះទេ ពោលគឺទស្សនៈកម្មផល បានន័យថាកម្មបែប ណាផលបែបនោះ ដូចឧទាហរណ៍ជាក់ស្តែងក្នុងរឿងនេះស្រាប់ម្យ៉ាងវិញទៀតរឿងក៏បានបង្ហាញពីគ្រួសារដែលធ្លាប់តែមានសុខសុភមង្គល តែបែរប្រែក្លាយជាគ្រួសារដែលពោរពេញដោយសេចក្តីប្រចណ្ឌ ច្រណែន ឈ្នានីស និងសេចក្តីលោភលន់ ជាពិសេសអំពើហិង្សាក្នុងគ្រួសារ ព្រោះតែស្នេហាត្រីកោណ។ ហើយការដែលមានប្រពន្ធច្រើននេះ គឺមែងតែងតែទទួលគុណវិបត្តិច្រើនជាគុណសម្បត្តិ ។

### ខ-មូលបញ្ហារឿង

យោងតាមខ្លឹមសារនៃរឿងទាំងមូល មូលបញ្ហានៃរឿងគឺបិតគ្រង់ថាតើអ្វីជាបញ្ហាដែលនាំឱ្យកើត រឿងកំសត់និងទុក្ខវេទនាចំពោះនាងមរណមាតា នរណាជាអ្នកធ្វើ ហើយនរណាជាអ្នករងនូវអំពើទាំង អស់នោះ រួចនរណាជាអ្នកទទួលខុសត្រូវនៅក្នុងរឿងនេះ បន្ទាប់មកគេដោះស្រាយបញ្ហាដោយរបៀបណា។ តាមរយៈគំនិតនិងទស្សនៈរបស់កវីនិពន្ធរឿងនេះបានដោះស្រាយតាមបច្ច័យហេតុនិងផល ពោល គឺ ៖

១- បញ្ហាការជឿទៅលើអបិយជំនឿឥតសមហេតុផលនិងមន្តអាគមដែលមានការធ្វើស្នេហ៍។

២- អំពើល្អ ការដឹងគុណ និងដឹងខុសដឹងត្រូវគឺមែងតែងតែទទួលនូវបុណ្យកុសលល្អ ព្រមទាំងយុត្តិធម៌។

៣- ហើយអំពើផិតក្បត់ មានគំនិតព្យាបាទគេតែងតែទទួលនូវបាបកម្មនូវអំពើដែលខ្លួនបានសាងជាក់ជាមិនខានឡើយ គ្រាន់តែថាយូរនិងឆាប់ដោយមិនចាំបាច់រងចាំដល់ទៅជាតិមុខជាតិក្រោយឡើយ ជាពិសេសគឺផលវិបាកនៃការមានប្រពន្ធច្រើន។

៤- ទ្រព្យសម្បត្តិនិងបុណ្យសក្តិពុំមែនជាសេចក្តីសុខពិតប្រាកដនោះទេ ។

៥- បញ្ហាការងប់ងល់នឹងស្នេហាខ្លាំងពេកឬយកស្នេហាជាត្រីមុខនាំឲ្យវិនាស។

### គ. តួនាទីកម្សាន្តបែបអប់រំ

តាមរយៈរឿងមរណមាតា ដូចយើងបានដឹងស្រាប់ហើយថាជារឿងដែលទាក់ទងនឹងគតិធម៌និងគតិលោក។ ជារឿងមួយដែលយើងពុំធ្លាប់បាននឹកគិតដល់ទាល់តែសោះឡើយ ថាវាមានតំលៃពុំអាចកាត់ ថ្លៃបាន ។ អ្នកនិពន្ធច្រើនលើកយកទស្សនៈកម្មផលក្នុងវិស័យពុទ្ធសាសនាផ្សាភ្ជាប់និងលោកិយ៍សច្ចៈ ។

តើការលើកយកទស្សនៈកម្មផលក្នុងវិស័យពុទ្ធសាសនាផ្សាភ្ជាប់នឹងលោកិយ៍សច្ចៈបានផ្តល់ផល ប្រយោជន៍អ្វីខ្លះដល់សង្គមជាតិ ?

– ជារឿងមួយដ៏ល្អមានសារៈសំខាន់បំផុតសំរាប់បំភ្លឺផ្លូវដល់បច្ចាជនឲ្យបានយល់ពីបាតុភូតរបស់ សង្គមក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សជាតិ ។

- អប់រំទាំងផ្លូវកាយផ្លូវចិត្ត សំរាប់ជាស្ពានចម្លងមនុស្សឲ្យផុតពីទុក្ខវេទនាក្នុងឆាកជីវិតរបស់ខ្លួនឱ្យប្រជាជនខ្មែរយើងមានកាយ វាចា ចិត្តស្លូតបូត សុភាពរាបសារ ដឹងខុសត្រូវ មិនច្រងេងច្រងាង។
- អប់រំឲ្យស្អប់អំពើអាក្រក់ស្រឡាញ់អំពើល្អ ដោយគោរពប្រតិបត្តពុទ្ធសាសនាឲ្យបានខ្ជាប់ខ្ជួន ប្រកាន់នូវធម៌អហិង្សានិងខន្តី ជាពិសេសការអប់រំឲ្យមានជំនឿលើកម្មផល ។
- អប់រំឱ្យស្រឡាញ់សន្តិភាព គ្មានគំនិតឈ្លានពានអ្នកដទៃ
- អប់រំឲ្យមានចិត្តមេត្តា ករុណា និងចេះធ្វើទានចំពោះអ្នកក្រីក្រជាពិសេសកត្តញ្ញូចំពោះអ្នកមានគុណ។
- អប់រំចិត្តគំនិតមិនឲ្យលោភលន់ហួសហេតុ ហួសពីសម្ថភាពខ្លួន។
- អប់រំឲ្យប្រកាន់ខ្ជាប់នូវសេចក្តីព្យាយាម
- អប់រំឲ្យចេះយកបញ្ហាមកដោះស្រាយក្នុងជីវភាពរស់នៅប្រចាំថ្ងៃ មុននឹងធ្វើអ្វីមួយៗត្រូវគិតត្រិះ រិះពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយ មិនត្រូវទទួលយកនូវឃោសនាអកុសលទាំងឡាយណាដោយគ្មាន ការពិចារណានោះឡើយ។ ហើយមុននឹងដាក់ទោសទណ្ឌដល់នរណាម្នាក់នោះគួរគប្បីស៊ើបឲ្យបានច្បាស់ ជាមុនសិន។
- អប់រំកុំឱ្យយើងយកស្នេហាធ្វើជាត្រីមុខ។ល។

## ៨. សន្និដ្ឋាន

អក្សរសិល្ប៍ខ្មែរសម័យក្រោយអង្គរ ពោលគឺសម័យលង្វែកនិងឧត្តុង្គ បានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងព្រះពុទ្ធសាសនា ហើយពិតជាមានការរីកចម្រើនឆ្ពោះទៅរកយុគមាសនៃអក្សរសាស្ត្រខ្មែរតាមរយៈស្នាដៃ និងអ្នកនិពន្ធដ៏សម្បូរបែប។ អក្សរសិល្ប៍ពុទ្ធនិយមមានតួនាទីយ៉ាងសំខាន់ក្នុងការជួយអប់រំជនានុជនជាពុទ្ធបរិស័ទ និងសត្វលោកទូទៅឱ្យវៀរចាកការប្រព្រឹត្តអំពើអាក្រក់ ងាកមកប្រព្រឹត្តអំពើល្អ និងព្យាយាមដុះខាត់សម្អាតចិត្តឱ្យស្អាតតាមមាគ៌ានៃអង្គព្រះសម្មាសម្ពុទ្ធ។ ក្នុងនោះព្រះអង្គបានបន្សល់ទុកមេរៀនដ៏ល្អឯកដូចជា៖ ទ្រឹស្តីបដិច្ចសមុប្បាទ ដែលបង្ហាញបុព្វហេតុនៃការវង្វេងក្នុងកាមភពនៃសត្វលោកងោកងុយរកផ្លូវចេញចាកមិនបានបើនៅតែអវិជ្ជា។ ចំណែកទ្រឹស្តីចតុរារិយសច្ចៈ ឬអរិយសច្ចៈ បង្ហាញពីជីវិតនេះជាទុក្ខ មូលហេតុនៃទុក្ខគឺតណ្ហា ផ្លូវរំលត់ទុក្ខគឺនិព្វាន ហើយមាគ៌ានៃការរំលត់ទុក្ខគឺតាមរយៈអដ្ឋង្គិកមគ្គ។

អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធ ពោលគឺទសជាតកបានរួមចំណែកបណ្តុះការអប់រំដែលជាតួនាទីបើកបង្ហាញផ្លូវមនុស្សឱ្យមើលឃើញពីទុក្ខលំបាកវេទនានៃសត្វលោកទាំងពួង ហើយការចេញចាកទុក្ខគឺមានតែការសាងព្រះផ្នួសស្វែងរកសេចក្តីពិតដែលជាសច្ចភាពរបស់ធម្មជាតិនេះឯង។

មួយចំណែកទៀតតាមរយៈអក្សរសិល្ប៍ពុទ្ធនិយមក្លាយ ដែលក្នុងនោះមានសាស្ត្រាល្បែងជាដើម គឺបានរួមចំណែកជួយបន្ធូរភាពតានតឹងនៃមនុស្សឱ្យធូរស្រាលបានខ្លះដែរ។ ទន្ទឹមនឹងនេះផងដែរ ទំនោរនៃឥទ្ធិពលរបស់ព្រះពុទ្ធសាសនា បានចាក់ឫសផ្សារភ្ជាប់ជាមួយផ្នត់គំនិត ជំនឿទំនៀមទម្លាប់ ប្រពៃណីរបស់ជនជាតិខ្មែរយ៉ាងជ្រាលជ្រៅតាមរយៈការប្រើប្រាស់អក្សរសិល្ប៍ធ្វើជាឱសថសម្រាប់បំពេលបួងលោមអារម្មណ៍ និងព្យាបាលជំងឺផ្លូវចិត្តខេមរជនឱ្យបានល្ហែល្ហើយធូរស្បើយពីទុក្ខលំបាកផងទាំងពួង។

ហេតុនេះហើយបានជាយើងឃើញមានស្នាដៃជាច្រើនកើតមានឡើង ដោយសារអ្នកនិពន្ធអក្សរសិល្ប៍បានចូលរួមចំណែកឆ្លុះបញ្ចាំងពីសង្គមជាក់ស្តែងផង និងផ្តល់ផលប្រយោជន៍ដល់ជាតិមាតុភូមិក្នុងការបណ្តុះស្មារតីប្រជាជនខ្មែរ ដែលធ្លាប់បាក់ស្បាតដោយសារសង្គ្រាមរ៉ាំរ៉ៃអស់ពេលជាយូរ ។ អក្សរសិល្ប៍បានផ្តល់ឱកាសឱ្យអ្នកនិពន្ធយើង

បានបញ្ចេញស្នាដៃផ្សំជាមួយទ្រឹស្តីព្រះពុទ្ធសាសនា ដែលមានក្នុងគម្ពីរទេសជាតកមកផ្សំជាមួយទំនោរ ផ្នត់គំនិត និងមនោសញ្ចេតនាដែលកើតពិតៗក្នុងជីវភាពរស់នៅរបស់ជាតិខ្មែរផ្ទាល់តែម្តង ។

ដូច្នេះអក្សរសិល្ប៍ពុទ្ធនិយមសម័យក្រោយអង្គរ ពិតជាបានរួមចំណែកយ៉ាងសំខាន់ក្នុងតួនាទីដឹកនាំ ក៏ដូចជាអប់រំមនុស្សឱ្យដើរតាមគន្លងរបស់ព្រះពុទ្ធសាសនាស្របតាមពុទ្ធវចនៈ ក៏ដូចជាបានចូលរួមកាត់បន្ថយភាពតានតឹងនៃប្រជាជនដែលមានការពិបាករស់នៅក្នុងជីវភាពប្រចាំថ្ងៃ។ លើសពីនេះទៅទៀត អក្សរសិល្ប៍សម័យនោះ បានបន្សល់ទុកនូវស្នាដៃ ឯកសារ គម្ពីរ ក្បួនខ្នាតជាច្រើន ជាកេរមត៌កដ៏មានតម្លៃខ្លឹមសារជាច្រើនឱ្យកូនខ្មែរជំនាន់ក្រោយសិក្សារៀនសូត្រ និងបណ្តុះស្មារតីស្នេហាជាតិមាតុភូមិ ដើម្បីចូលរួមចំណែកកសាង និងអភិវឌ្ឍសង្គមជាតិទាំងមូល។

# ឯកសារយោង


– ក្រសួងអប់រំ, អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២
– លាង ហាប់អាន សិក្សាអត្ថបទ ភាគទី១ (សិក្សាស្នាដៃអក្សរសិល្ប៍ខ្មែរ) ភ្នំពេញ ១៩៦៦
– បណ្ឌិត ញ៉ុក ថែម បញ្ញាសជាតក (១៩៦៣)
– ជុំ កាណាល់ សិក្សាស្វែងយល់អក្សរសាស្ត្រខ្មែរសង្ខេបបែបទំនើប (១៩៩៦)
– បណ្ឌិត ឈឹម ស៊ុមន៍ សង្ខេបទសជាតក (១៩៥៩)
– លី ធាមតេង អក្សរសាស្ត្រខ្មែរ (១៩៦៦)
– បណ្ឌិត ធ សោ អក្សរសិល្ប៍ពុទ្ធនិយម (១៩៩៤)
– បណ្ឌិត ញ៉ុក ថែម បញ្ញាសជាតក (១៩៦៣)
– បណ្ឌិត ញ៉ុក ថែម មហាវេស្សន្តរជាតក (១៩៦៣)
– ត្រឹង ងា , អរិយធម៌ខ្មែរ, ឆ្នាំ១៩៧៥
– លាង ហាប់អាន, *សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរសម័យនគរភ្នំ ដល់សម័យឧដុង្គ (ស.វ.ទី១ ដល់ឆ្នាំ១៨៥៩)* ឆ្នាំ១៩៦៧
– ឃីង ហុកឌី, *ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ* ឆ្នាំ១៩៧៧
– សិលាចារឹកនគរវត្ត និងបទានុក្រម ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ឆ្នាំ១៩៥៨។
– គោលប្រវត្តិនៃអក្សរសាស្ត្រខ្មែរ ដោយប្រជុំសាស្ត្រាចារ្យ ការផ្សាយរបស់បណ្ណាគារភ្នំពេញ ឆ្នាំ១៩៥៦។
– ម៉ក់ ស៊ីនេត *អក្សរសិល្ប៍ក្រោយអង្គរ*
– ឃួន សុខម្ភ *គំនិតរិះគន់សង្គមក្នុងអក្សរសិល្ប៍ខ្មែរ* សន្និសីទធ្វើទៅសាលាជាតិខាងរដ្ឋបាល នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៤ នៅភ្នំពេញ
– សម្ដេច ជួន ណាត, វចនានុក្រមខ្មែរ ១៩៦៧
– ក្រសួងអប់រំ, សៀវភៅគ្រូ ភាសាខ្មែរ ថ្នាក់ទី១០,២០១២
– បណ្ឌិត ហង់ជួន ណារ៉ុន, វិភាគទាននៃការសិក្សាអក្សរសិល្ប៍ខ្មែរ, ទំព័រ៥២, ២០១៩
– ទេស ហាវ, ទេព ណន, ធុក ផល្លីនី, តែ ស្រីសោភ័ណ វប្បធម៌អរិយធម៌ខ្មែរ ទំព័រ៧៤, ២០០៩